

# របាយការណ៍ប្រចាំឆ្នាំ
# ២០២៣

# មាតិកា


## អំពីធនាគារ

| | |
|---|---|
| សារពីប្រធានក្រុមប្រឹក្សាភិបាល | ៤ |
| សារពីអគ្គនាយក | ៦ |
| សារតាធនាគារ | ៨ |
| របាយការណ៍សម្រេចបានឆ្នាំ២០២៣ | ១០ |
| បណ្តាញសាខា | ១១ |
| វឌ្ឍនភាពនៃធនាគារ | ១២ |
| ស្ថាប័នដៃគូយុទ្ធសាស្ត្រ | ១៤ |

## លទ្ធផលអាជីវកម្ម

| | |
|---|---|
| គម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើន ក្នុងវិស័យទេសចរណ៍ (TRCS) | ១៦ |
| គម្រោងហិរញ្ញប្បទានដោយផ្ទាល់ | ១៧ |

## ព្រឹត្តិការណ៍ប្រចាំឆ្នាំ

| | |
|---|---|
| កិច្ចប្រជុំប្រចាំឆ្នាំ | ២០ |
| កម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ | ២១ |
| ព្រឹត្តិការណ៍ផ្សេងៗ | ២២ |
| ទំនួលខុសត្រូវសង្គម | ៣០ |
| អនុស្សរណៈនៃការយោគយល់ | ៣១ |

## រចនាសម្ព័ន្ធធនាគារ ៣២

## ក្រុមប្រឹក្សាភិបាល ៣៣

## គណៈគ្រប់គ្រងជាន់ខ្ពស់ ៣៨

## អភិបាលកិច្ចសាជីវកម្ម

| | |
|---|---|
| កិច្ចប្រជុំក្រុមប្រឹក្សាភិបាល | ៤៣ |
| គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម | ៤៤ |
| គណៈកម្មការសវនកម្ម | ៤៧ |
| គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ | ៤៩ |

## របាយការណ៍ហិរញ្ញវត្ថុ

| | |
|---|---|
| របាយការណ៍ហិរញ្ញវត្ថុ | ៥០ |



## សារពីប្រធាន ក្រុមប្រឹក្សាភិបាល

"គិតត្រឹមដំណាច់ឆ្នាំ២០២៣ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានចូលរួមផ្តល់ហិរញ្ញប្បទានដល់អាជីវកម្មគោលដៅចំនួន ៣ ៤០០ សហគ្រាស ក្នុងទំហំទឹកប្រាក់សរុបប្រមាណ ៥០០ លានដុល្លារអាម៉េរិក តាមរយៈយន្តការ ២ គឺ គម្រោងហិរញ្ញប្បទានដោយផ្ទាល់ និង គម្រោងសហហិរញ្ញប្បទានដែលសហការអនុវត្តជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ក្នុងនោះការផ្តល់ឥណទានដោយផ្ទាល់ពីធនាគារ ត្រង់ទៅអតិថិជន មានចំនួនប្រមាណ ៨៦ លានដុល្លារអាម៉េរិក។"



តាងនាមក្រុមប្រឹក្សាភិបាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ធ.ស.ក) ខ្ញុំមានកិត្តិយសសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ ដែលសង្ខេបអំពីលទ្ធផលការងារផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងឆ្នាំ២០២៣។ លទ្ធផលនេះ ជាសក្ខីភាពនៃការប្តេជ្ញាចិត្ត និងការខិតខំរបស់ ធ.ស.ក ក្នុងនាមធនាគារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដែលត្រូវបានរំពឹងទុកថា នឹងមានតួនាទីកាន់តែសំខាន់រួមចំណែកជំរុញសម្ទុះកំណើនសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ និងធន់នឹងវិបត្តិ។

ជាការពិត, ស្ថានភាពសេដ្ឋកិច្ចសកលបាន និងកំពុងបន្តប្រឈមនឹងហានិភ័យ និងភាពមិនប្រាកដប្រជាខ្ពស់ ដែលបង្កឡើងដោយឥទ្ធិពលពីវិបត្តិ និងព្រឹត្តិការណ៍ធំៗ មានជាអាទិ៍ ស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩, សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន, និងការផ្ទុះឡើងនូវការប្រយុទ្ធរវាងអ៊ីស្រាអែល និងក្រុមហាម៉ាស់ នៅចុងឆ្នាំ២០២៣ ជាដើម។ បន្ថែមលើនេះ, ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុសកល ក៏បានបង្កផលប៉ះពាល់អវិជ្ជមានមួយកម្រិតទៀត ដល់ចលនាសេដ្ឋកិច្ចសកល និងវិស័យសក្តានុពល រាប់ទាំង វិស័យហិរញ្ញវត្ថុ និងធនាគារ។ ជាលទ្ធផល កំណើនសេដ្ឋកិច្ចសកលក្នុងឆ្នាំ២០២៣ បានថមថយមកក្នុងរង្វង់ ៣,២% ស្របពេលដែលកំណើនសេដ្ឋកិច្ចកម្ពុជាសម្រេចបានប្រហាក់ប្រហែលនឹងឆ្នាំ២០២២ ពោលគឺក្នុងរង្វង់ ៥%។

ក្នុងបរិការណ៍នេះ, វិស័យហិរញ្ញវត្ថុនៅកម្ពុជា ដូចគ្នាទៅនឹងបណ្តាប្រទេសក្នុងតំបន់ បានជួបប្រទះនឹងឥទ្ធិពលអវិជ្ជមានដែលឆ្លុះបញ្ចាំងតាមរយៈការថមថយនៃកំណើនឥណទាន ពី ១៩% ក្នុងឆ្នាំ២០២២ មកត្រឹម ៤,៨% ក្នុងឆ្នាំ២០២៣ និងការកើនឡើងនៃអនុបាតឥណទានមិនដំណើរការដល់ ៥,៤% ក្នុងឆ្នាំ២០២៣ ធៀបនឹង ៣,១% ក្នុងឆ្នាំ២០២២។ ទោះស្ថិតក្នុងស្ថានភាពពុំសូវអំណោយផលក្តី, ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានពុះពារក្នុងការបន្តបេសកកម្មផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម។ ជាក់ស្តែង គិតត្រឹមឆ្នាំ២០២៣ ធនាគារបានចូលរួមផ្តល់ឥណទាន តាមរយៈយន្តការឥណទានដោយផ្ទាល់ ទៅដល់អាជីវកម្ម គោលដៅចំនួន ៣៦៥ សហគ្រាស ស្មើនឹងទំហំទឹកប្រាក់សរុបប្រមាណ ៨៦,១៥ លានដុល្លារអាម៉េរិក កើនឡើង ប្រមាណ ៦០% ធៀបនឹងឆ្នាំ២០២២ ខណៈការផ្តល់ឥណទានតាមរយៈគម្រោងសហហិរញ្ញប្បទាន ដោយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម បានផ្តល់ការគាំទ្រដល់សហគ្រាសសរុបចំនួន ៣ ០៩៥ ស្មើនឹងទំហំទឹកប្រាក់សរុបប្រមាណជា ៣៩៤ លានដុល្លារអាម៉េរិក។

ឆ្លងកាត់ប្រតិបត្តិការនាប៉ុន្មានឆ្នាំចុងក្រោយនេះ, យើងសង្កេតឃើញថា បញ្ហាប្រឈមរបស់សហគ្រាសធុនតូច និងមធ្យម នៅមានច្រើន ស្មុគស្មាញ និងលើសពីតម្រូវការហិរញ្ញប្បទាន ដែលត្រូវការរួមចំណែកពីតួអង្គពាក់ព័ន្ធទាំងស្ថាប័នសាធារណៈ, ដៃគូអភិវឌ្ឍន៍ និងជាពិសេស វិស័យឯកជនផ្ទាល់ រួមគ្នាដោះស្រាយក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយភាពម្ចាស់ការ។ ក្នុងន័យនេះ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ប្តេជ្ញាបន្តខិតខំផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម តាមរយៈការពង្រឹងសេវាឥណទានឱ្យកាន់តែមានប្រសិទ្ធភាព ពោលគឺ ផ្តល់ភាពទន់ភ្លន់ឱ្យបានច្រើនលើលក្ខខណ្ឌទទួលបានឥណទាន, កាត់បន្ថយរយៈពេលបញ្ចេញឥណទានជូនអតិថិជន និងជាពិសេស ផ្តល់ឥណទានឱ្យចំគោលដៅ ស្របតាមគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ដែលបានគូសរំលេចក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអតិថិជនទាំងអស់ដែលផ្តល់ការជឿទុកចិត្ត និងតែងចាត់ទុកធនាគារសហគ្រាសធុនតូច និងមធ្យម ជាដៃគូដ៏ស្មោះត្រង់ គាំទ្រដល់ការចាប់ផ្តើម និងការពង្រីក អាជីវកម្មរបស់ខ្លួននាពេលកន្លងមក។ ជាការតបស្នងចំពោះកាយវិការនេះ យើងខ្ញុំទាំងអស់គ្នាក្នុងនាមក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិក ធ.ស.ក ប្តេជ្ញាបន្តធ្វើជាដៃគូល្អ និងបន្តផ្តល់ឥណទានដល់សហគ្រាស ធុនតូច និងមធ្យម ទាំងអស់ ដែលមានតម្រូវការហិរញ្ញប្បទាន ដើម្បីគាំទ្រដល់ការរីកលូតលាស់នៃអាជីវកម្ម សំដៅរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។

បណ្ឌិត ផាន់ ផល្លា
ប្រធានក្រុមប្រឹក្សាភិបាល

# សារពីអគ្គនាយក

ឆ្នាំ២០២៣ សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងក្នុងល្បឿនយឺត ដោយសារការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ការរឹតបន្តឹងនយោបាយរូបិយវត្ថុនៅប្រទេសអភិវឌ្ឍន៍ចម្បងៗ ការកើនឡើងភាពតានតឹងភូមិសាស្ត្រនយោបាយនៅមជ្ឈិមបូព៌ា ជាដើម។ ក្នុងស្ថានភាពនេះ កំណើនសេដ្ឋកិច្ចពិភពលោក ត្រូវបានរំពឹងថាអាចសម្រេចបានទាបជាងឆ្នាំ២០២២។

ការថមថយកំណើនសេដ្ឋកិច្ចពិភពលោក និងតំបន់ បានដាក់សម្ពាធដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេស ការនាំចេញផលិតផលកាត់ដេរ និងការធ្លាក់ចុះនៃវិស័យសំណង់ និងអចលនទ្រព្យ។ ប៉ុន្តែការងើបឡើងនៃវិស័យទេសចរណ៍ កំណើនការនាំចេញផលិតផលមិនមែនកាត់ដេរ និងកំណើនតម្រូវការក្នុងស្រុក បានរួមចំណែកគាំទ្រសេដ្ឋកិច្ចកម្ពុជាសម្រេចបានប្រហាក់ប្រហែលនឹងឆ្នាំ២០២២ ពោលគឺក្នុងរង្វង់៥% (ប្រភព៖ ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមឆ្នាំ២០២៥-២០២៧)។ ការសម្រេចបានកំណើននេះ កើតឡើងដោយសារមានការគាំទ្រ មិនអាចខ្វះបានពីស្ថិរភាពនយោបាយ ដែលជាមូលដ្ឋានគ្រឹះនៃជំនឿទុកចិត្ត និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។



ទន្ទឹមនេះ ប្រព័ន្ធធនាគារនៅកម្ពុជា បន្តរក្សាបានភាពធន់ និងមានវឌ្ឍនភាពជាលំដាប់ ដែលធានាដល់ការរក្សាចីរភាពហិរញ្ញប្បទាន និងសេវាហិរញ្ញវត្ថុចាំបាច់នានា ក្នុងការរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច និងសង្គម។ ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ឥណទាននៅឆ្នាំ២០២៣ នេះ មានកំណើនតិចតួចបំផុតពោលគឺត្រឹមតែ ៤,៨% ប៉ុណ្ណោះ ដែលជាអត្រាទាបបំផុតក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយនេះ ស្របពេលដែលធនាគារជាតិ នៃ កម្ពុជា បានសម្រេចបញ្ចប់ការរៀបចំឥណទានឡើងវិញសម្រាប់វិបត្តិកូវីដ-១៩។ ជាមួយនេះ អនុបាតឥណទានមិនដំណើរការបន្តកើនឡើង ដែលតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវដាក់ចេញវិធានការចាំបាច់នានា ដើម្បីបង្កើនការតាមដាន ការវាយតម្លៃ និងរឹតបណ្តឹងការផ្តល់ឥណទាន ថ្មីបន្ថែម និងការធ្វើស្ត្រេសតេស្តជាប់ជាប្រចាំលើហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា មានចរិតជាធនាគារគោលនយោបាយ ដែលត្រូវបានបង្កើតឡើងដោយឈរលើចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់ខ្លួន ដើម្បីអនុវត្តគោលនយោបាយហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល គាំទ្រដល់សហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ នៅក្នុងឆ្នាំ២០២៣ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា សម្រេចបាននូវលទ្ធផលការងារចម្បងៗមួយចំនួន ដូចជា៖

- ទ្រព្យសកម្មសរុបមានចំនួន ៣២២ លានដុល្លារអាម៉េរិក កើនឡើងប្រមាណ ១៥% ពីឆ្នាំ២០២២ ដែលមាន ២៨១ លានដុល្លារអាម៉េរិក។
- សមតុល្យឥណទានដុលសរុបមានចំនួន ២២០ លានដុល្លារអាម៉េរិក កើនឡើងប្រមាណ ៣% ប៉ុណ្ណោះ ពីឆ្នាំ២០២២ ដោយសារការសងត្រឡប់ជាបណ្តើរៗ ពីអតិថិជនក្រោមគម្រោងសហហិរញ្ញប្បទាន ទាំង ២ ដែលបានអនុវត្តចប់ទាំងស្រុងតាំងពីឆ្នាំ២០២១ និង ២០២២។ ទន្ទឹមនេះ សមតុល្យឥណទានដោយផ្ទាល់ ដែលផ្តល់ត្រង់ពីធនាគារទៅឱ្យសហគ្រាសគោលដៅបានកើនឡើងប្រមាណ ៦១% ធៀបនឹងឆ្នាំ២០២២ ស្មើនឹង ៣២,៧ លានដុល្លារអាម៉េរិក។
- បានបង្កើតចំណែកទីផ្សារថ្មីបន្ថែម គឺ SME Plus និងបានបង្កើនទំហំឥណទាន (សម្រាប់អតិថិជនម្នាក់) រហូតដល់ ១ លានដុល្លារអាម៉េរិក ដើម្បីពង្រីកការគាំទ្រដល់សហគ្រាសដែលមានទំហំធំជាងមុន ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា។ បន្ថែមលើនេះ ធនាគារ ក៏បាន បង្កើតឱ្យមានគម្រោងហិរញ្ញប្បទានខ្នាតតូច ដែលមិនយកទ្រព្យធានាក្នុងកម្រិតឥណទានត្រឹម ៥០ ពាន់ដុល្លារអាម៉េរិក (សម្រាប់អតិថិជនម្នាក់) ដើម្បីគាំទ្រដល់អាជីវកម្មធុនមីក្រូ ដែលមានចំនួនច្រើនលើសលប់ និងមានការលំបាកក្នុងការទទួលបានហិរញ្ញប្បទានដោយសារមិនមានទ្រព្យធានាដាក់ឱ្យធនាគារ។
- បានដាក់ឱ្យដំណើរការ "កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប" ជាមួយនឹងកញ្ចប់ថវិកាចំនួន ៥០ លានដុល្លារអាម៉េរិក ដែលផ្តល់ជូនដោយផ្ទាល់ពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដើម្បីគាំទ្រវិស័យទេសចរណ៍នៅខេត្តសៀមរាប ក្រោមវិធានការកែទម្រង់មុតស្រួចជាកញ្ចប់របស់រាជរដ្ឋាភិបាល។
- បានបង្កើតសាខាថ្មីបន្ថែមចំនួន ៤ (សាខាប្រភេទ flagship ចំនួន ១ និងសាខាប្រភេទ satellite ចំនួន ៣) នៅខេត្តត្បូងឃ្មុំ (បានដាក់ឱ្យដំណើរការនៅឆ្នាំ២០២៣), ខេត្តបន្ទាយមានជ័យ, ខេត្តកំពង់ស្ពឺ និងខេត្តកំពត (គ្រោងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៤) ដើម្បីពង្រីកវិសាលភាពក្នុងការគាំទ្រដល់បណ្តាខេត្តដែលមានសក្តានុពល។
- បន្តអភិវឌ្ឍដៃគូអាជីវកម្មជាមួយនឹងសមាគមសហគ្រាសធុនតូច និងមធ្យម គោលដៅ ចំនួន ៦ បន្ថែមទៀត ដើម្បីពង្រីកប្រព័ន្ធអេកូឡូស៊ីឱ្យធំទូលាយ សំដៅជម្រុញការផ្តល់ឥណទានឱ្យចំគោលដៅ និងឆាប់រហ័ស។ ជាមួយគ្នានេះ ធនាគារ ក៏បានចុះកិច្ចសហការជាមួយគ្រឹះស្ថានធនាគារ និងក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុធំៗមួយចំនួន ដើម្បីផ្តល់ជម្រើសកាន់តែសម្បូរបែបជូនដល់អតិថិជនក្នុងការសងត្រឡប់ឥណទានមកធនាគារវិញ ប្រកបដោយភាពងាយស្រួល ឆាប់រហ័ស និងចំណាយតិច។
- បានបង្កើនចំនួនបុគ្គលិករហូតដល់ ២២២នាក់ កើនឡើងប្រមាណ ៦៣% ធៀបនឹងឆ្នាំ២០២២ ស្មើនឹង ៨៦នាក់។
- ម្យ៉ាងទៀត ធនាគារក៏បានរួមចំណែកជាមួយភាគីពាក់ព័ន្ធ ទាំងស្ថាប័នសាធារណៈ និងឯកជន ក្នុងសកម្មភាពលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ ជូនដល់សហគ្រាសធុនតូច និងមធ្យម ដើម្បីជំរុញលទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុផ្លូវការ និងសារៈសំខាន់នៃការប្រើប្រាស់ឥណទានដែលទទួលបានឱ្យចំគោលដៅ សម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន ប្រកបដោយនិរន្តភាព និងភាពធន។

ជារួម លទ្ធផលដែលទទួលបានខាងលើ បានបង្ហាញពីការខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តយ៉ាងមុតមាំ របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងការផ្តល់គុណតម្លៃដល់ភាគីពាក់ព័ន្ធរបស់ខ្លួន ហើយយើងនៅតែបន្តអនុវត្តការងារដ៏មានសារៈសំខាន់នេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ជាកិច្ចបញ្ចប់ ខ្ញុំសូមសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ធនាគារជាតិ នៃ កម្ពុជា និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រ នាពេលកន្លងមក។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះ ចំពោះក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង ព្រមទាំងបុគ្គលិកគ្រប់ជាន់ថ្នាក់ របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដែលបានផ្តល់នូវអនុសាសន៍ណែនាំ និងខិតខំបំពេញការងារអស់ពីកម្លាំងកាយចិត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមគ្នាកសាង និងអភិវឌ្ឍធនាគារឱ្យមានការអភិវឌ្ឍជឿនលឿន និងប្រកបដោយចីរភាព។ ជាមួយគ្នានេះ ខ្ញុំសូមអរគុណដល់អតិថិជន និងដៃគូសហការនានា ដែលបានចូលរួមសហការ, គាំទ្រ និងផ្តល់ទំនុកចិត្តលើធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងការលើកកម្ពស់ និងអភិវឌ្ឍវិស័យ អេស អឹម អ៊ី នៅកម្ពុជា ឱ្យកាន់តែមានភាពរីកចម្រើន។

បណ្ឌិត លឹម អូន
អគ្គនាយក និងជាអភិបាល



# សារតាធនាគារ

សហគ្រាសធុនតូច និងមធ្យម (SMEs) គឺជាតួអង្គដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការធានានូវបរិយាប័ន្ន និងកំណើនសេដ្ឋកិច្ច។ នៅប្រទេសកម្ពុជា បានចាត់ទុក សហគ្រាសធុនតូច និងមធ្យម ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដែលបំពេញតម្រូវការមូលដ្ឋាននៃទំនិញ និងសេវាកម្ម ក៏ដូចជាការរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅ បង្កើនផលចំណូលសរុបក្នុងស្រុក និងជំរុញការនាំចេញ។ ក្នុងដំណើរការគ្រប់គ្រង និងអភិវឌ្ឍវិស័យនេះ នៅមានបញ្ហាប្រឈម ដែលក្នុងនោះសហគ្រាសមួយចំនួន ស្ថិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលមានការគ្រប់គ្រងជាលក្ខណៈគ្រួសារ ខ្វះលទ្ធភាពទទួលបានហិរញ្ញប្បទាន និងខ្វះការប្រកួតប្រជែងតាមរយៈការពង្រីកទីផ្សារក្នុងតំបន់ និងអន្តរជាតិ។ ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព រាជរដ្ឋាភិបាលបានសម្រេចបង្កើតធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នេះឡើង។

ធនាគារទទួលបានអាជ្ញាបណ្ណផ្លូវការជាធនាគារពាណិជ្ជពីធនាគារជាតិ នៃ កម្ពុជា (“NBC”) កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ និងស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។ ធនាគារ មានគោលបំណង និងទិសដៅចម្បងក្នុងការផ្តល់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញ ស្របតាមគោលនយោបាយដែលបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា។

វត្តមានរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅក្នុងប្រទេសកម្ពុជានារយៈពេលជិត ៤ឆ្នាំកន្លងមក ត្រូវបានសាធារណជនទទួលស្គាល់ជាធនាគារគោលនយោបាយដែលបាន និងកំពុងផ្តល់សេវាហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ គាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ដោយផ្តោតលើវិស័យអាទិភាពរួមមាន៖

- ការផលិត និងកែច្នៃម្ហូបអាហារ ដែលជាសកម្មភាពបំប្លែងសារធាតុ ផលិតផលកសិកម្ម ឬរុក្ខជាតិ ដោយកែច្នៃទាំងស្រុង ឬកែច្នៃបឋមដោយប្រើម៉ាស៊ីន និងហត្ថកម្ម សម្រាប់មនុស្សបរិភោគ។
- កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ ផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឱ្យកម្មន្តសាលដទៃ, កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍
- ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍ គឺសំដៅលើការបង្កើត និងផ្គត់ផ្គង់សេវាបច្ចេកវិទ្យាព័ត៌មានដែលផ្សារភ្ជាប់ទៅនឹងជំនួញ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- សហគ្រាសស្ថិតនៅក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសដែលអភិវឌ្ឍតំបន់នេះ (SME Cluster)
- សហគ្រាសផលិតទំនិញវេជ្ជសាស្ត្រ និងថ្នាំពេទ្យ សំដៅលើសហគ្រាសទាំងឡាយណា ដែលផលិតឧបករណ៍ ឬគ្រឿងបរិក្ខារ និងថ្នាំពេទ្យសម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល
- សហគ្រាសផ្តល់សេវាកម្ម គាំទ្រដល់សហគ្រាសក្នុងវិស័យអាទិភាព សំដៅដល់អាជីវកម្មដែលចែកចាយទំនិញ និងផ្តល់សេវាកម្មបម្រើដល់វិស័យអាទិភាពនានាកំណត់ដោយរាជរដ្ឋាភិបាល រួមទាំងវិស័យដែលមានសក្តានុពល និងវិស័យដែលរងផលប៉ះពាល់ខ្លាំងដោយវិបត្តិកូវីដ ១៩

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានរួមចំណែកយ៉ាងសំខាន់ជាមួយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទានដល់សហគ្រាសធុនតូច និងមធ្យម។ បច្ចុប្បន្ន ដើម្បីសម្រេចបាននូវទិសដៅនេះ ធនាគារបាននឹងកំពុងបន្តអនុវត្តគម្រោងសហហិរញ្ញប្បទានជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) ក៏ដូចជាការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ដល់សហគ្រាសគោលដៅ និងផ្តោតសំខាន់លើការអភិវឌ្ឍផលិតផលសេវាកម្ម បន្តពង្រីកបណ្តាញចែកចាយ ក៏ដូចជាការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន។



# ចក្ខុវិស័យ

ជាធនាគារជម្រើសដំបូង និងល្អបំផុតសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា ក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុដែលមានតម្លៃសមស្រប, ងាយស្រួលក្នុងការទទួលបានហិរញ្ញប្បទាន, ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការបម្រើសេវាកម្មល្អ។

# បេសកកម្ម

ផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីគាំទ្រសហគ្រាសធុនតូច និងមធ្យម សំដៅជំរុញពិពិធកម្មសេដ្ឋកិច្ច និងការនាំចេញស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។




# គុណតម្លៃ

## ប្រសិទ្ធភាព

យើងខិតខំប្រឹងប្រែងសម្រាប់ប្រតិបត្តិការដ៏ល្អ ដើម្បីប្រាកដថាម្ចាស់ភាគហ៊ុនទាំងអស់ទទួលបានប្រាក់ចំណេញ ភាពរីកចម្រើន និងស្ថេរភាពអាជីវកម្ម។

## អតិថិជន

ដោយសារតែអតិថិជន ជាគោលដៅចម្បងសម្រាប់ការអភិវឌ្ឍអាជីវកម្មរបស់យើង នោះយើងនឹងផ្តល់ជូនសេវាកម្មដ៏ល្អឥតខ្ចោះ។

## ទំនួលខុសត្រូវ

យើងមានទំនួលខុសត្រូវខ្ពស់ និងប្រកបដោយវិជ្ជាជីវៈ ចំពោះអ្នកពាក់ព័ន្ធក្នុងអាជីវកម្ម និងទៅលើតួនាទី ក៏ដូចជាមុខងារដែលយើងបានកំណត់។

## បុគ្គលិក

យើងចាត់ទុកគ្រប់បុគ្គលិកជាទ្រព្យដ៏សំខាន់ ហើយគោរព ផ្តល់តម្លៃ និងផ្តល់ឱកាសឲ្យពួកគាត់ចូលរួមយ៉ាងសកម្មក្នុងដំណើរការអាជីវកម្មរបស់យើង។

## សច្ចៈភាព

លើកកម្ពស់សច្ចៈភាពក្នុងអត្តសញ្ញាណរបស់យើង ដើម្បីធានាឲ្យបាននូវកេរ្តិ៍ឈ្មោះ និងទំនុកចិត្តខ្ពស់ក្នុងអាជីវកម្ម។

# របាយការណ៍សម្រេចបានឆ្នាំ២០២៣

**ចំនួនសហគ្រិនសរុប**
+៣៤០០នាក់

**សមតុល្យឥណទានសរុប**
+២១៩លាន
ដុល្លារអាម៉េរិក

**ទ្រព្យសកម្ម**
៣២២លាន
ដុល្លារអាម៉េរិក

**ចំនួនដៃគូសហការ**
១០

**ចំនួនបុគ្គលិកសរុប**
២២២នាក់

**ចំនួនសាខា**
៧

**ចំនួនសហគ្រិនជាស្ត្រី**




**ហិរញ្ញប្បទានវិស័យអាទិភាព**




**មូលធនធនាគារ** (លានដុល្លារអាម៉េរិក)

| | |
|---|---|
| ឆ្នាំ ២០២៣ | ១៩៨.២ |
| ឆ្នាំ ២០២២ | ១៩៨.៥ |
| ឆ្នាំ ២០២១ | ១៤៨ |
| ឆ្នាំ ២០២០ | ៩៩ |

**ទ្រព្យសកម្មសរុប** (លានដុល្លារអាម៉េរិក)

| | |
|---|---|
| ឆ្នាំ ២០២៣ | ៣២២ |
| ឆ្នាំ ២០២២ | ២៨១ |
| ឆ្នាំ ២០២១ | ១៥០ |
| ឆ្នាំ ២០២០ | ១០០ |



# បណ្តាញសាខា





**ទីស្នាក់ការកណ្តាល**

**អគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
ដីឡូត៍លេខ អេស ផ្លូវអូស៊ីអាយស៊ី
ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ
ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ



**សាខាផ្សារថ្មី**
អគារលេខ ៣០ ផ្លូវប៉ាស្ទ័រ
កែងផ្លូវព្រៃនគរ សង្កាត់ផ្សារថ្មីទី១
ខណ្ឌដូនពេញ រាជធានីភ្នំពេញ



**សាខាខេត្តបាត់ដំបង**
ផ្ទះលេខ ១៦១ និង ១៦២
ផ្លូវជាតិលេខ ៥ ក្រុមទី ៦
ភូមិរំចេក ៥ សង្កាត់រតនៈ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង



**សាខាខេត្តត្បូងឃ្មុំ**
ផ្លូវជាតិលេខ៧ ភូមិសួងកើត
សង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ



**សាខាខេត្តកំពង់ស្ពឺ**
ក្បាលដីលេខ ៤៦៥ ផ្លូវជាតិលេខ៤
ភូមិពាណិជ្ជកម្ម សង្កាត់រការធំ
ក្រុងច្បារមន ខេត្តកំពង់ស្ពឺ



**សាខាខេត្តកំពត**
ក្បាលដីលេខ ៤១៣ ភូមិស្វាយធំ
សង្កាត់ក្រាំងអំពិល ក្រុងកំពត
ខេត្តកំពត



**សាខាខេត្តបន្ទាយមានជ័យ**
ភូមិ ៣ សង្កាត់ព្រះពន្លា
ក្រុងសិរីសោភ័ណ
ខេត្តបន្ទាយមានជ័យ

# វឌ្ឍនភាពនៃធនាគារ




- ទទួលបានអាជ្ញាបណ្ណជាធនាគារពាណិជ្ជ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០
- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី ១ ជាមួយគម្រោងទឹកប្រាក់សរុប ១០០ លានដុល្លារអាមេរិក ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុជាដៃគូចំនួន ៣៣ និងបានបញ្ចប់ជាស្ថាពរនៅខែតុលា ឆ្នាំ២០២០
- ដាក់ដំណើរការគម្រោងហិរញ្ញប្បទានដោយផ្ទាល់រួមមាន៖
  - → គម្រោងហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម កម្ពុជា (CSS)
  - → គម្រោងហិរញ្ញប្បទានសម្រាប់វិស័យឌីជីថល និងទំនើបកម្ម (CDAS)
  - → គម្រោងហិរញ្ញប្បទានសម្រាប់សហគ្រិនស្ត្រីកម្ពុជា (CWES)
  - → និងគម្រោងហិរញ្ញប្បទានស្តារសហគ្រាសធុនតូច និងមធ្យម (CRSS)
- សម្រេចបាន **ទ្រព្យសកម្ម សរុបជាង ១០០ លានដុល្លារអាមេរិក**

- ទទួលបានពានរង្វាន់ជា **“ធនាគារឆ្នើមសម្រាប់ សហគ្រាសធុនតូច និងមធ្យម ប្រចាំឆ្នាំ ២០២១ នៅកម្ពុជា”** ពីស្ថាប័ន Asian Banking & Finance
- ចុះកិច្ចសហប្រតិបត្តិការក្នុងការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ជាមួយសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា, សហគ្រិនខ្មែរ, និងក្រុមហ៊ុន បញ្ជី ហ្វាញថេក ។ល។
- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី២ ជាមួយទំហំទឹកប្រាក់សរុប ២៤០ លានដុល្លារអាម៉េរិកដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន ២៨ និងបានផ្តល់ហិរញ្ញប្បទានជូនដល់សហគ្រាសចំនួន ៩៨១
- សម្រេចបានទ្រព្យសកម្មសរុបជាង **១៥០ លានដុល្លារអាម៉េរិក**

- ដាក់ឲ្យដំណើរការគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ ជាមួយ**ទំហំទឹកប្រាក់សរុប ១៥០ លានដុល្លារអាម៉េរិក**ដោយសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមចំនួន២៤
- បានចូលរួមជាសមាជិកសេវាទូទាត់រហ័ស (Fast Payment) របស់ធនាគារជាតិ នៃ កម្ពុជា ដើម្បីអនុញ្ញាតឲ្យអតិថិជនអាចផ្ទេរប្រាក់ឆ្លងធនាគារបានលឿនទាន់ចិត្ត
- ដាក់ឲ្យដំណើរការគម្រោងហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច ដែលជាគម្រោងហិរញ្ញប្បទានគ្មានទ្រព្យធានា (CMES)
- ដាក់ឲ្យដំណើរការសាខាថ្មីចំនួន ២ បន្ថែមទៀត រួមមានសាខាផ្សារថ្មី និងសាខាខេត្តបាត់ដំបង

- បានអភិវឌ្ឍដៃគូអាជីវកម្មជាមួយនឹងសមាគមសហគ្រាសធុនតូច និងមធ្យម ចំនួន ៥ បន្ថែម ដើម្បីជំរុញការបញ្ចេញឥណទានដោយផ្ទាល់ទៅអតិថិជនគោលដៅ រួមមាន CEO Master Club នៃក្រុមហ៊ុន ឡាយហ្វ៍ អេឌ្យូខេសិន ឯ.ក, សមាគមសហគ្រិនវ័យក្មេងកម្ពុជា, ក្រុមហ៊ុន អាហ្វ្រីប៊ី (ខេមបូឌា), សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា, និងសមាគមអ្នកផលិតចំណីអាហារកម្ពុជា
- សម្រេចបាន**ទ្រព្យសកម្មសរុបជាង ២៨១ លានដុល្លារអាម៉េរិក**

- ដាក់ឲ្យដំណើរការសាខាថ្មីចំនួន ៤ បន្ថែមទៀត សាខាខេត្តត្បូងឃ្មុំ សាខាខេត្តកំពត និងសាខាខេត្តបន្ទាយមានជ័យ និងសាខាខេត្តកំពង់ស្ពឺ
- បានអភិវឌ្ឍដៃគូអាជីវកម្ម ចំនួន ២ បន្ថែម ដើម្បីជំរុញការបញ្ចេញឥណទានដោយផ្ទាល់ ទៅអតិថិជនគោលដៅរួមមាន សមាគមស្វាយចន្ទីកម្ពុជា និងសហព័ន្ធស្វាយចន្ទីកម្ពុជា
- ចុះកិច្ចសហប្រតិបត្តិការជាមួយនឹងក្រុមហ៊ុន ទ្រូម៉ាន់នី (ខេមបូឌា), ធនាគារ អេស៊ីលីដា, និងធនាគារ វឌ្ឍនៈ អាស៊ីចំកាត់ លើសេវាកម្មទូទាត់ការសងត្រឡប់ប្រាក់កម្ចីពីអតិថិជន របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា
- ចុះកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកធនាគារ ទាក់ទងនឹងបច្ចេកទេសវិភាគឥណទានសម្រាប់សហគ្រាសធុនតូច និងមធ្យម
- ដាក់ឲ្យដំណើរការ កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាប (Tourism Financing Scheme for Siem Reap - TFSS) ជាមួយនឹងកញ្ចប់ថវិកាចំនួន ៥០ លានដុល្លារអាម៉េរិក
- សម្រេចបាន**ទ្រព្យសកម្មសរុប ជាង ៣២២ លានដុល្លារអាម៉េរិក**

# ស្ថាប័នដៃគូយុទ្ធសាស្ត្រ

ដើម្បីផ្តល់ការគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមឱ្យបានទូលំទូលាយ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បាន និងកំពុងចាប់ដៃគូសហការជាមួយសមាគម និងស្ថាប័នជាច្រើន ក្នុងគោលបំណងចូលរួមលើកកម្ពស់ និងអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម នៅកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព។



សមាគមសហគ្រិនស្ត្រីកម្ពុជា



សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា



សមាគមសហគ្រិនវ័យក្មេងកម្ពុជា



សហព័ន្ធស្វាយចន្ទីកម្ពុជា



សមាគមស្វាយចន្ទីកម្ពុជា



សមាគមអ្នកផលិតចំណីអាហារកម្ពុជា



សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា



សហគ្រិនខ្មែរ



ក្រុមហ៊ុនបញ្ជីហ្វាញចេក ឯ.ក



ស៊ីអ៊ីអូម៉ាស្ទ័រក្លឹប នៃក្រុមហ៊ុន ឡាយហ្វ៍អេឌ្យូខេសិន ឯ.ក

# លទ្ធផលអាជីវកម្ម

ក្នុងឆ្នាំ២០២៣ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានបញ្ចេញឥណទានសរុបប្រមាណ ៤៦ លានដុល្លារអាម៉េរិក ដល់សហគ្រាសប្រមាណជិត ២០០ សហគ្រាស។ ការបញ្ចេញឥណទាននេះ ត្រូវបានរួមចំណែកពីគម្រោងចំនួនពីរគឺ៖ គម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ (TRCS) និង ហិរញ្ញប្បទានដោយផ្ទាល់ (DL)។ គិតត្រឹមចុងឆ្នាំ២០២៣ សមតុល្យហិរញ្ញវត្ថុរបស់ធនាគារមានចំនួន ២១៩លានដុល្លារអាម៉េរិកដែលរួមមាន ១២៥ លានដុល្លារអាម៉េរិកពីគម្រោងសហហិញ្ញប្បទាន, ៨៦ លានដុល្លារអាម៉េរិកពីគម្រោងហិញ្ញប្បទានដោយផ្ទាល់ និង ៨ លានដុល្លារអាម៉េរិកពីគម្រោងហិរញ្ញប្បទានផ្សេងៗ។ នៅក្នុងឆ្នាំ ២០២៣ សមតុល្យឥណទានមិនដំណើរការ (NPL) មានចំនួនប្រមាណ ៩.៧លានដុល្លារអាម៉េរិក ជាមួយនឹងអត្រា ៤ % នៃសមតុល្យឥណទានសរុប។

**សមតុល្យឥណទានសរុប**
**២១៩**
លានដុល្លារអាម៉េរិក

**គម្រោងសហហិរញ្ញប្បទាន**
**១២៥**
លានដុល្លារអាម៉េរិក

**គម្រោងហិរញ្ញប្បទានដោយផ្ទាល់**
**៨៦**
លានដុល្លារអាម៉េរិក

# គម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើន ក្នុងវិស័យទេសចរណ៍ (TRCS)

គម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍ (TRCS) គឺជាផ្នែកមួយនៃការគាំទ្រសម្រាប់ការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣។ ដើម្បីលើកកម្ពស់ និងពង្រឹងវិស័យទេសចរណ៍ឱ្យងើបឡើងវិញ រាជរដ្ឋាភិបាលបានសម្រេចអនុវត្តគម្រោងនេះ ដើម្បីដោះស្រាយបញ្ហាកង្វះហិរញ្ញប្បទានសម្រាប់អាជីវកម្មទាក់ទងនឹងវិស័យទេសចរណ៍។

គម្រោង TRCS នឹងគាំទ្រ (ក) ដំណើរការស្តារអាជីវកម្មឡើងវិញ (ខ) ការកែលម្អ និងទំនើបកម្ម និង (គ) ការពង្រឹង និងធ្វើពិពិធកម្មសេវាកម្មទេសចរណ៍ ដើម្បីរៀបចំសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិក្នុងវិបត្តិក្រោយកូវីដ-១៩។

គម្រោង TRCS ត្រូវបានផ្តួចផ្តើមបង្កើតឡើងនៅខែកក្កដា ឆ្នាំ២០២២ ជាមួយនឹងថវិកាសរុបចំនួន ១៥០ លានដុល្លារអាម៉េរិក ដែលជាសហហិរញ្ញប្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs)។

គិតត្រឹមចុងខែធ្នូ ឆ្នាំ២០២៣ គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមមានចំនួន២៤ កំពុងចូលរួមក្នុងគម្រោងTRCS។ គម្រោងនេះ បានផ្តល់ហិរញ្ញប្បទានដល់សហគ្រាសប្រមាណ ៣៥០ រួមមានអាជីវកម្មសណ្ឋាគារ ៦០, អាជីវកម្មផ្ទះសំណាក់ ១០២, អាជីវកម្មភោជនីយដ្ឋាន ១៣៣, អាជីវកម្មគាំទ្រដល់វិស័យទេសចរណ៍ ៥៥ ជាមួយនឹងទំហំហិរញ្ញប្បទានដែលបានបញ្ចេញសរុបប្រមាណ ៥៤ លានដុល្លារអាម៉េរិក។

**វឌ្ឍនភាពគម្រោងសហហិរញ្ញប្បទានស្តារ និងជំរុញកំណើនក្នុងវិស័យទេសចរណ៍**

- គម្រោងថវិកាសរុប: **150** លានដុល្លារអាម៉េរិក
- ឥណទានបានបញ្ចេញ: **54** លានដុល្លារអាម៉េរិក
- សហគ្រាសដែលទទួលបានហិរញ្ញប្បទាន: **350**
- 29% អាជីវកម្មសណ្ឋាគារ
- 28% អាជីវកម្មផ្ទះសំណាក់
- 38% អាជីវកម្មភោជនីយដ្ឋាន
- 16% អាជីវកម្មគាំទ្រវិស័យទេសចរណ៍
- 41% សហគ្រិនស្ត្រី



# គម្រោងហិរញ្ញប្បទានដោយផ្ទាល់

គម្រោងហិញ្ញប្បទានដោយផ្ទាល់ មានកំណើនប្រមាណជា ៦២% ដែលកើនពី ៥៣ លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២២ ដល់ ៨៦ លានដុល្លារអាម៉េរិកនៅចុងឆ្នាំ២០២៣។ ប្រមាណជា ៧៦% នៃសមតុល្យហិញ្ញប្បទានសរុប បានគាំទ្រដល់វិស័យអាទិភាព និង៥០% ត្រូវបានបញ្ចេញទៅឱ្យសហគ្រាសដែលស្ថិតក្នុងវិស័យកម្មន្តសាល កែច្នៃម្ហូបអាហារ និងកសិផល។ លទ្ធផលខាងលើទទួលបានពីការដាក់ឱ្យដំណើរការកម្មវិធីហិរញ្ញប្បទានដោយផ្ទាល់ ចំនួន ៤គម្រោងរួមមាន៖ គម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច និងមធ្យម (CSS), គម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី (CWES), គម្រោងហិរញ្ញប្បទានវិស័យឌីជីថល និងទំនើបកម្ម (CDAS) និងគម្រោងហិរញ្ញប្បទានសហគ្រាសធុនតូច (CMES)។












## កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍ នៅខេត្តសៀមរាប (TFSS)

ដើម្បីជំរុញវិស័យទេសចរណ៍នៅខេត្តសៀមរាបឱ្យមានសម្ទុះងើបឡើងវិញ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដូចបានកំណត់ត្រង់ចំណុច ៦.២.៤ ក្នុងសេចក្តីជូនដំណឹង ស្តីពីលទ្ធផលនៃវេទិកាราជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ ដោយប្រគល់ភារកិច្ចជូនធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា រៀបចំជាកម្មវិធីផ្តល់កម្ចីដោយផ្ទាល់ ជាមួយនឹងទឹកប្រាក់បឋមចំនួន ៥០ លានដុល្លារអាម៉េរិកដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប។ កម្មវិធីនេះ ផ្តល់ជូននូវអត្រាការប្រាក់សមរម្យ និងលក្ខខណ្ឌអនុគ្រោះផ្សេងៗទៀត ដែលអនុញ្ញាតឱ្យប្រតិបត្តិករទេសចរណ៍អាចទទួលបាននូវហិរញ្ញប្បទាន ដើម្បីបើកដំណើរការអាជីវកម្មឡើងវិញ, ធ្វើការកែលម្អ និងធ្វើទំនើបកម្មសេវាទេសចរណ៍ ព្រមទាំងការពង្រីកខ្លួន និងធ្វើពិពិធកម្មសេវាទេសចរណ៍ សំដៅទាក់ទាញ និងទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

**គម្រោង TFSS ផ្តល់ការគាំទ្រដល់សហគ្រាស ឬអាជីវកម្មគោលដៅដែលបម្រើសេវាកម្មដោយផ្ទាល់ដល់ទេសចរជាតិ និងអន្តរជាតិដូចជា៖**

- **សណ្ឋាគារ ផ្ទះសំណាក់ រមណីយដ្ឋាន**
- **ភោជនីយដ្ឋាន**
- **អាជីវកម្មផលិត និង/ឬ លក់វត្ថុអនុស្សាវរីយ៍**
- ក្រុមហ៊ុនភ្នាក់ងារទេសចរណ៍
- សេវាកម្មដឹកជញ្ជូនភ្ញៀវទេសចរណ៍
- **អាជីវកម្មអភិវឌ្ឍផលិតផលទេសចរណ៍**
- **ការផ្គត់ផ្គង់ផលិតផល និង/ឬសេវាកម្ម ដែលគាំទ្រឧស្សាហកម្មទេសចរណ៍**

### លក្ខណៈពិសេសនៃគម្រោង

| **បរិយាយ** | **លក្ខណៈពិសេស** |
|---|---|
| ប្រភេទឥណទាន | ឥណទានមានកាលកំណត់ |
| ទំហំហិរញ្ញប្បទាន | ចាប់ពី ២០,០០០ ដល់ ៦០០,០០០ ដុល្លារអាម៉េរិកឬ សមមូលប្រាក់រៀល |
| គោលបំណងប្រើប្រាស់ | សម្រាប់ទុនវិនិយោគ ឬទុនបង្វិល |
| រយៈពេលហិរញ្ញប្បទាន | រហូតដល់ ៨ឆ្នាំ |
| រូបិយប័ណ្ណ | ប្រាក់រៀល ឬ ប្រាក់ដុល្លារអាម៉េរិក |
| អត្រាការប្រាក់ | ៦.៥០% ក្នុងមួយឆ្នាំ |
| សោហ៊ុយរៀបចំ ឥណទាន | មិនមាន |
| រយៈពេលអនុគ្រោះបង់ប្រាក់ដើម | រហូតដល់ ២៤ ខែ |
| ការសងត្រឡប់មុនកាលកំណត់ | មិនមានពិន័យ |

ដោយហេតុថាប្រតិបត្តិករទេសចរណ៍មានផលប៉ះពាល់ជាអវិជ្ជមានច្រើនពីវិបត្តិសកល ដូច្នេះធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានកែសម្រួលលក្ខខណ្ឌឥណទានមួយចំនួនដូចខាងក្រោម:

- ទទួលស្គាល់ប្រាក់ចំណូលដែលបានមកពីការព្យាករណ៍ ដើម្បីគណនាលទ្ធភាពទូទាត់បំណុល
- ទម្លាក់អនុបាតលទ្ធភាពទូទាត់បំណុលពី ១.៥ ទៅ ១.២
- ទទួលស្គាល់ឥណទានដែលស្ថិតនៅចំណាត់ថ្នាក់ឃ្លាំមើល (ប៉ុន្តែរយៈពេលសងយឺតមិនឱ្យលើសពី៦០ថ្ងៃ)



# កិច្ចប្រជុំប្រចាំឆ្នាំ

សៀមរាប, នាព្រឹកថ្ងៃសៅរ៍ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤



ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០២៤ (Annual General Meeting 2024) ក្រោមប្រធានបទ «Grow Strong, Grow Right» នៅសណ្ឋាគារសុខាសៀមរាប ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ព្រមទាំងមានការចូលរួមពីសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល, អគ្គនាយក, ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃធនាគារ ប្រមាណ២១០នាក់។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យមើលវឌ្ឍនភាព និងសមិទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០២៣ របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ព្រមទាំងផ្សព្វផ្សាយនូវផែនការ និងយុទ្ធសាស្ត្រអាជីវកម្មសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៤ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលធនាគារ។ កិច្ចប្រជុំនេះ នឹងជួយតម្រង់ទិសដៅការងាររបស់បុគ្គលិក ដើម្បីធានាបាននូវការអនុវត្តផែនការប្រកបដោយប្រសិទ្ធភាព។







# កម្មវិធីទទួលស្គាល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ

សៀមរាប, រាត្រីថ្ងៃសៅរ៍ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤








ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានរៀបចំកម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ ក្រោមប្រធានបទ «Sparkling Night» នៅសណ្ឋាគារសុខាសៀមរាប ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ព្រមទាំងមានការចូលរួមពីសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល, អគ្គនាយក, ថ្នាក់ដឹកនាំ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃធនាគារ ប្រមាណ២១០នាក់។

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា តែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខុមាលភាពបុគ្គលិក ក៏ដូចជាលើកកម្ពស់ការអភិវឌ្ឍសមត្ថភាព ដោយផ្តល់ជូននូវការទទួលស្គាល់សមិទ្ធផល តាមរយៈការផ្តល់រង្វាន់លើកទឹកចិត្តដល់បុគ្គលិកឆ្នើមប្រចាំឆ្នាំ ចំពោះកិច្ចខិតខំប្រឹងប្រែង បំពេញការងារប្រកបដោយទំនួលខុសត្រូវ និងវិជ្ជាជីវៈ។ “Sparkling Night” បានក្លាយជារាត្រីដ៏វិសេសវិសាលមួយ ដែលផ្តល់ជូននូវកម្មវិធីពិសេសៗជាច្រើនរួមមាន៖ ការប្រកាសបុគ្គលិកឆ្នើមប្រចាំឆ្នាំ, ការសម្តែងទេពកោសល្យរបស់បុគ្គលិក, ការចាប់រង្វាន់ផ្សងសំណាង ក៏ដូចជាការបរិភោគអាហារ និងការរាំកំសាន្ត។

# ព្រឹត្តិការណ៍ផ្សេងៗ

## ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ សាខាខេត្តបាត់ដំបង

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានបើកសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការសាខាខេត្ត គឺសាខាខេត្តបាត់ដំបង ក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារ, ឯកឧត្តម សុខ លូ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង, ឯកឧត្តមរដ្ឋលេខាធិការ, ឯកឧត្តមអនុរដ្ឋលេខាធិការ, ឯកឧត្តមលោកជំទាវ, សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល និងមានការចូលរួមជាកិត្តិយសពីអាជ្ញាធរពាក់ព័ន្ធមួយចំនួនរបស់ខេត្តបាត់ដំបង, ពោធិ៍សាត់,បន្ទាយមានជ័យ, និងប៉ៃលិន ព្រមទាំងម្ចាស់សហគ្រាសធុនតូច និងមធ្យម ប្រមាណជាង១៤០ នាក់ផងដែរ។












## ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ សាខាខេត្តត្បូងឃ្មុំ

ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៣

សាខាខេត្តត្បូងឃ្មុំ ដែលជាសាខាខេត្ត ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ក្រោមអធិបតីភាពរបស់ឯកឧត្តម សុន សេងហួត រដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ អភិបាល នៃគណៈអភិបាលខេត្តត្បូងឃ្មុំ, ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលរបស់ធនាគារ ភ្ញៀវកិត្តិយសជាម្ចាស់សហគ្រាសធុនតូច និងមធ្យម និងឥស្សរជនកិត្តិយសជាច្រើនរូបទៀតយ៉ាងអធិកអធម ប្រមាណ១៥០នាក់។



## ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា បានរៀបចំសិក្ខាសាលា និងសន្និសីទសារព័ត៌មានផ្សព្វផ្សាយ «កម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប»

ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

សិក្ខាសាលានេះ ត្រូវបានប្រារព្ធឡើងក្រោមវត្តមានរបស់បណ្ឌិត លឹម អូន អគ្គនាយក នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា, ឯកឧត្តម នាក់ ណេរ៉ុន អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប, ឯកឧត្តម ឈុន មករា ប្រធាននាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារ ដឹកជញ្ជូន និងមគ្គុទ្ទេសក៍ទេសចរណ៍, លោកជំទាវ ឆាយ ស៊ីវលីន ប្រធានសមាគមទេសចរណ៍កម្ពុជា និងមានការអញ្ជើញចូលរួមពីម្ចាស់សហគ្រាស អាជីវកម្ម និងសេវាកម្មដែលគាំទ្រវិស័យទេសចរណ៍ ប្រមាណជា១៦០នាក់ មកពីទូទាំងខេត្តសៀមរាប។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្សព្វផ្សាយពីកម្មវិធីកម្ចីដោយផ្ទាល់ ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប ក៏ដូចជាជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទាន ដែលមានលក្ខខណ្ឌអនុគ្រោះ ដើម្បីជំរុញការធ្វើប្រតិបត្តិការអាជីវកម្មឡើងវិញ, ការកែលម្អ និងធ្វើទំនើបកម្ម, ការពង្រីកខ្លួនបន្ថែម និងធ្វើពិពិធកម្មនៃសេវាទេសចរណ៍ សំដៅទាក់ទាញ និងទទួលភ្ញៀវទេសចរជាតិ និងអន្តរជាតិ។









ថ្ងៃទី៣១ មករា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភកម្មវិធី និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «ត្រៀមខ្លួនដើម្បីទទួលបានការវិនិយោគ ជុំទីមួយ ឆ្នាំ២០២២» ដែលត្រូវបានរៀបចំឡើងដោយសហគ្រិនខ្មែរ




ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ «សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣» នៃសម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា (FASMEC)



ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងវេទិកាជួបជុំសហគ្រិន ក្រោមប្រធានបទ «ជីវិតជាសហគ្រិន»



ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានសហគ្រិនស្ត្រី ក្នុងសិក្ខាសាលាស្តីពី «ពង្រីកកាលានុវត្តភាពសហគ្រិនស្ត្រី ក្នុងបរិបទសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល» ត្រូវបានរៀបចំឡើងដោយ ក្រសួងកិច្ចការនារី



ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២៣

កិច្ចទទួលស្វាគមន៍ គណៈប្រតិភូក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មនៃប្រទេសឡាវ ក្នុងដំណើរទស្សនកិច្ចមកកម្ពុជា



ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣

ការចូលរួមក្នុង «ពិធីសំណេះសំណាល និងពិសារអាហារសាមគ្គីជាមួយសហគ្រិនវ័យក្មេង» ដែលត្រូវបានរៀបចំឡើងដោយ សហគ្រិនវ័យក្មេង





ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣

ការរៀបចំសិក្ខាសាលាស្តីពី «លទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងការអភិវឌ្ឍទៅរកទីផ្សារពិភពលោក»





ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «ពន្លឿនអាជីវកម្មថ្នាលឌីជីថល រដូវកាលទី២» ដែលត្រូវបានរៀបចំឡើងដោយ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"



ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញ ក្នុងវេទិកាពិភាក្សាស្តីពី «ការផ្លាស់ប្តូរឌីជីថលនៅក្នុងវិស័យឧស្សាហកម្មក្នុងបរិបទនៃឧស្សាហកម្ម ៤.០» ដែលត្រូវបានរៀបចំឡើងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍



ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ ព្រឹត្តិការណ៍ «ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា-អន្តរជាតិ លើកទី ១ ប្រចាំឆ្នាំ២០២៣» ដែលត្រូវបានរៀបចំឡើងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍



ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ «ពិព័រណ៍ផលិតផលសហគ្រិនស្ត្រីកម្ពុជា ឆ្នាំ២០២៣» ដែលត្រូវបានរៀបចំឡើងដោយ សមាគមសហគ្រិនស្ត្រីកម្ពុជា





ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទានប្រកបដោយលក្ខខណ្ឌអនុគ្រោះ ក្នុងកម្មវិធី «លទ្ធភាពទទួលបានហិរញ្ញប្បទាន» ដែលត្រូវបានរៀបចំឡើងដោយ សមាគមសហគ្រិនវ័យក្មេងកម្ពុជា




ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣

កិច្ចទទួលស្វាគមន៍គណៈប្រតិភូ ពីធនាគារកណ្តាល នៃប្រទេសឡាវ, ថ្នាក់ដឹកនាំនៃគម្រោង Lao Access to Finance Fund (LAFF), គ្រឹះស្ថានហិរញ្ញវត្ថុពីប្រទេសឡាវ និងតំណាងសមាគមមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្នុងកម្មវិធី «ទស្សនកិច្ចសិក្សាដើម្បីស្វែងយល់អំពីគម្រោងហិរញ្ញប្បទានរបស់ធនាគារ»



ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ សិក្ខាសាលាសហគ្រិនភាពស្តីពី «វិធីសាស្ត្រដើម្បីរស់រាន សម្រាប់សហគ្រិនសម័យបដិវត្តន៍ឧស្សាហកម្ម ៤.0» ដែលត្រូវបានរៀបចំឡើងដោយ វិទ្យាស្ថានខេមអេដ




ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ ពិព័រណ៍ការងារ «Paragon.U's Career Fair» ដែលត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន



ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ «កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល រដូវកាលទី ២ វគ្គផ្តាច់ព្រ័ត្រ» ដែលត្រូវបានរៀបចំឡើងដោយ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"





ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣

ការរៀបចំសិក្ខាសាលាស្តីពី «ការវិភាគ និងការគ្រប់គ្រងឥណទាន» ត្រូវបានសហការរៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ (PRI) នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន (JFC-Micro)។





ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ «ទិវាសហគ្រាសធុនមីក្រូ តូច និងមធ្យម សកល ២០២៣» ដែលត្រូវបានរៀបចំឡើងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍




ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣

ការរៀបចំសិក្ខាសាលា តាមប្រព័ន្ធអនឡាញស្តីពី «លទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងការអភិវឌ្ឍទៅរកទីផ្សារពិភពលោក»



ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣

ការរៀបចំសិក្ខាសាលាស្តីពី «លទ្ធភាពទទួលបានហិរញ្ញប្បទាន និងការត្រៀមខ្លួនដើម្បីទទួលបានហិរញ្ញប្បទានពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា»



ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ ការបើកកម្មវិធីដែកអំពីធុរកិច្ចលើកទី៧ ស្តីពី «អាជីវកម្មលក្ខណៈគ្រួសារ និងបទប្បញ្ញត្តិពាក់ព័ន្ធ» ដែលត្រូវបានរៀបចំឡើងដោយសាកលវិទ្យាល័យជាតិគ្រប់គ្រង



ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣

ការចូលរួមជាវាគ្មិនកិត្តិយស ក្នុងសិក្ខាសាលាស្តីពី «ការគាំទ្រសហគ្រាសធុនតូច និងមធ្យម លើការយល់ដឹងផ្នែកច្បាប់ និងហិរញ្ញវត្ថុ សម្រាប់កំណើនប្រកបដោយចីរភាព» ដែលត្រូវបានរៀបចំឡើងដោយ មជ្ឈមណ្ឌលស្រាវជ្រាវ និងសិក្សាច្បាប់កម្រិតខ្ពស់ នៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី

## ព្រឹត្តិការណ៍




ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៣

កិច្ចទទួលស្វាគមន៍ និងកិច្ចពិភាក្សា ស្ដីអំពីហិរញ្ញប្បទាន ដែលពាក់ព័ន្ធ ដើម្បីគាំទ្រដល់គម្រោងផែនការអភិវឌ្ឍន៍ វិស័យកសិកម្មនៅកម្ពុជា



ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

កិច្ចប្រជុំ TOWN HALL លើកទី១



ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញស្ដីពី «លទ្ធភាពទទួលបានហិរញ្ញប្បទាន ក្រោមប្រធានបទ៖ តើម្ចាស់សហគ្រាសធុនតូច និងមធ្យម គួរត្រៀមអ្វីខ្លះ ដើម្បីទទួលបានហិរញ្ញប្បទាន ពីធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា» ដែលត្រូវបានរៀបចំឡើងដោយ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍



ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញ ក្នុងកិច្ចជំនួបលើកទី១ នៃកម្មវិធី «ហិរញ្ញវត្ថុសម្រាប់អាជីវកម្ម» ដែលត្រូវបានរៀបចំឡើងដោយ សហគ្រិនខ្មែរ



ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញ ក្នុងកម្មវិធី «ជំនួបលើកទី៣ រវាងសហគ្រាសធុនមីក្រូ តូច និងមធ្យម ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ» ដែលត្រូវបានរៀបចំឡើង ដោយ សមាគមសហគ្រិនវ័យក្មេងកម្ពុជា, សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា



ព្រឹត្តិការណ៍



ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភ និងការធ្វើបទបង្ហាញ ក្នុងកម្មវិធីការរៀបចំផែនការជីវិតយុវជន ក្រោមប្រធានបទ «បាននិទ្ទេសហើយ គួរធ្វើអ្វីទៀត» ដែលត្រូវបានរៀបចំឡើងដោយ មាគ៌ា




ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភព្រឹត្តិការណ៍ជិះកង់ ក្រោមប្រធានបទ «ជិះកង់ដើម្បីផ្សព្វផ្សាយអំពីនិរន្តរភាពនៃវិស័យធនាគារ និងការលើកកម្ពស់ប្រាក់រៀល» ដែលត្រូវបានរៀបចំឡើងដោយ សមាគមធនាគារនៅកម្ពុជា



ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

ការចូលរួម និងការធ្វើបទបង្ហាញពីគម្រោងហិរញ្ញប្បទាន ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្ដីពី «គោលនយោបាយជាតិ ស្ដីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧» ដែលត្រូវបានរៀបចំឡើងដោយ ក្រសួងពាណិជ្ជកម្ម



ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

ការចូលរួមឧបត្ថម្ភព្រឹត្តិការណ៍ «ពិព័រណ៍ការងារ និងផលិតភាពជាតិឆ្នាំ២០២៣» ដែលត្រូវបានរៀបចំឡើងដោយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣

ការរៀបចំសិក្ខាសាលា បណ្តុះបណ្តាលស្តីអំពី «សហគ្រាសបង្កើតថ្មី» ត្រូវបានសហការរៀបចំឡើងដោយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ (PRI) នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន (JFC-Micro)។




ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

កិច្ចប្រជុំស្តីពីការកំណត់គោលដៅយុទ្ធសាស្ត្រ និងផែនការអាជីវកម្មរបស់ធនាគារ សម្រាប់ឆ្នាំ២០២៤-២០២៦

# ទំនួលខុសត្រូវសង្គម



ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣

ការចូលរួមបរិច្ចាគឈាម ក្នុងយុទ្ធនាការបរិច្ចាគឈាមសង្គ្រោះជីវិត នាថ្ងៃទិវាអន្តរជាតិនារី ដែលត្រូវបានរៀបចំឡើងដោយ សមាគមធនាគារនៅកម្ពុជា



ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣

ការចូលរួមបរិច្ចាគថវិកា និងគាំទ្រមូលនិធិគន្ធបុប្ផាកម្ពុជា




ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣

ការចូលរួមបរិច្ចាគឈាម ក្នុងកម្មវិធីសប្បុរសធម៌ផ្តល់ឈាម សង្គ្រោះជីវិត ដែលត្រូវបានរៀបចំធ្វើឡើងដោយ មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច



# អនុស្សរណៈនៃការយោគយល់



ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងសមាគមស្វាយចន្ទី កម្ពុជា ស្តីពីការជំរុញលទ្ធភាពទទួលបានហិរញ្ញប្បទានសម្រាប់សហគ្រាសធុនតូច និងមធ្យម ក្នុងអាជីវកម្មកែច្នៃគ្រាប់ស្វាយចន្ទី



ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣

ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា និងសហព័ន្ធស្វាយចន្ទីកម្ពុជា ក្នុងគោលបំណងលើកស្ទួយវិស័យកែច្នៃស្វាយចន្ទី នៅកម្ពុជា ក៏ដូចជា ជំរុញការនាំចេញគ្រាប់ស្វាយចន្ទីកែច្នៃទៅកាន់ទីផ្សារអន្តរជាតិ។



ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣

កិច្ចសហប្រតិបត្តិការ ជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ នៃក្រសួងហិរញ្ញវត្ថុជប៉ុន និងអង្គភាពអាជីវកម្មខ្នាតតូច នៃសាជីវកម្មហិរញ្ញវត្ថុជប៉ុន ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកធនាគារ ទាក់ទងនឹងបច្ចេកទេសវិភាគឥណទាន សម្រាប់សហគ្រាសធុនតូច និងមធ្យម

# រចនាសម្ព័ន្ធធនាគារ







## ក្រុមប្រឹក្សាភិបាល



## ឯកឧត្តមបណ្ឌិត ផាន់ ផល្លា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាភិបាល

ឯកឧត្តមបណ្ឌិត ផាន់ ផល្លា បានចាប់ផ្តើមបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងឆ្នាំ២០០៤។ ឯកឧត្តមបណ្ឌិត បានចូលរួមយ៉ាងសកម្ម ក្នុងការងារអភិវឌ្ឍគម្រោងប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMIS), កម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (PFMRP), ការរៀបចំយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រតាមវិស័យ, យុទ្ធសាស្ត្រគៀរគរចំណូល, ការគ្រប់គ្រង និងវិភាគម៉ាក្រូសេដ្ឋកិច្ច, ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣។ល។

បច្ចុប្បន្ន ឯកឧត្តមបណ្ឌិត មានតួនាទីជាសមាជិក នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, សមាជិកក្រុមប្រឹក្សាភិបាល នៃកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ, អគ្គលេខាធិការនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានក្រុមប្រឹក្សាភិបាល របស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។ ឯកឧត្តមបណ្ឌិត បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកសេដ្ឋកិច្ច ពីប្រទេសអូស្ត្រាលី។





## ឯកឧត្តម សុន សេងហួត

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម សុន សេងហួត ជារដ្ឋលេខាធិការ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ធ្លាប់មានបទពិសោធន៍ជាច្រើនរួមមាន មុនឆ្នាំ២០១៣ ឯកឧត្តមជាប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ។ ក្នុងឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤ ឯកឧត្តមជាអគ្គនាយករងនៃនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ចាប់ពីឆ្នាំ២០១៤ រហូតមកដល់ពេលបច្ចុប្បន្ន ឯកឧត្តមជារដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ទទួលបន្ទុក អគ្គនាយកដ្ឋានសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម និងនាយកដ្ឋានកិច្ចការ ឧស្សាហកម្ម នៃអគ្គនាយកដ្ឋានឧស្សាហកម្ម។

ឯកឧត្តម បានបញ្ចប់ការសិក្សាលើជំនាញគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសវៀតណាម និងជំនាញគ្រប់គ្រងភូមិមួយផលិតផលមួយ ពីប្រទេសជប៉ុន។ ឯកឧត្តម បានឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម ពីប្រទេសសិង្ហបុរី និងកូរ៉េ។ ឯកឧត្តម ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលសាធារណៈ ពីសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។



## ឯកឧត្តម ទេព ភិយ្យោវិទ្ធ

សមាជិកក្រុមប្រឹក្សាភិបាល

ឯកឧត្តម ទេព ភិយ្យោវិទ្ធ បច្ចុប្បន្នកាន់តំណែងជាអនុរដ្ឋលេខាធិការនៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កន្លងមក ឯកឧត្តម ធ្លាប់ជាអគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ។ ឯកឧត្តម ក៏ធ្លាប់បម្រើការងារជាទីប្រឹក្សានៃនាយកប្រតិបត្តិធនាគារពិភពលោករបស់ World Bank Group ដែលមានទីតាំងនៅទីក្រុង Washington D.C. សហរដ្ឋអាម៉េរិក។ ឯកឧត្តម បានចូលបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ១៩៩៩ ក្នុងតំណែងជាមន្ត្រីផ្នែកថវិកា ហើយបន្តពីពេលនោះ ឯកឧត្តម ក៏បានកាន់តំណែងជាច្រើនផងដែរនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរួមមាន ប្រធានការិយាល័យម៉ាក្រូសេដ្ឋកិច្ច, អនុប្រធាននាយកដ្ឋាន, និងប្រធាននាយកដ្ឋាន គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។

ឯកឧត្តម បានបញ្ចប់ការសិក្សាផ្នែកគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈពី University of Birmingham នៃចក្រភពអង់គ្លេស និងផ្នែកសេដ្ឋកិច្ចពី Kharkov State University of Economics នៃប្រទេសអ៊ុយក្រែន។ បច្ចុប្បន្ន ឯកឧត្តម ទទួលខុសត្រូវលើការតាមដានការអភិវឌ្ឍ ម៉ាក្រូសេដ្ឋកិច្ច, ការត្រួតពិនិត្យគោលនយោបាយ និងវិភាគបញ្ហាអភិវឌ្ឍ។ ឯកឧត្តម ក៏ទទួលបន្ទុកផ្នែកក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចសារពើពន្ធរយៈពេលមធ្យម និងផ្តល់យោបល់ផ្នែកសេដ្ឋកិច្ច, ហិរញ្ញវត្ថុ និងការគ្រប់គ្រងវិស័យសាធារណៈផងដែរ។



**លោកស្រី ឈន ដាលិះ**
សមាជិកាក្រុមប្រឹក្សាភិបាលឯករាជ្យ



**ឯកឧត្តម ចាន់ សុខទី**
សមាជិកក្រុមប្រឹក្សាភិបាល

លោកស្រី ឈន ដាលិះ ត្រូវបានតែងតាំងជាសមាជិកាក្រុមប្រឹក្សាភិបាល ឯករាជ្យ នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅឆ្នាំ២០២០។ លោកស្រី មានបទពិសោធន៍ជាង ២០ឆ្នាំ ក្នុងអាជីពជាគណនេយ្យករ និងដឹកនាំអាជីវកម្មធុនតូច និងមធ្យម ក្នុងវិស័យផ្សេងៗ រួមមាន វិស័យកសិឧស្សាហកម្ម និងវិស័យទឹកស្អាត។

លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម នៅ Asian Institute of Technology ប្រទេសថៃ និងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុអន្តរជាតិនៅ Ceram Sophia Antipolis ប្រទេសបារាំង នៅឆ្នាំ២០០២។

ឯកឧត្តម ចាន់ សុខទី បច្ចុប្បន្នកាន់តំណែងជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានអគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ នៃក្រសួងពាណិជ្ជកម្ម ឋានៈស្មើរដ្ឋលេខាធិការ និងជាសមាជិកក្រុមប្រឹក្សាភិបាល ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។

ឯកឧត្តម ជាសមាជិកគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា (ប.ស.ប.ក) ដែលទទួលខុសត្រូវសម្រាប់គ្រប់គ្រងប្រព័ន្ធស្បៀង បម្រុងរបស់រាជរដ្ឋាភិបាល។

ឯកឧត្តម ធ្លាប់ធ្វើជាអគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស នៃក្រសួងពាណិជ្ជកម្មផងដែរ ឯកឧត្តមបានធ្វើជានាយកគម្រោងជំរុញទីផ្សារសម្រាប់ កសិកម្មខ្នាតតូច (AIMS)។

ឯកឧត្តម បានចូលបម្រើការងារនៅក្រសួងពាណិជ្ជកម្ម នៅក្នុងឆ្នាំ១៩៩៧ ក្នុងតំណែងជា មន្ត្រីការិយាល័យមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋានកាំកុងត្រូល ហើយបន្តពីនោះមក ឯកឧត្តមក៏បានកាន់តំណែងជាច្រើនផងដែរនៅក្នុងក្រសួងពាណិជ្ជកម្ម រួមមាន៖ ជាអនុប្រធានសាខាផែស្វួតចុងទី, ជាអនុប្រធាននាយកដ្ឋាន និងជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ អគ្គនាយកស្ដីទីនៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

ឯកឧត្តម បានបញ្ចប់ការសិក្សាផ្នែកវិស្វករគីមីចំណីអាហារនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអនុបណ្ឌិតផ្នែកកសិកម្មនៅសាកលវិទ្យាល័យតូក្យូប្រទេសជប៉ុន។





**ឯកឧត្តមបណ្ឌិត គង់ ម៉ារី**
មន្ត្រីត្រួតពិនិត្យរដ្ឋ



**បណ្ឌិត លឹម អូន**
អគ្គនាយក និងជាអភិបាល

ឯកឧត្តមបណ្ឌិត គង់ ម៉ារី មានមុខតំណែងជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ជាប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ", ជាប្រធានមូលនិធិអភិវឌ្ឍន៍សហគ្រិន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល។ នៅក្នុងក្របខណ្ឌការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមទទួលភារកិច្ចក្នុងការជួយជំរុញការងារកែទម្រង់តាមរយៈការប្រើប្រាស់ បច្ចេកវិទ្យាឌីជីថល, ការកសាងធុរកិច្ចថ្មី និងសហគ្រិនភាព, ការជំរុញសហគ្រាសធុនតូច និងមធ្យមឆ្ពោះទៅរកការចាប់យកឌីជីថល និងការលើកកម្ពស់នវានុវត្តន៍ក្នុងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ឯកឧត្តមបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតពីសាកលវិទ្យាល័យវ៉ាសេដាប្រទេសជប៉ុនផ្នែកបច្ចេកវិទ្យាព័ត៌មាន។



**លោក នៀវ សុគន្ធ**
នាយកប្រតិបត្តិ ប្រតិបត្តិការ និងជាអភិបាល




# គណៈគ្រប់គ្រងជាន់ខ្ពស់





## បណ្ឌិត លឹម អូន

អគ្គនាយក

បណ្ឌិត លឹម អូន មានបទពិសោធន៍ការងារជាង ២៥ឆ្នាំ ក្នុងវិស័យធនាគារ និងក្រុមហ៊ុនសវនកម្មអន្តរជាតិ។ មុនចាប់ផ្តើមបម្រើការងារនៅ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០២១ លោក ធ្លាប់បម្រើការងារជាសវនករជាន់ខ្ពស់ នៅក្រុមហ៊ុនខេភីអឹមជី ក្នុងប្រទេសកម្ពុជា និង ម៉ាឡេស៊ី, ជាអគ្គនាយករង នៅធនាគារវឌ្ឍនៈ និងចុង ក្រោយជា អគ្គនាយកនៅធនាគារស្ថាបនា។

លោកត្រូវបានតែងតាំងជាអគ្គនាយក និងជាសមាជិកក្រុម ប្រឹក្សាភិបាល នៃ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ដោយរាជរដ្ឋាភិបាលកម្ពុជា នាខែសីហា ឆ្នាំ២០២១។

លោកទទួលបានសញ្ញាបត្រថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច ពីប្រទេសបារាំង។



## លោក នៀវ សុគន្ធ
នាយកប្រតិបត្តិ ប្រតិបត្តិការ

លោក នៀវ សុគន្ធ មានបទពិសោធន៍ជាង២០ ឆ្នាំនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកបានចាប់ផ្ដើមបម្រើការងារនៅក្នុងវិស័យហិរញ្ញវត្ថុនេះ ចាប់ពីមុខតំណែងមន្ត្រីឥណទានរហូតដល់ថ្នាក់គ្រប់គ្រង។ ជំនាញ និងបទពិសោធន៍របស់លោក រួមមាន៖ ការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រ, សេវាកម្មធនាគារ, ធនាគារសហគ្រាសធុនតូច និងមធ្យម, ការគ្រប់គ្រងសាខា, ការគ្រប់គ្រងផ្នែកប្រតិបត្តិការ និងសេវាកម្មអតិថិជន។ នាពេលបច្ចុប្បន្ននេះ លោកមានដំណែងជានាយកប្រតិបត្តិ ប្រតិបត្តិការ នៃធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងតួនាទីទទួលខុសត្រូវលើកិច្ចការអភិវឌ្ឍអាជីវកម្ម, ប្រតិបត្តិការធនាគារ និងផ្នែកទីផ្សារ។ កាលពីមុន លោកបានធ្លាប់បម្រើការជានាយកគ្រប់គ្រង បណ្ដាញសាខា នៅធនាគារស្ថាបនា អស់រយៈពេលជាង១៧ឆ្នាំ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ច ពីសាកលវិទ្យាល័យន័រតុន និងបរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេស (TEFL) ពីសាកលវិទ្យាល័យបៀលប្រាយ។ លោកក៏បានបញ្ចប់វគ្គបណ្ដុះបណ្ដាល ផ្នែកគ្រប់គ្រងធនាគារ និងមីក្រូហិរញ្ញវត្ថុជាច្រើន ប្រមាណជាង៣០ វគ្គទាំងក្នុងស្រុក និងនៅបរទេស។



## លោក ដែន ដារុទ្ធ
នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន

លោក ដែន ដារុទ្ធ មានបទពិសោធន៍ការងារក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុរយៈពេល ១៩ ឆ្នាំ។ លោកបានចូលបម្រើការងារនៅធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា នៅខែកក្កដា ឆ្នាំ២០២១ ជានាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន ដែលមានទំនួលខុសត្រូវចម្បងដូចជា៖ ការអនុវត្តគោការណ៍, យុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន, ដឹកនាំការកែលម្អ, ពន្លឿនប្រព័ន្ធប្រតិបត្តិការផ្សេងៗ, គ្រប់គ្រង និងពង្រឹងហានិភ័យព័ត៌មានវិទ្យា។ ជំនាញនិងការដឹកនាំរបស់លោក មានសារៈប្រយោជន៍ដ៏ល្អ ដល់ធនាគារក្នុងការដឹកនាំអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យានិងប្រសិទ្ធភាពប្រតិបត្តិការ។

លោក បានចាប់ផ្ដើមអាជីពរបស់គាត់នៅឆ្នាំ២០០៥ជាមួយនឹងធនាគារក្នុងស្រុកមួយក្នុងផ្នែកព័ត៌មានវិទ្យា។ នៅឆ្នាំ២០១០ គាត់ជាបុគ្គលិកក្នុងចំណោមអ្នកចូលរួមដំបូងក្នុងការបង្កើតស្ថាប័នធនាគារថ្មី នៃធនាគារធំក្នុងតំបន់មួយ មានតួនាទីជានាយក នាយកដ្ឋានព័ត៌មានវិទ្យានិងប្រតិបត្តិការ។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០១៩ លោកបានដឹកនាំអនុវត្តគម្រោងធនាគារក្នុងស្រុកថ្មីមួយ លើការដំឡើងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យានិងប្រព័ន្ធធនាគារឌីជីថលថ្មី។ ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១ លោកជានាយកប្រតិបត្តិបច្ចេកទេសព័ត៌មានវិទ្យា និងឌីជីថលនៃធនាគាស្ថាបនា។

លោកបានទទួលបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅឆ្នាំ២០០៤ បរិញ្ញាបត្រផ្នែកទំនាក់ទំនងសាធារណៈពីវិទ្យាស្ថានភាសាបរទេសនៅឆ្នាំ២០០៩ និងទទួលវិញ្ញាបនប័ត្រផ្នែកគ្រប់គ្រងនិងដឹកនាំ ពីមហាវិទ្យាល័យបច្ចេកទេសណានយ៉ាង ប្រទេសសឹង្ហបូរី នៅឆ្នាំ២០១៣។





## លោក អឿ វិបុល
នាយកប្រតិបត្តិឥណទាន

លោក អឿ វិបុល មានបទពិសោធន៍ការងារជាង ១៧ឆ្នាំក្នុងវិស័យធនាគារ។ លោកចាប់ផ្ដើមអាជីពនៅធនាគារក្នុងស្រុកឈានមុខគេមួយចាប់តាំងពីឆ្នាំ២០០៤ ជាមួយនឹងតួនាទីជាច្រើនក្នុងផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០១០ លោកបានផ្លាស់ទៅបម្រើការងារក្នុងធនាគារមួយនៃធនាគារដ៏ធំក្នុងតំបន់ ជាអ្នកចូលរួមក្នុងការបង្កើតធនាគារដំបូង ដែលអាចផ្ដល់បន្ថែមនៅបទពិសោធន៍ និងវិជ្ជាជីវៈក្នុងផ្នែកគណនេយ្យ, ហិរញ្ញវត្ថុ, និងការគ្រប់គ្រងហានិភ័យ ព្រមទាំងតួនាទីចុងក្រោយជានាយកផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យ ជាមួយនឹងទំនួលខុសត្រូវចម្បង គឺការអភិវឌ្ឍនិងការអនុវត្តក្របខ័ណ្ឌ និងគោលនយោបាយគ្រប់គ្រងហានិភ័យឱ្យសមស្របនឹងប្រតិបត្តិការ និងបទប្បញ្ញត្តិនានា។

នៅក្នុងខែសីហា ឆ្នាំ២០២០ លោកបានចូលបម្រើការងារជាមួយធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ក្នុងតួនាទីជានាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ ដើម្បីត្រួតពិនិត្យមុខងារគ្រប់គ្រងហានិភ័យ រួមមាន ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យសន្ទនីយភាព និងហានិភ័យទីផ្សារ។

នៅក្នុងឆ្នាំ២០០៤ លោកបានបញ្ចប់ការសិក្សាផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង។



## លោក ជា សុភ័ក្ត
នាយកប្រតិបត្តិហិរញ្ញវត្ថុ

លោក ជា សុភ័ក្ត បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកអភិវឌ្ឍន៍ និងសេដ្ឋកិច្ចអន្តរជាតិ ពីសាលកវិទ្យាល័យជាតិអូស្ត្រាលី និងបានចូលបម្រើការងារ ជាសេដ្ឋកិច្ចវិទូវ័យក្មេងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០១៥ ។ អំឡុងពេលបំពេញការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, លោកត្រូវបានចាត់បញ្ជូនឱ្យទៅបំពេញការងារជា ទីប្រឹក្សាក្រុមប្រឹក្សាភិបាលតំណាងព្រះរាជាណាចក្រកម្ពុជា ប្រចាំធនាគារអភិវឌ្ឍន៍អាស៊ី មានទីស្នាក់ការក្នុងទីក្រុងម៉ានីល នៃប្រទេសហ្វីលីពីន រយៈពេល ២ ឆ្នាំ។

លោកត្រូវបានចាត់តាំងឱ្យមកបម្រើការងារនៅធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ជានាយកប្រតិបត្តិហិរញ្ញវត្ថុ ក្នុងខែមករា ឆ្នាំ២០២៤។



# អភិបាលកិច្ច សាជីវកម្ម

ធនាគារមានអភិបាលកិច្ចដ៏រឹងមាំ ដោយទទួលបានការណែនាំបច្ចេកទេស និងហិរញ្ញវត្ថុ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការត្រួតពិនិត្យបន្ថែមពីធនាគារជាតិ នៃ កម្ពុជា។ ធនាគារត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធានក្រុមប្រឹក្សាភិបាល និងសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល។

ធនាគារ បានអនុវត្តការងារផ្អែកលើគោលការណ៍, បទប្បញ្ញត្តិ, នីតិវិធី, ការផ្ទៀងផ្ទាត់, និងយន្តការវាយតម្លៃដែលបានរៀបចំឡើងដោយគណៈគ្រប់គ្រង និងផ្នែកពាក់ព័ន្ធផ្សេងៗក្នុងធនាគារ និងត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។



## កិច្ចប្រជុំក្រុមប្រឹក្សាភិបាល



ក្រុមប្រឹក្សាភិបាលមានសមាជិកចំនួនប្រាំពីរ (០៧) រូប ដែលរួមមាន៖ អភិបាលប្រតិបត្តិចំនួន ២ រូប និងអភិបាលមិនប្រតិបត្តិចំនួន ៥ រូប។ ក្រុមប្រឹក្សាភិបាលរបស់ធនាគារមានទំនួលខុសត្រូវក្នុងការកំណត់គោលដៅ និងត្រួតពិនិត្យការគ្រប់គ្រង និងកិច្ចការទូទៅរបស់ធនាគារ ស្របតាមគោលនយោបាយរាជរដ្ឋាភិបាល និងបទប្បញ្ញត្តិរបស់អាជ្ញាធរពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព និងទទួលខុសត្រូវជាចម្បងចំពោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ម្ចាស់ភាគហ៊ុនតែមួយគត់) ចំពោះការប្រព្រឹត្តទៅនៃអាជីវកម្មរបស់ធនាគារ។

ក្នុងឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាលបានជួបប្រជុំចំនួន ៥ លើក ដើម្បីពិនិត្យ និងអនុម័តលើកិច្ចការសំខាន់ៗ ដូចជា៖ ការពិនិត្យលើវឌ្ឍនភាពនៃប្រតិបត្តិការធនាគារជាប្រចាំ, ការបង្កើតសាខាថ្មីបន្ថែម, ពិនិត្យ និងពិភាក្សាស្វែងរកដំណោះស្រាយលើបញ្ហាឥណទានមិនដំណើរការ (NPL), ការអនុម័តលើផែនការអាជីវកម្មសម្រាប់រយៈពេល ៣ឆ្នាំ ២០២៤-២០២៦, ការអនុម័តលើផែនការលទ្ធកម្មសម្រាប់ឆ្នាំ២០២៤ និងការអនុម័ត កែសម្រួល និងធ្វើបច្ចុប្បន្នភាពគោលនយោបាយសំខាន់ៗមួយចំនួន។

# គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិចំនួនបួន (០៤) រូប។ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រូវបានអនុញ្ញាតដោយក្រុមប្រឹក្សាភិបាលដើម្បីធានាថាមុខងារគ្រប់គ្រងហានិភ័យនៅក្នុងធនាគារត្រូវបានរៀបចំឡើងប្រកបដោយប្រសិទ្ធភាព។

គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ត្រួតពិនិត្យលើហានិភ័យឥណទាន, ហានិភ័យសន្ទនីយភាព, ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ រួមមាន ការពិនិត្យឡើងវិញនូវហានិភ័យយុទ្ធសាស្ត្រគោលនយោបាយ គោលការណ៍វិធីសាស្ត្រវាយតម្លៃ និងរបាយការណ៍គ្រប់គ្រងហានិភ័យ។ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានតួនាទីរាយការណ៍ទៅក្រុមប្រឹក្សាភិបាលស្តីពីបញ្ហាគ្រប់គ្រងហានិភ័យទាំងអស់របស់ធនាគារ។

កិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម នៅឆ្នាំ២០២៣ បានរៀបចំឡើងចំនួន ៩ ដង ដែលមានការអញ្ជើញចូលរួមពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | ប្រធាន |
| ២ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៣ | ឯកឧត្តម ចាន់ សុខទី (១) | សមាជិក |
| ៤ | លោកស្រី ឈន ដាលិះ | សមាជិក |

*(១) ត្រូវបានតែងតាំងជាសមាជិកនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤*

**តួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម មានដូចខាងក្រោម៖**

## ការងារគ្រប់គ្រងហានិភ័យ

- ពិនិត្យ និងផ្តល់អនុសាសន៍ លើការរៀបចំគោលនយោបាយពាក់ព័ន្ធនានា ការកែប្រែផលិតផល និងគោលនយោបាយផ្សេងៗសម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងផ្តល់អនុសាសន៍ លើសំណើសុំឥណទានមុនដាក់ទៅក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងអនុម័តលើនីតិវិធីផ្សេងៗដែលជំនួយដល់ការអនុវត្តគោលនយោបាយ
- ពិនិត្យលើភាពគ្រប់គ្រាន់នៃគោលនយោបាយ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ការកំណត់ការវាស់វែង និងការតាមដាន ដែលប្រតិបត្តិការទាំងនេះអាចអនុវត្តប្រកបដោយប្រសិទ្ធភាព
- អនុម័តលើគោលនយោបាយដែលបានត្រួតពិនិត្យរួចហើយ ដោយពុំមានការកែប្រែ ឬផ្លាស់ប្តូរតិចតួច
- ធានាឱ្យបាននូវហេដ្ឋារចនាសម្ព័ន្ធធនធាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ ព្រមទាំងធានាថាបុគ្គលិកដែលទទួលខុសត្រូវអាចអនុវត្តភារកិច្ចទាំងនោះដោយឯករាជ្យ
- ពិនិត្យមើលឡើងវិញនូវរបាយការណ៍គ្រប់គ្រងលើសមាសធាតុហានិភ័យប្រឈម គុណភាពទ្រព្យសកម្ម ប្រព័ន្ធវាយតម្លៃហានិភ័យ វិសអាប់តែថាយ (Risk Appetite) ការធ្វើស្ត្រេសតេស្ត និងសកម្មភាពគ្រប់គ្រងហានិភ័យជាប្រចាំ
- ធានាបាននូវការទទួលស្គាល់ឥណទានមិនដំណើរការ អនុលោមទៅតាមគោលនយោបាយ និងនីតិវិធីដែលបានអនុម័ត និងបទប្បញ្ញត្តិនានាដែលមាន
- ពិនិត្យ និងអនុម័តសកម្មភាពហានិភ័យដែលអាចទទួលយកស្របតាមសិទ្ធិដែលបានផ្តល់ជូន
- បង្កើត និងពិនិត្យគណៈកម្មការចំណុះផ្សេងៗ
- ពិនិត្យ និងផ្តល់អនុសាសន៍លើបញ្ហាផ្សេងទៀត ដែលតម្រូវដោយក្រុមប្រឹក្សាភិបាល



## ការងារប្រតិបត្តិតាម

- ពិភាក្សាអំពីហានិភ័យនានាទាក់ទងនឹងបញ្ហា ការប្រតិបត្តិតាមច្បាប់ បទប្បញ្ញត្តិ និងហានិភ័យការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយធានាថាហានិភ័យនានាត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា
- ពិនិត្យ និងអនុម័តគោលនយោបាយ វាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងរួមរបស់ធនាគារក្នុងការអនុលោមភាពច្បាប់ និងហានិភ័យ ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ស្របតាមការយកចិត្តទុកដាក់ខ្ពស់ និងពង្រឹងមុខងារអនុលោមភាព ធនធាន និងហេដ្ឋារចនាសម្ព័ន្ធ របស់ ធ.ស.ក
- ដឹកនាំ និងត្រួតពិនិត្យនូវការអភិវឌ្ឍន៍បច្ចេកទេសនៃអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់បុគ្គលដែលមានសញ្ជាតិអាម៉េរិក(FATCA) និងការរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ
- ពិនិត្យរបាយការណ៍ពីមន្ត្រីប្រតិបត្តិតាម ដើម្បីធានាបាន នូវគោលនយោបាយ និងនីតិវិធី អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិតាមការស្នើសុំពីគណៈកម្មាធិការ ឬតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិនានា
- រាយការណ៍ទៅក្រុមប្រឹក្សាភិបាលលើបញ្ហាដែលទាក់ទងនឹងការប្រតិបត្តិតាម ដើម្បីចាត់វិធានការ និងធ្វើការកែលម្អឱ្យបានទាន់ពេលវេលា ឬតាមសេចក្តីណែនាំផ្សេងៗពីផ្នែកពាក់ព័ន្ធ
- ពិចារណា និងផ្តល់ការយល់ព្រមជាមុន លើការជ្រើសរើស ការតែងតាំង និងការដកតំណែងមន្ត្រីប្រតិបត្តិតាម ទៅតាមសេចក្តីណែនាំរបស់ធនាគារជាតិ នៃកម្ពុជា
- ពិចារណា និងពិនិត្យលើបញ្ហាផ្សេងៗ ដែលក្រុមប្រឹក្សាភិបាលធ្វើការណែនាំឱ្យកែតម្រូវ និងយកចិត្តទុកដាក់ នូវចំណុចដែលត្រូវបានតម្រូវ ឬ/និងរាយការណ៍ជូនក្រុមប្រឹក្សាភិបាលតាមការសមស្រប

## ការងារសំខាន់ៗដែលបានត្រួតពិនិត្យ និងអនុម័តដោយគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម

ក្នុងអំឡុងឆ្នាំ២០២៣ គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម បានសម្រេចការងារសំខាន់ៗមានដូចខាងក្រោម ៖

- បានពិភាក្សាអំពីរបាយការណ៍គ្រប់គ្រងហានិភ័យ
- បានពិភាក្សាអំពីរបាយការណ៍ស្តីពីហានិភ័យប្រតិបត្តិតាមបទប្បញ្ញត្តិ និងហានិភ័យប្រតិបត្តិតាម
- ត្រួតពិនិត្យ និងអនុម័តលើឯកសារវិសអាប់តែថាយ (Risk Appetite)
- ត្រួតពិនិត្យ និងអនុម័តលើសំណើបើកសាខាថ្មីៗបន្ថែម
- ត្រួតពិនិត្យ និងអនុម័តយល់ព្រមលើសិទ្ធអនុម័តឥណទាន
- ត្រួតពិនិត្យ និងអនុម័តលើផលិតផលឥណទានទុនបង្វិល
- ត្រួតពិនិត្យ និងអនុម័តលើគោលនយោបាយគ្រប់គ្រងហានិភ័យក្លែងបន្លំ
- ត្រួតពិនិត្យ និងអនុម័តលើគោលនយោបាយវីស្សលប្លូវីង (Whistleblowing)
- បានអនុម័តលើសេចក្តីណែនាំអំពីនិមិត្តសញ្ញា
- បានអនុម័តលើសេចក្តីណែនាំអំពីវីស្សលប្លូវីង (Whistleblowing)
- បានអនុម័តលើនីតិវិធី ហិរញ្ញវត្ថុ និងគណនេយ្យ
- បានអនុម័តលើនីតិវិធីឥណទាន
- បានអនុម័តលើឯកសារណែនាំប្រតិបត្តិការទូទាត់មូលប្បទានបត្រ
- បានអនុម័តលើឯកសារណែនាំប្រតិបត្តិការផ្ទេរប្រាក់
- បានអនុម័តលើលទ្ធផលនៃការធ្វើស្ត្រេសតេស្ត និងការវិភាគក្នុងឆ្នាំ២០២៣

## ផ្នែកគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យដើរតួនាទីចម្បងក្នុងវិស័យធនាគារ និងកាន់តែសំខាន់ក្នុងស្ថានភាពសេដ្ឋកិច្ចមិនច្បាស់លាស់។ វប្បធម៌គ្រប់គ្រងហានិភ័យត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកនីមួយៗនៃអាជីវកម្ម ដើម្បីធានានូវភាពគ្រប់គ្រាន់នៃប្រព័ន្ធគ្រប់គ្រងហានិភ័យក្នុងកម្រិតមួយដែលអាចទទួលយកបាន សម្រាប់ការរីកចម្រើនប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងហានិភ័យមានមុខងារឯករាជ្យ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកពាក់ព័ន្ធ ដើម្បីធានាបាននូវប្រព័ន្ធ និងវប្បធម៌គ្រប់គ្រងហានិភ័យល្អ ប្រកបដោយភាពរឹងមាំ។

ជាការសន្និដ្ឋានរួម ការគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវចំពោះមុខងារគ្រប់គ្រងហានិភ័យប្រចាំថ្ងៃ ក៏ដូចជាការត្រួតពិនិត្យហានិភ័យប្រឈមរបស់ធនាគារ និងធ្វើការរាយការណ៍ជាប្រចាំទៅគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម។

**ធនាគារបានផ្តោតសំខាន់ទៅលើហានិភ័យចម្បងៗមួយចំនួនដូចខាងក្រោម៖**

### ហានិភ័យឥណទាន

ជាការខាតបង់ដែលកើតឡើងដោយភាគីអ្នកខ្ចី ឬដៃគូសហការខកខានមិនបានអនុវត្តកាតព្វកិច្ចសងតាមកិច្ចសន្យារបស់ខ្លួនជាមួយធនាគារ។ ដំណាក់កាលនៃការគ្រប់គ្រងហានិភ័យឥណទាន ត្រូវបានផ្តោតសំខាន់លើការវិភាគ អនុម័ត និងតាមដានឥណទានប្រកបដោយភាពឯករាជ្យ និងវិជ្ជាជីវៈ ដើម្បីធ្វើឱ្យប្រាកដថាលក្ខខណ្ឌដែលបានអនុម័តត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ផ្នែកគ្រប់គ្រងឥណទានអនុវត្តតួនាទីនៃការដាស់តឿន និងតាមដាន ដើម្បីធានាថាលក្ខខណ្ឌដែលបានអនុម័តត្រូវបានត្រួតពិនិត្យយ៉ាងត្រឹមត្រូវ។ ផ្នែកគ្រប់គ្រងឥណទានក៏មានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យឥណទានទាំងអស់របស់ធនាគារ និងកម្រិតកំណត់ដែលទាក់ទងនឹងឥណទាន។ ផ្នែកគ្រប់គ្រងឥណទាន មានតួនាទីក្នុងការត្រួតពិនិត្យគុណភាពឥណទាន និងការត្រួតពិនិត្យ និងការស្តារឥណទាន ដើម្បីពង្រឹងគុណភាពទ្រព្យសកម្ម និងនិរន្តរភាពរយៈពេលវែងរបស់ធនាគារផងដែរ។ ការអភិវឌ្ឍជំនាញនៃការគ្រប់គ្រងហានិភ័យឥណទានជូនដល់គ្រប់បុគ្គលិកពាក់ព័ន្ធ ចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយហានិភ័យឥណទាន។

### ហានិភ័យសន្ទនីយភាព

ហានិភ័យដែលធនាគារមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ដល់ការរីកចម្រើន ឬបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួន ដោយមិនមានការខាតបង់ដែលមិនអាចទទួលយកបាន។

ធនាគារ ត្រូវរក្សាកម្រិតសន្ទនីយភាពឱ្យបានគ្រប់គ្រាន់ គ្រប់ពេលវេលាដូចជាស្ថានភាពរំហូរសាច់ប្រាក់ និង/ឬ ទ្រព្យសកម្មដែលងាយស្រួលក្នុងការដោះដូរ ដើម្បីអាចបំពេញបានទៅតាមកាតព្វកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិក្រោមលក្ខខណ្ឌអាជីវកម្មធម្មតា និងស្ថានភាពស្ត្រេស។

ការទទួលយកហានិភ័យសន្ទនីយភាពរបស់ធនាគារត្រូវបានគ្រប់គ្រងដោយ Liquidity Risk Appetite កំណត់កម្រិតហានិភ័យសន្ទនីយភាព ដែលធនាគារនឹងទទួលយកតាមយុទ្ធសាស្ត្រ និងគោលដៅអាជីវកម្មរបស់ខ្លួន។ វិសអាប់ភៃថាយ (Risk Appetite) គិតគូរពីកំណើនផលចំណូល និងគោលបំណងអាជីវកម្មរបស់ធនាគារ ក៏ដូចជា សមត្ថភាពគ្រប់គ្រងហានិភ័យ។

តួនាទីគ្រប់គ្រងហានិភ័យ ទទួលខុសត្រូវតាមដានដោយឯករាជ្យនូវទម្រង់ហានិភ័យសន្ទនីយភាពរបស់ធនាគារ និងផ្តល់របាយការណ៍ជាប្រចាំដល់គណៈកម្មការគ្រប់គ្រងហានិភ័យ (កម្រិតប្រតិបត្តិ) ក៏ដូចជាគណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម ដើម្បីឱ្យធនាគារចាត់ចែងស្ថានភាពសន្ទនីយភាព ហើយឆ្លើយតបនឹងតម្រូវការប្រតិបត្តិការប្រចាំថ្ងៃ និងតម្រូវការបទប្បញ្ញត្តិ។

### ហានិភ័យទីផ្សារ

ត្រូវបានកំណត់ថាជាការប្រែប្រួល នៅក្នុងតម្លៃទីផ្សារហិរញ្ញវត្ថុដោយសារតែការផ្លាស់ប្តូរ អត្រាហានិភ័យទីផ្សារ ដូចជាអត្រាការប្រាក់, ប្តូរប្រាក់ និងការប៉ះពាល់លើប្រាក់ចំណេញឥណទាន, តម្លៃភាគហ៊ុន, តម្លៃទំនិញ និងបម្រែបម្រួលពីកត្តាផ្សេងៗ ដែលពាក់ព័ន្ធ។

### ហានិភ័យប្រតិបត្តិការ

សំដៅទៅលើហានិភ័យនៃការបាត់បង់ដែលបណ្តាលមកពីភាពមិនគ្រប់គ្រាន់ ឬបរាជ័យនៃដំណើរការផ្ទៃក្នុង មនុស្ស និងប្រព័ន្ធ ឬព្រឹត្តិការណ៍ខាងក្រៅ។ ហានិភ័យប្រតិបត្តិការ បានរួមបញ្ចូលទាំងហានិភ័យផ្នែកច្បាប់ ប៉ុន្តែមិនមានហានិភ័យយុទ្ធសាស្ត្រ និងហានិភ័យកេរ្តិ៍ឈ្មោះទេ។ តម្រូវការសំខាន់មួយនៃរចនាសម្ព័ន្ធគ្រប់គ្រងហានិភ័យរឹងមាំគឺ ត្រូវមានឧបករណ៍គ្រប់គ្រងហានិភ័យប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពដើម្បីកំណត់វាស់វែង តាមដាន ត្រួតពិនិត្យ និងរាយការណ៍អំពីហានិភ័យប្រតិបត្តិការរបស់ធនាគារ។



# គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាល និងមានអភិបាលមិនប្រតិបត្តិចំនួនបួន (០៤) រូបដើម្បីផ្តល់ការត្រួតពិនិត្យឯករាជ្យទៅលើសវនកម្មផ្ទៃក្នុង, របាយការណ៍ហិរញ្ញវត្ថុ, ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ ដើម្បីធានាដល់ការត្រួតពិនិត្យ និងសមតុល្យ ព្រមទាំងសមភាព និងអនុលោមតាមតម្រូវការបទប្បញ្ញត្តិនៅក្នុងវិស័យធនាគារ។ ការប្រជុំរបស់គណៈកម្មការសវនកម្ម នៅឆ្នាំ២០២៣ សរុបចំនួនប្រាំ (០៥) ដង ហើយមានការចូលរួមពីសមាជិក-សមាជិកា ដូចខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | លោកស្រី ឈន ដាលិះ | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម សុន សេងហួត | សមាជិក |
| ៤ | ឯកឧត្តម ចាន់ សុខទី | សមាជិក |

**គណៈកម្មការសវនកម្ម អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- ធានាថាព័ត៌មានដែលបានផ្តល់ជូនដល់សាធារណជន និងធនាគារជាតិ នៃ កម្ពុជា មានភាពច្បាស់លាស់ ត្រឹមត្រូវ និងអាចទុកចិត្តបាន
- ធានាថា សវនករផ្ទៃក្នុងធ្វើសវនកម្មជាទៀងទាត់នូវវិធីសាស្ត្រគណនេយ្យកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីឆ្លើយតបនឹងការរំពឹងទុកនៃបទប្បញ្ញត្តិ និងក្រុមប្រឹក្សាភិបាល
- វាយតម្លៃ ត្រួតពិនិត្យ និងអនុម័ត ទៅលើគោលនយោបាយសវនកម្មផ្ទៃក្នុង នីតិវិធី និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ជាពិសេសប្រព័ន្ធសម្រាប់វាស់តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យមានភាពស៊ីសង្វាក់គ្នា និងផ្តល់អនុសាសន៍នូវចំណុចខ្វះខាត
- ជួយដល់ក្រុមប្រឹក្សាភិបាល ក្នុងការត្រួតពិនិត្យលើការអនុវត្តស្តីពីគោលនយោបាយគណនេយ្យ និងការរៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង
- ធានាឱ្យបាននូវសកម្មភាពកែតម្រូវ ដែលបានព្រមព្រៀងរវាងសវនករផ្ទៃក្នុង និងគណៈគ្រប់គ្រង ដើម្បីអនុវត្តតាមកាលបរិច្ឆេទដែលបានកំណត់

### សមិទ្ធផលដែលគណៈកម្មការសវនកម្មសម្រេចបានក្នុងឆ្នាំ២០២៣៖

- ពិនិត្យ និងផ្តល់ជាអនុសាសន៍លើការរកឃើញរបស់សវនកម្មផ្ទៃក្នុង
- ពិភាក្សាអំពីសូចនាករវាយតម្លៃលទ្ធផលការងារសម្រាប់ក្រុមសវនកម្មផ្ទៃក្នុង, កញ្ចប់ថវិកា, និងចំនួនបុគ្គលិក
- ត្រួតពិនិត្យការអនុវត្តតាមអនុសាសន៍ពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងគណៈកម្មការសវនកម្ម
- ពិនិត្យ និងអនុម័តលើការធ្វើបច្ចុប្បន្នកម្មលើវិធីសាស្ត្រសវនកម្មផ្ទៃក្នុង និងទម្រង់របាយការណ៍សវនកម្មផ្ទៃក្នុង
- ពិនិត្យ និងឯកភាពលើសំណើក្នុងការជ្រើសរើសសវនករឯករាជ្យ មុននឹងធ្វើការដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ដឹកនាំកិច្ចប្រជុំរវាងគណៈគ្រប់គ្រងជាមួយសវនករឯករាជ្យលើការរកឃើញរបស់សវនករឯករាជ្យ
- ត្រួតពិនិត្យលើរបាយការណ៍សវនកម្មប្រចាំឆ្នាំ២០២២ មុននឹងធ្វើការដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត ព្រមទាំងធ្វើការរាយការណ៍ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងដែលបានអនុម័ត ២០២២ រាយការណ៍ជូនទៅធនាគារជាតិ នៃ កម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ពិនិត្យលើវគ្គបណ្តុះបណ្តាលសម្រាប់សវនករផ្ទៃក្នុង ដើម្បីធ្វើការពង្រឹងនូវសមត្ថភាព
- ពិនិត្យ និងអនុម័តផែនការការងារនៃសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំ២០២៣
- វាយតម្លៃការអនុវត្តប្រចាំឆ្នាំរបស់នាយិកាសវនកម្មផ្ទៃក្នុង។

## សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុងមានតួនាទីក្នុងការវាយតម្លៃ ត្រួតពិនិត្យ តាមដាន ការអនុវត្ត ទៅលើដំណើរការប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចរបស់ធនាគារជាប្រចាំគ្រា  ដើម្បីឱ្យប្រាកដថាទទួលបានលទ្ធផលសមស្របទៅតាមទស្សនៈវិស័យ និងកម្មវត្ថុដែលធនាគារកំណត់ប្រកបដោយប្រសិទ្ធភាព។ ដើម្បីធានាបាននូវតម្លាភាព និងឯករាជ្យភាពនៃការងារសវនកម្ម សវនករផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនទៅគណៈកម្មការសវនកម្ម និងរាយការណ៍ដោយប្រយោលជូនទៅអគ្គនាយក លើការងាររដ្ឋបាលមួយចំនួន។

### តួនាទីសវនករផ្ទៃក្នុង៖

- គ្រប់គ្រងការងារសវនកម្ម តួនាទី សម្របសម្រួលពិនិត្យឡើងវិញ និងរាយការណ៍អំពីការងាររបស់សវនករផ្ទៃក្នុង និងផ្តល់ជំនាញក្នុងស្តង់ដារសវនកម្ម និងលក្ខណៈវិនិច្ឆ័យការអនុវត្ត និងតម្រូវការរបស់សវនកម្មផ្ទៃក្នុង។
- រៀបចំផែនការចាត់ចែង និងត្រួតពិនិត្យសកម្មភាព និងការងារប្រចាំថ្ងៃរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង រក្សាទំនាក់ទំនងអតិថិជន និងបុគ្គលិកប្រកបដោយប្រសិទ្ធភាព ព្រមទាំងប្រសិទ្ធផល។
- ធានាឱ្យបានថារាល់គោលនយោបាយ និងនីតិវិធីផ្ទៃក្នុង ត្រូវបានអនុវត្តយ៉ាងពេញលេញដោយគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ។
- ណែនាំការគ្រប់គ្រងលើផលប៉ះពាល់នៃហានិភ័យដែលទាក់ទងនឹងផលិតផល សេវាកម្ម ឬសកម្មភាពថ្មីៗ និងផែនការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យទាំងនោះ។
- រៀបចំ និងធ្វើបច្ចុប្បន្នភាពលើផែនការសវនកម្មផ្ទៃក្នុងដោយផ្អែកលើហានិភ័យសម្រាប់ការវាយតម្លៃ ប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យសំខាន់ៗ។
- ធានានូវការឆ្លើយតប និងចំណាត់ការពីគណៈគ្រប់គ្រង ចំពោះលទ្ធផលនៃការធ្វើសវនកម្ម និងការអនុវត្តអនុសាសន៍នានា ដែលផ្តល់ដោយសវនករផ្ទៃក្នុង ទៅតាមពេលវេលាដែលបានព្រមព្រៀង។
- ជួយគណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាលក្នុងការបំពេញនូវទំនួលខុសត្រូវ ទៅលើការអនុវត្តត្រឹមត្រូវនៃគោលនយោបាយគណនេយ្យ របាយការណ៍ ភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុង។



# គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ ត្រូវបានបង្កើតឡើង នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ដែលជាគណៈកម្មការចំណុះឱ្យក្រុមប្រឹក្សាភិបាល នៃធ.ស.ក។ គណៈកម្មការនេះ មានតួនាទីភារកិច្ចជាចម្បងក្នុងការធានាថា គោលនយោបាយអត្ថប្រយោជន៍របស់បុគ្គលិកត្រូវមានសង្គតិភាពទៅនឹងគោលដៅរយៈពេលវែង គុណតម្លៃស្នូលរបស់ធនាគារ គោលដៅរបស់ធនាគារ អត្ថប្រយោជន៍ត្រូវមានភាពប្រហាក់ប្រហែលទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុនានា និងកត្តាផ្សេងៗទៀតដែលបម្រើឱ្យតម្រូវការហិរញ្ញវត្ថុ និងតម្រូវការពាណិជ្ជកម្មរបស់ធនាគារ។ គណៈកម្មការនេះ ត្រូវបានបង្កើតឡើងស្របតាមប្រកាសធនាគារជាតិនៃកម្ពុជា លេខធ៧-០៨-២១១ ប្រ.ក ស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។ បច្ចុប្បន្នគណៈកម្មការនេះ មានសមាជិកចំនួន ៤ (បួន) រូប និងប្រធានចំនួន ១ (មួយ) រូប ដូចមានរៀបរាប់ខាងក្រោម៖

| ល.រ | ឈ្មោះ | សមាសភាពក្នុងអង្គប្រជុំ |
|---|---|---|
| ១ | ឯកឧត្តម សុន សេងហួត | ប្រធាន |
| ២ | ឯកឧត្តម ទេព ភិយ្យោរិទ្ធ | សមាជិក |
| ៣ | ឯកឧត្តម ចាន់ សុខទី | សមាជិក |
| ៤ | លោកស្រី ឈន ដាលិះ | សមាជិកា |
| ៥ | លោក នៀវ សុគន្ធ | សមាជិក |

### គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ អនុវត្តតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យមើលលើគ្រប់ទិដ្ឋភាពនៃតម្លៃការទាំងអស់ មិនកំណត់តែលើប្រាក់កម្រៃរបស់អភិបាលដែលមានដូចជា៖ ប្រាក់ខែ ប្រាក់ឧបត្ថម្ភការចំណាយ ថ្លៃប្រឹក្សាយោបល់ (ប្រសិនបើមាន) និងអត្ថប្រយោជន៍ផ្សេងៗ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលអំពីតម្លៃការរបស់អភិបាលធនាគារ។
- ផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាលនូវគោលដៅប្រចាំឆ្នាំ និងផែនការអត្ថប្រយោជន៍ (រួមទាំងប្រាក់រង្វាន់ និងផែនការផ្សេងទៀត ដែលបង្កើតឡើងដើម្បីជំរុញដល់ការបង្កើនតម្លៃរួមរយៈពេលវែង) សម្រាប់គណៈគ្រប់គ្រងធនាគារ នាយកផ្នែកសវនកម្មផ្ទៃក្នុង និងប្រធានផ្នែកប្រតិបត្តិតាម សម្រាប់ឆ្នាំបន្ទាប់។
- ពិនិត្យឡើងវិញនូវប្រាក់ឧបត្ថម្ភ និងទម្រង់នៃអត្ថប្រយោជន៍ផ្សេងៗដល់គណៈគ្រប់គ្រង និងប្រធានផ្នែកសំខាន់ៗរបស់ធនាគារ ដើម្បីធានាភាពសមស្របទៅនឹងទំនួលខុសត្រូវ និងហានិភ័យដែលអាចពាក់ព័ន្ធនឹងសមាជិកភាពប្រកបដោយប្រសិទ្ធភាពរបស់គណៈគ្រប់គ្រង។
- ពិនិត្យឡើងវិញ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល និងគណៈកម្មការ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។
- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីពាក់ព័ន្ធយ៉ាងហោចណាស់ ម្តងក្នុងមួយឆ្នាំ សម្រាប់ការអនុម័តពីក្រុមប្រឹក្សាភិបាល។

### សមិទ្ធផលដែលគណៈកម្មការតែងតាំង និងផ្តល់តម្លៃការសម្រេចបានក្នុងឆ្នាំ ២០២៣៖

- ពិនិត្យ  និងផ្តល់យោបល់លើការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំ២០២៣ ដល់បុគ្គលិកធនាគារ មុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត
- ពិនិត្យ និងទទួលស្គាល់លើទម្រង់ និងការកំណត់សូចនាករវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ២០២៣
- ពិនិត្យ និងផ្តល់ការឯកភាពជាគោលការណ៍ លើលទ្ធផលវាយតម្លៃសូចនាករការងាររបស់បុគ្គលិកប្រចាំឆ្នាំ២០២៣
- ពិនិត្យ និងអនុម័តលើ នីតិវិធីជ្រើសរើសបុគ្គលិក
- ពិនិត្យ និងផ្តល់ការឯកភាពជាគោលការណ៍ លើគោលនយោបាយធនធានមនុស្ស មុននឹងដាក់ជូនក្រុមប្រឹក្សា-ភិបាលអនុម័ត






# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ហៅកាត់ថា “ធនាគារ”) សូមដាក់បង្ហាញនូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។

## សកម្មភាពអាជីវកម្មចម្បង

ធនាគារត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាធនាគារគ្រប់គ្រងដោយរដ្ឋ ដែលរៀបចំឡើងក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ Co ០០០១ M/២០២០ ចេញដោយក្រសួងពាណិជ្ជកម្មចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ ធនាគារស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។

ធនាគារទទួលបានអាជ្ញាបណ្ណធនាគាររបស់ខ្លួនពី ធនាគារជាតិ នៃ កម្ពុជា (“NBC”) នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវអូស៊ីអាយស៊ី ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលនៃប្រតិបត្តិការ និងភាគលាភ

លទ្ធផលនៃប្រតិបត្តិអាជីវកម្មការរបស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងស្ថានភាពនៃអាជីវកម្មរបស់ធនាគារនាកាលបរិច្ឆេទនោះ គឺត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលអមមកជាមួយ។

ពុំមានភាគលាភត្រូវបានដាក់ស្នើ បានប្រកាស ឬបានបង់ដោយធនាគារក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

## ការខាតបង់ឥណទានដែលបានរំពឹងទុកលើឥណទាន និងបុរេប្រទាន

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីឈានដល់ការអះអាងថាទីតិវិធីដែលពាក់ព័ន្ធនឹងការលុបឥណទានអាក្រក់ចេញពីបញ្ជី ឬការទទួលស្គាល់នៃសំវិធានធនលើការខាតបង់ឥណទានដែលបានរំពឹងទុកត្រូវបានយកមកអនុវត្ត ហើយជឿជាក់ថារាល់ឥណទានអាក្រក់ដែលបានទទួលស្គាល់ត្រូវបានលុបចេញពីបញ្ជី និងបានធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះការខាតបង់ឥណទានដែលបានរំពឹងទុកលើឥណទាន និងបុរេប្រទានទាំងនោះ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានការណ៍ណាមួយដែលបណ្តាលឱ្យសមតុល្យនៃឥណទានអាក្រក់ត្រូវបានលុបចេញ ឬសមតុល្យនៃសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានមិនគ្រប់គ្រាន់ទៅនឹងវិសាលភាពជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីធានាថាទ្រព្យសកម្មទាំងឡាយណាដែលទំនងជាមិនអាចទទួលស្គាល់ក្នុងប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារបានតាមតម្លៃដែលបានបង្ហាញក្នុងកំណត់ត្រាគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងសមតុល្យដែលត្រូវបានរំពឹងទុកថាអាចទទួលស្គាល់បាន។

នាកាលបរិច្ឆេទនៃរបាយកាណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលនឹងបណ្តាលឱ្យការកំណត់តម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនត្រឹមត្រូវជាសារវន្តណាមួយនោះទេ។

## វិធីសាស្ត្រវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺ៖

(ក) ពុំមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទមក ដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ លើកលែងតែបានលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(ខ) ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះធនាគារចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងបញ្ចប់ការិយបរិច្ឆេទដែលនឹងមាន ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

## ការប្រែប្រួលកាលៈទេសៈ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលមិនបានរៃកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលនឹងបណ្តាលឱ្យសមតុល្យណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងចុងការិយបរិច្ឆេទនេះ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ធនាគារ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុបច្ចុប្បន្នដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។



## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលកាន់តំណែងក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចជា៖

| ឈ្មោះ | មុខតំណែង |
|---|---|
| ឯកឧត្តមបណ្ឌិត ផាន់ ផល្លា | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាល |
| ឯកឧត្តម ទេព ភិយ្យោវិទ្រូ | សមាជិក |
| ឯកឧត្តម សុន សេងហួត | សមាជិក |
| ឯកឧត្តម ចាន់ សុខទី | សមាជិក |
| លោកស្រី ឈន ដាលិះ | សមាជិកា |
| បណ្ឌិត លឹម អូន | អគ្គនាយក និងសមាជិក |
| លោក នៀវ សុគន្ធ | នាយកប្រតិបត្តិប្រតិបត្តិការ និងសមាជិក |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនស្នងការគណនេយ្យ ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់កាន់កាប់ភាគកម្មណាមួយក្នុងគណនីមូលធនរបស់ធនាគារឡើយ។ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងផ្តល់លទ្ធភាពដល់សមាជិកឱ្យទទួលបានភាគកម្មនៅក្នុងធនាគារ ឬសកម្មភាពសាជីវកម្មផ្សេងៗទៀតនោះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងនាចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយដែលមានធនាគារជាភាគី ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុន ឬបណ្ណបំណុលរបស់ធនាគារ ឬសកម្មភាពសាជីវកម្មផ្សេងៗទៀតនោះទេ។

ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានអភិបាលរបស់ធនាគារបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬដោយសាជីវកម្មពាក់ព័ន្ធជាមួយនឹងធនាគារដែលមានអភិបាលនោះជាសមាជិក ឬជាមួយក្រុមហ៊ុនដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែមានការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញនូវគ្រប់ទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRS) និងសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ គណៈគ្រប់គ្រងតម្រូវឱ្យ៖

- អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព

- អនុលោមតាមតម្រូវការលាតត្រដាងនៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”) ឬប្រសិនបើមានការប្រាសចាកណាមួយពីតម្រូវការទាំងនោះក្នុងការបង្ហាញនូវភាពទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងត្រូវប្រាកដថាការប្រាសចាកទាំងនោះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព
- វាយតម្លៃលទ្ធភាពរបស់ធនាគារដើម្បីបន្តនិរន្តរភាព ការលាតត្រដាង ប្រសិនបើមាន បញ្ហាដែលទាក់ទងនឹងការបន្តនិរន្តរភាព និងការប្រើប្រាស់មូលដ្ឋាននៃការបន្តនិរន្តរភាពនៃគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើស ប៉ុន្តែចាំបាច់ត្រូវធ្វើ និង
- ត្រួតពិនិត្យ និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងអស់ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ធនាគារ ហើយត្រូវប្រាកដថារាល់ការសម្រេចចិត្ត និង/ឬ សេចក្តីណែនាំត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យសមស្របដើម្បីទប់ស្កាត់ និងរកឱ្យឃើញនូវការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ធនាគារបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំ និងត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល អមជាមួយរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានរៀបចំឡើងយ៉ាងសមស្រប និងផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាជំនួសឱ្យក្រុមប្រឹក្សាភិបាល៖

**ឯកឧត្តមបណ្ឌិត ផាន់ ផល្លា**
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាភិបាល

**បណ្ឌិត លឹម អួន**
អគ្គនាយក និងសមាជិក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤



# របាយការណ៍របស់សវនករឯករាជ្យ

### ជូនចំពោះភាគហ៊ុនិករបស់
### ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក

## មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ហៅកាត់ថា “ធនាគារ”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់ជាមួយត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវជាសារវន្តពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (”CIFRSs”) ព្រមជាមួយសេចក្តីណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដាទាំងនោះ គឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកនៃការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីធនាគារ ដោយអនុលោមតាមក្រុមប្រឹក្សាស្តង់ដាវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យអន្តរជាតិ) (“IESBA Code”) រួមជាមួយនឹងតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានគឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

គណៈគ្រប់គ្រងមានទំនួលខុសត្រូវទាំងស្រុងទៅលើការរៀបចំព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗទាំងនោះរួមមាន របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ដែលបានផ្តល់ជូនយើងខ្ញុំមុនកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករនេះ ប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំ ព្រមទាំងរបាយការណ៍ប្រចាំឆ្នាំ ដែលរំពឹងទុកថាបានរៀបចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំមិនផ្តល់ការធានា ឬសេចក្តីសន្និដ្ឋានក្នុងទម្រង់បែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើព័ត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើ ផ្អែកតាមការងារដែលយើងធ្វើសវនកម្ម យើងខ្ញុំសន្និដ្ឋានថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តណាមួយកើតមានឡើង យើងខ្ញុំត្រូវធ្វើការទាក់ទងជាមួយក្រុមប្រឹក្សាភិបាល និងឆ្លើយតបទៅលើបញ្ហាទាំងនេះដោយអនុលោមតាមការតម្រូវរបស់ CISA ៧២០ (បានធ្វើការកែតម្រូវ)។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (”CIFRSs”) និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមិនឱ្យមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើសមត្ថភាពធនាគារក្នុងការបន្តប្រតិបត្តិដោយផ្អែកលើមូលដ្ឋាននិរន្តរភាពការលាតត្រដាងប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តរភាព និងការប្រើប្រាស់និរន្តរភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យទៅលើដំណើរការនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀតដែលបានបង្ហាញមតិយោបល់មិនអាចកែប្រែបាន ហើយរបាយការណ៍ហិរញ្ញវត្ថុទាំងនោះបានបង្ហាញនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលកើតមានឡើង។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”) យើងខ្ញុំអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យ និងរក្សាមជ្ឈធាតុនិយមប្រកបដោយវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់ និងសមស្របដើម្បីជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនាការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។
- វាយតម្លៃភាពសមស្របលើគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រងលើមូលដ្ឋាននិរន្តរភាពគណនេយ្យ និងផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តរភាពរបស់ធនាគារ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងខ្ញុំតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឱ្យធនាគារមិនអាចបន្តប្រតិបត្តិការជានិរន្តរភាពបាន។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

យើងខ្ញុំប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបកគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលយើងខ្ញុំរកឃើញអំឡុងពេលធ្វើសវនកម្ម។

**ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត**
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាម៉េរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៤.២) | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាម៉េរិក | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៦ | ១.៩៩៨.៦៣៤ | ៨.១៦៤.៤២០ | ៥៧០.៧៥០ | ២.៣៤៩.៧៧៨ |
| សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា | ៧ | ១០.២៤៥.៨៣៣ | ៤១.៨៥៤.២២៨ | ១២.៩៧០.៣៩៨ | ៥៣.៣៩៩.១២៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៨ | ៩១.០៨២.៧៩៣ | ៣៧២.០៧៣.២០៩ | ៥០.៤៧៨.៣៨២ | ២០៧.៨១៩.៤៩៩ |
| ឥណទាន និងបុរេប្រទានជូនអតិថិជន - សុទ្ធ | ៩ | ២១១.៩៣៣.៨៥៣ | ៨៦៥.៧៤៩.៧៩០ | ២១០.៥០០.៩៣២ | ៨៦៦.៦៣២.៣៣៧ |
| ទ្រព្យសកម្មអរូបី | ១១ | ៦១៤.៤១៩ | ២.៥០៩.៩០២ | ៧៨៩.៧២៧ | ៣.២៥១.៣០៦ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ២.១៤៥.៥១១ | ៨.៧៦៤.៤១២ | ១.៨០៨.៨៩៧ | ៧.៤៤៧.២២៩ |
| សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម | ១៣ | ២.០៣៤.៦០១ | ៨.៣១១.៣៤៥ | ២.២៩៥.១៩១ | ៩.៤៤៩.៣០១ |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | ១៤ | ៣៣៨.២៧២ | ១.៣៨១.៨៤១ | ៣២១.៩៦៥ | ១.៣២៥.៥៣០ |
| ទ្រព្យសកម្មពន្ធពន្យារ | ១៥ | ៨៣៦.៩១៧ | ៣.៤១៨.៨០៥ | ៨២០.៩៦៩ | ៣.៣៧៩.៩២៩ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ៣៨៦.៦៧៧ | ១.៥៧៩.៥៧៥ | ១៨២.៩៣៩ | ៧៥៣.១៥៩ |
| **ទ្រព្យសកម្មសរុប** | | **៣២១.៦១៧.៥១០** | **១.៣១៣.៨០៧.៥២៧** | **២៨០.៧៤០.១៥០** | **១.១៥៥.៨០៧.១៩៧** |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ២០ | ២០០.០០០.០០០ | ៨០០.០០០.០០០ | ២០០.០០០.០០០ | ៨០០.០០០.០០០ |
| វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២១ | ១.២៤៦.៨៨២ | ៤.៩៨៧.៥២៨ | ១.២៤៦.៨៨២ | ៤.៩៨៧.៥២៨ |
| ទុនបម្រុងបទប្បញ្ញត្តិ | ៤.១៦ | ១.២៥៩.៥៨៤ | ៥.១៤៥.៤០១ | - | - |
| ខាតបង្គរ | | (៤.២១៣.៣៤៤) | (១៧.១៧៧.៥៥៣) | (២.៦៨១.៣៦៩) | (១០.៩១២.៦២៤) |
| លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរ | | - | ១៧.០៧២.០២៧ | - | ២៣.៤១៩.៣១៣ |
| **មូលធនសរុប** | | **១៩៨.២៩៣.១២២** | **៨១០.០២៧.៤០៣** | **១៩៨.៥៦៥.៥១៣** | **៨១៧.៤៩៤.២១៧** |
| **បំណុល** | | | | | |
| ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ | ១៦ | ៥២.៨៥៥ | ២១៥.៩១៣ | ៤៩.៤៦១ | ២០៣.៦៣១ |
| ប្រាក់បញ្ញើពីអតិថិជន | ១៧ | ៣.៩៦៤.៨៦០ | ១៦.១៩៦.៤៥៣ | ៤.៦៦០.៥២៤ | ១៩.១៨៧.៣៧៧ |
| ប្រាក់កម្ចី | ១៨ | ១១៦.៥១១.៥៧៣ | ៤៧៥.៩៤៩.៧៧៦ | ៧៤.០១៦.២៧៤ | ៣០៤.៧២៥.០០០ |
| បំណុលពន្ធលើប្រាក់ចំណូល | ១៥.១ | ១១.៥២១ | ៤៧.០៦៣ | ២៥៣.០៦៩ | ១.០៤១.៨៨៥ |
| បំណុលភតិសន្យា | ១៣ | ២.១០០.០៤១ | ៨.៥៧៨.៦៦៧ | ២.៣១០.៦១៨ | ៩.៥១២.៨១៤ |
| បំណុលផ្សេងៗ | ១៩ | ៦៨៣.៥៣៨ | ២.៧៩២.២៥២ | ៨៨៤.៦៩១ | ៣.៦៤២.២៧៣ |
| **បំណុលសរុប** | | **១២៣.៣២៤.៣៨៨** | **៥០៣.៧៨០.១២៤** | **៨២.១៧៤.៦៣៧** | **៣៣៨.៣១២.៩៨០** |
| **មូលធន និងបំណុលសរុប** | | **៣២១.៦១៧.៥១០** | **១.៣១៣.៨០៧.៥២៧** | **២៨០.៧៤០.១៥០** | **១.១៥៥.៨០៧.១៩៧** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។



# របាយការណ៍ចំណូលលម្អិត

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាម៉េរិក | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល (កំណត់សម្គាល់ ៤.២) | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាម៉េរិក | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពាន់រៀល (កំណត់សម្គាល់ ៤.២) |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ២២ | ១០.៧៨០.៤៨៣ | ៤៤.៣០៧.៧៨៥ | ៦.៣៨៧.៨៥៩ | ២៦.១០៧.១៨០ |
| ចំណាយការប្រាក់ | ២២ | (១.៧១១.៤០៣) | (៧.០៣៣.៨៦៦) | (៣៦.៣៤៥) | (១៤៨.៥៤២) |
| **ចំណូលការប្រាក់សុទ្ធ** | | ៩.០៦៩.០៨០ | ៣៧.២៧៣.៩១៩ | ៦.៣៥១.៥១៤ | ២៥.៩៥៨.៦៣៨ |
| កម្រៃសេវា និងកម្រៃជើងសាសុទ្ធ | ២៣ | ២០៣.៥៩៤ | ៨៣៦.៧៧១ | ២៤.០៦២ | ៩៨.៣៤១ |
| ចំណេញ/(ខាត)ពីការប្តូររូបិយប័ណ្ណ | | ២១៥.៥៣៧ | ៨៨៥.៨៥៧ | (៥២៧.៧៩៥) | (២.១៥៧.០៩៨) |
| **ចំណូលប្រតិបត្តិការសរុប** | | ៩.៤៨៨.២១១ | ៣៨.៩៩៦.៥៤៧ | ៥.៨៤៧.៧៨១ | ២៣.៨៩៩.៨៨១ |
| សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក | ៩ | (៣.៥១៧.២៥៧) | (១៤.៤៥៥.៩២៦) | (២.០២៨.៦០៧) | (៨.២៩០.៩១៧) |
| ចំណាយលើបុគ្គលិក | ២៤ | (៣.៥៤៩.៥៨៧) | (១៤.៥៨៨.៨០៣) | (១.៩៦៤.៦៤២) | (៨.០២៩.៤៩២) |
| រំលស់លើទ្រព្យសកម្មរូបី និងអរូបី | ២៥ | (១.២៤៧.៩៥០) | (៥.១២៩.០៧៥) | (១.០២៥.១៤៨) | (៤.១៨៩.៧៨០) |
| ចំណាយទូទៅ និងចំណាយរដ្ឋបាល | ២៦ | (១.៣៦៦.៣២០) | (៥.៦១៥.៥៧៥) | (៩២៩.៧៩៩) | (៣.៨០០.០៨៩) |
| **ខាតមុនបង់ពន្ធលើប្រាក់ចំណូល** | | (១៩២.៩០៣) | (៧៩២.៨៣២) | (១០០.៤១៥) | (៤១០.៣៩៧) |
| (ចំណាយ)/អត្ថប្រយោជន៍ពន្ធលើប្រាក់ចំណូល | ១៥.២ | (៧៩.៤៨៨) | (៣២៦.៦៩៦) | ៥១០.៨៤៨ | ២.០៨៧.៨៣៦ |
| **(ខាត)/ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | (២៧២.៣៩១) | (១.១១៩.៥២៨) | ៤១០.៤៣៣ | ១.៦៧៧.៤៣៩ |
| **ចំណូល/(ខាត)លម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៦.៣៤៧.២៨៦) | - | ១២.២២៨.៤៥៣ |
| **(ខាត)/ចំណូលលម្អិតសរុបក្នុងការិយបរិច្ឆេទ** | | **(២៧២.៣៩១)** | **(៧.៤៦៦.៨១៤)** | **៤១០.៤៣៣** | **១៣.៩០៥.៨៩២** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដើមទុន | វិភាគទានពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខាតបង្គរ | ទុនបម្រុង បទប្បញ្ញត្តិ | លម្អៀងពី ការប្តូរ រូបិយប័ណ្ណ | មូលធនសរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | ដុល្លារអាម៉េរិក | | ពាន់រៀល | ដុល្លារអាម៉េរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ២០០.០០០.០០០ | ១.២៤៦.៨៨២ | (២.៦៨១.៣៦៩) | | ២៣.៤១៩.៣១៣ | ១៩៨.៥៦៥.៥១៣ | ៨១៧.៤៩៤.២១៧ |
| ខាតសុទ្ធក្នុងការិយបរិច្ឆេទ | - | - | (២៧២.៣៩១) | - | - | (២៧២.៣៩១) | (១.១១៩.៥២៨) |
| ផ្ទេរទៅទុនបម្រុងបទប្បញ្ញត្តិ | - | - | (១.២៥៩.៥៨៤) | ១.២៥៩.៥៨៤ | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៦.៣៤៧.២៨៦ ) | - | (៦.៣៤៧.២៨៦) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **២០០.០០០.០០០** | **១.២៤៦.៨៨២** | **(៤.២១៣.៣៤៤)** | **១.២៥៩.៥៨៤** | **១៧.០៧២.០២៧** | **១៩៨.២៩៣.១២២** | **៨១០.០២៧.៤០៣** |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ១៥០.០០០.០០០ | ១.៣០៨.០៨២ | (៣.០៩១.៨០២) | - | ១១.១៩០.៨៦០ | ១៤៨.២១៦.២៨០ | ៦០៣.៨៣៣.១២៥ |
| ការបញ្ចូលដើមទុន | ៥០.០០០.០០០ | - | - | - | - | ៥០.០០០.០០០ | ២០០.០០០.០០០ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | ៤១០.៤៣៣ | - | - | ៤១០.៤៣៣ | ១.៦៧៧.៤៣៩ |
| ការប្រគល់សងវិភាគទានទៅ MEF | - | (៦១.២០០) | - | - | - | (៦១.២០០) | (២៤៤.៨០០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ១២.២២៨.៤៥៣ | - | ១២.២២៨.៤៥៣ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **២០០.០០០.០០០** | **១.២៤៦.៨៨២** | **(២.៦៨១.៣៦៩)** | **-** | **២៣.៤១៩.៣១៣** | **១៩៨.៥៦៥.៥១៣** | **៨១៧.៤៩៤.២១៧** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។



# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | សម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាម៉េរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាម៉េរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនបង់ពន្ធលើប្រាក់ចំណូល | | (១៩២.៩០៣) | (៧៩២.៨៣២) | (១០០.៤១៥) | (៤១០.៣៩៧) |
| **និយ័តកម្មសម្រាប់៖** | | | | | |
| សំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក | ៩ | ៣.៥១៧.២៥៨ | ១៤.៤៥៥.៩៣២ | ២.០២៨.៦០៧ | ៨.២៩០.៩១៧ |
| ចំណាយការប្រាក់លើប្រាក់កម្ចី | ១៨ | ១.៥៤៧.៥៣៩ | ៦.៣៦០.៣៨៥ | | |
| រំលស់លើទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី | ២៥ | ១.២៤៧.៩៥០ | ៥.១២៩.០៧៥ | ១.០២៥.១៤៨ | ៤.១៨៩.៧៨០ |
| ការវាយតម្លៃរូបិយប័ណ្ណឡើងវិញលើប្រាក់កម្ចី | ១៨ | ៥៧៩.៨០៩ | ២.៣៨៣.០១៥ | - | - |
| ចំណេញលើការប្តូររូបិយប័ណ្ណបរទេសដែលមិនបានទទួលស្គាល់ | | ៣២១.៤៤៩ | ១.៣២១.១៥៥ | ៧៦.៦៣៩ | ៣១៣.២២៤ |
| ចំណាយការប្រាក់លើបំណុលភតិសន្យា | ១៣ | ៥២.០២២ | ២១៣.៨១០ | ២៤.២៦៤ | ៩៩.១៦៧ |
| **ចំណេញប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល** | | ៧.០៧៣.១២៤ | ២៩.០៧០.៥៤០ | ៣.០៥៤.២៤៣ | ១២.៤៨២.៦៩១ |
| **បម្រែបម្រួលទុនបង្វិល** | | | | | |
| **បម្រែបម្រួលសុទ្ធក្នុង៖** | | | | | |
| ប្រាក់តម្កល់តាមបទប្បញ្ញត្តិ | | (១៦.៣០៧) | (៦៧.០២២) | (២៩៩.០១៩) | (១.២២២.០៩១) |
| ឥណទាន និងបុរេប្រទានជូនអតិថិជន-សុទ្ធ | | (៤.៩៥០.១៧៩) | (២០.៣៤៥.២៣៦) | (១០៣.២១៧.៨៨៨) | (៤២១.៨៥១.៥០៨) |
| ប្រាក់បញ្ញើពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ | | ៣.៣៩៤ | ១៣.៩៤៩ | ៣៣.៦២២ | ១៣៧.៤១៣ |
| ប្រាក់បញ្ញើពីអតិថិជន | | (៦៩៥.៦៦៤) | (២.៨៥៩.១៧៩) | ៤.១៥៥.៥៤៤ | ១៦.៩៨៣.៧០៨ |
| ទ្រព្យសកម្មផ្សេងៗ | | (៥២៩.៨០៧) | (២.១៧៧.៥០៧) | (២២៩.៤៣៦) | (៩៣៧.៧០៥) |
| បំណុលផ្សេងៗ | | (២០១.១៥៤) | (៨២៦.៧៤៣) | ៥១៥.១៨៤ | ២.១០៥.៥៥៧ |
| **សាច់ប្រាក់បានពី/(បានប្រើ) ក្នុងសកម្មភាពប្រតិបត្តិការ** | | ៦៨៣.៤០៧ | ២.៨០៨.៨០២ | (៩៥.៩៨៧.៧៥០) | (៣៩២.៣០១.៩៣៥) |
| ពន្ធលើប្រាក់ចំណូលបានបង់ | ១៥.១ | (៣៣៦.៩៨៤) | (១.៣៨៥.០០៤) | (៦៦.៩៤១) | (២៧៣.៥៨៨) |
| **សាច់ប្រាក់សុទ្ធបានពី/(បានប្រើ) ក្នុងសកម្មភាពប្រតិបត្តិការ** | | ៣៤៦.៤២៣ | ១.៤២៣.៧៩៨ | (៩៦.០៥៤.៦៩១) | (៣៩២.៥៧៥.៥២៣) |

# របាយការណ៍លំហូរសាច់ប្រាក់ (ត)

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | សម្រាប់ដំណាច់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាម៉េរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) | ដុល្លារអាម៉េរិក | ពាន់រៀល (កំណត់សម្គាល់ ៤.២) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពវិនិយោគ** | | | | | |
| ប្រាក់តម្កល់ក្នុងប្រាក់បញ្ញើរយៈពេលខ្លី | ៨ | (៨.១៦៩.៥២៩) | (៣៣.៥៧៦.៧៦៤) | (១៧.២៥៣.១៦៣) | (៧០.៥១៣.៦៧៧) |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | (៩១៥.៩៧៦) | (៣.៧៦៤.៦៦១) | (១.៥២៧.៦៤៤) | (៦.២៤៣.៤៨១) |
| ទិញទ្រព្យសកម្មអរូបី | ១១ | (១៤៧.៩១៣) | (៦០៧.៩២២) | (៧៨.១៥៤) | (៣១៩.៤១៥) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (៩.២៣៣.៤១៨) | (៣៧.៩៤៩.៣៤៧) | (១៨.៨៥៨.៩៦១) | (៧៧.០៧៦.៥៧៣) |
| **លំហូរសាច់ប្រាក់បានពីសកម្មភាពហិរញ្ញវត្ថុ** | | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១៨ | ៤១.៤៦៧.០៨២ | ១៧០.៤២៩.៧០៧ | ៧៤.០១៦.២៧៤ | ៣០២.៥០៤.៥១២ |
| ការប្រាក់បានទូទាត់លើប្រាក់កម្ចី | ១៨ | (១.០៩៩.១៣១) | (៤.៥១៧.៤២៩) | - | - |
| ការទូទាត់បំណុលភតិសន្យា | ១៣ | (៣៤២.៧៥៥) | (១.៤០៨.៧២៣) | (២៣៣.៧៦៨) | (៩៥៥.៤១០) |
| ការប្រគល់សងវិភាគទានទៅ MEF | ២១ | - | - | (៦១.២០០) | (២៥០.១២៤) |
| សាច់ប្រាក់បានពីដើមទុនបន្ថែម | ២០ | - | - | ៥០.០០០.០០០ | ២០៤.៣៥០.០០០ |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញវត្ថុ** | | ៤០.០២៥.១៩៦ | ១៦៤.៥០៣.៥៥៥ | ១២៣.៧២១.៣០៦ | ៥០៥.៦៤៨.៩៧៨ |
| **ការកើនឡើងក្នុងសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ៣១.១៣៨.២០១ | ១២៧.៩៧៨.០០៦ | ៨.៨០៧.៦៥៤ | ៣៥.៩៩៦.៨៨២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល ដើមការិយបរិច្ឆេទ | | ៤៤.១៣២.៣៦៧ | ១៨១.៦៩២.៩៥៥ | ៣៥.៣២៤.៧១៣ | ១៤៣.៩១២.៨៨១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (២.១៩០.៦៩០) | - | ១.៧៨៣.១៩២ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលចុងការិយបរិច្ឆេទ** | ៦ | ៧៥.២៧០.៥៦៨ | ៣០៧.៤៨០.២៧១ | ៤៤.១៣២.៣៦៧ | ១៨១.៦៩២.៩៥៥ |
| *ព័ត៌មានបន្ថែមលើលំហូរសាច់ប្រាក់ប្រតិបត្តិការពីការប្រាក់៖* | | | | | |
| ការប្រាក់បានទទួល | | ១០.២៥២.៧១១ | ៤២.១៣៨.៦៤២ | ៥.៧២៩.៦៦៤ | ២៣.៤១៧.១៣៧ |
| **ការប្រាក់បានបង់** | | **១.៦០៦.៣៨៧** | **៦.៦០២.២៥១** | **២៥.៥១២** | **១០៤.២៦៨** |

កំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។



# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

## ១. ព័ត៌មានសាជីវកម្ម

ធនាគារត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាធនាគារគ្រប់គ្រងដោយរដ្ឋ ដែលរៀបចំឡើងក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co 000១ M/២០២០ ដែលបានចេញផ្សាយដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ ធនាគារស្ថិតនៅក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)។

ធនាគារទទួលបានអាជ្ញាបណ្ណរបស់ខ្លួនពីធនាគារជាតិ នៃ កម្ពុជា (“NBC”) នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីធ្វើប្រតិបត្តិការជាធនាគារពាណិជ្ជ។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្តល់ហិរញ្ញប្បទាន និងសេវាធនាគារពាណិជ្ជ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្លូវអូស៊ីអាយស៊ី ភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ធនាគារមាននិយោជិតចំនួន ២២២នាក់ (ឆ្នាំ២០២២៖ មាននិយោជិតចំនួន ១៤៤នាក់)។

## ២. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ដែលអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា

របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“CIFRSs”)។

និយ័តករគណនេយ្យ និងសវនកម្ម បានចេញប្រកាស (សារាចរ) លេខ ០៦៨-សហវ ប្រ.ក ចុះនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ដែលបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃកម្ពុជា លើការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជាបានសម្រេចឱ្យអនុវត្តពេញលេញលើស្តង់ដាស្តីពីរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ (“IFRS”) ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (“IASB”) ដោយមិនមានការកែប្រែលើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាឡើយ។

## ៣. ស្តង់ដាដែលបានកែសម្រួល និងការបកស្រាយ

### ៣.១ វិសោធនកម្ម និងការបកស្រាយទៅលើស្តង់ដាដែលមានស្រាប់ដែលចូលជាធរមានគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

ធនាគារបានអនុវត្តនូវស្តង់ដាគណនេយ្យ និងការបកស្រាយទាំងអស់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ ស្តង់ដាគណនេយ្យដែលបានកែសម្រួលត្រូវបានវាយតម្លៃថាអាចអនុវត្តបាន ហើយមិនមានផលប៉ះពាល់ជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានដូចខាងក្រោម៖

- ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការតែមួយ (វិសោធនកម្មទៅលើ CIAS ១២ ពន្ធលើប្រាក់ចំណូល)

  *ក្រុមប្រឹក្សាភិបាលស្តង់ដាគណនេយ្យអន្តរជាតិ (“IASB”) ធ្វើវិសោធនកម្មលើ CIAS ១២ ដើម្បីផ្តល់នូវការលើកលែងបន្ថែមពីការលើកលែងលើការទទួលស្គាល់ដំបូង។ ស្ថិតក្រោមវិសោធនកម្ម អង្គភាព ដែលមិនអនុវត្តការលើកលែងពីការទទួលស្គាល់ដំបូងទៅលើប្រតិបត្តិការដែលបណ្តាលឱ្យមានការជាប់ពន្ធដូចគ្នា និងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន។ ផ្អែកតាមច្បាប់ពន្ធដែលអាចអនុវត្តបាន ការជាប់ពន្ធដូចគ្នា និងភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន អាចកើតឡើងលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងប្រតិបត្តិការដែលមិនមែនជាការរួមបញ្ចូលអាជីវកម្ម ហើយមិនប៉ះពាល់ដល់ទាំងគណនេយ្យ ឬប្រាក់ចំណេញជាប់ពន្ធឡើយ។ ឧទាហរណ៍ វាអាចកើតឡើងនៅពេលទទួលស្គាល់បំណុលភតិសន្យា និងសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មដែលស្របគ្នាទៅនឹងការអនុវត្ត CIFRS ១៦ ភតិសន្យា នាកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ បន្ទាប់ពីការធ្វើវិសោធនកម្មលើ CIAS ១២ អង្គភាពដែលត្រូវបានតម្រូវឱ្យទទួលស្គាល់ទ្រព្យសកម្ម និងបំណុលពន្ធពន្យារដែលពាក់ព័ន្ធជាមួយនឹងការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារដែលស្ថិតនៅក្រោមលក្ខខណ្ឌនិទិដ្ឋិយនៃការស្តារឡើងវិញនៅក្នុង CIAS ១២។*

- ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មទៅលើ CIAS ១ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ និងការអនុវត្តរបាយការណ៍ CIFRS ២)

  *វិសោធនកម្មតម្រូវឱ្យអង្គភាពបង្ហាញនូវគោលការណ៍គណនេយ្យជាសារវន្ត សម្រាប់ជំនួសឱ្យគោលនយោបាយគណនេយ្យសំខាន់ៗរបស់ខ្លួន។ វិសោធនកម្មបន្ថែមពន្យល់ពីរបៀបដែលអង្គភាពអាចកំណត់អត្តសញ្ញាណគោលនយោបាយគណនេយ្យជាសារវន្ត។ ឧទាហរណ៍នៅពេលដែលគោលនយោបាយគណនេយ្យទំនងជាត្រូវបានបន្ថែមជាសារវន្ត។ ដើម្បីគាំទ្រដល់ការធ្វើវិសោធនកម្ម IASB ក៏បានអភិវឌ្ឍន៍ការណែនាំ និងបង្ហាញនូវការអនុវត្តជា ‘ដំណើរការជាសារវន្ត៤ជំហាន’ដែលបានពិពណ៌នាក្នុងការអនុវត្តរបាយការណ៍ CIFRS ២។*

- និយមន័យគណនេយ្យប៉ាន់ស្មាន (វិសោធនកម្មទៅលើ CIAS ៨ គោលនយោបាយគណនេយ្យ បម្រែបម្រួលក្នុងគណនេយ្យប៉ាន់ស្មាន និងកំហុសឆ្គង)

  *ការធ្វើវិសោធនកម្មជំនួសឱ្យនិយមន័យនៃបម្រែបម្រួលគណនេយ្យប៉ាន់ស្មានជាមួយនឹងនិយមន័យគណនេយ្យប៉ាន់ស្មាន។ នៅក្រោមនិយមន័យថ្មី គណនេយ្យប៉ាន់ស្មាន គឺជា "សមតុល្យរូបិយវត្ថុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលស្ថិតក្រោមការវាស់វែងមិនជាក់លាក់"។ អង្គភាពបង្កើតគណនេយ្យប៉ាន់ស្មាន ប្រសិនបើគោលនយោបាយគណនេយ្យតម្រូវឱ្យធាតុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរបៀបដែលពាក់ព័ន្ធនឹងការវាស់វែងមិនជាក់លាក់ទាំងនោះ។ វិសោធនកម្មបញ្ជាក់យ៉ាងច្បាស់ថា បម្រែបម្រួលគណនេយ្យប៉ាន់ស្មានដែលកើតចេញពីព័ត៌មានថ្មី ឬការអភិវឌ្ឍថ្មី មិនមែនជាការកែតម្រូវកំហុសឆ្គងនោះទេ។*

  *ការអនុវត្តវិសោធនកម្មទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ស្ថិតក្រោមកំណត់សម្គាល់ ៤និង៥។*

### ៣.២ ស្តង់ដារគណនេយ្យដែលបានធ្វើវិសោធនកម្ម ដែលមិនទាន់ចូលជាធរមានហើយមិនទាន់បានអនុវត្តជាមុនដោយធនាគារ

នាកាលបរិច្ឆេទនៃការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ស្តង់ដាថ្មី និងស្តង់ដាដែលបានកែសម្រួលឡើងវិញដែលបានចេញផ្សាយ ប៉ុន្តែមិនទាន់មានប្រសិទ្ធភាព ហើយមិនទាន់បានអនុវត្តជាមុនដោយធនាគារ មានដូចខាងក្រោម៖

- ការធ្វើចំណាត់ថ្នាក់លើបំណុលរយៈពេលខ្លី ឬរយៈពេលវែង (វិសោធនកម្មទៅលើ CIAS ១)
- កិច្ចព្រមព្រៀងលើបំណុលរយៈពេលវែង (វិសោធនកម្មទៅលើ CIAS ១)
- កង្វះខាតលទ្ធភាពក្នុងការផ្លាស់ប្តូរ (វិសោធនកម្មទៅលើ CIAS ២១ ផលប៉ះពាល់នៃការផ្លាស់ប្តូរអត្រាប្តូររូបិយប័ណ្ណបរទេស)
- បំណុលភតិសន្យាក្នុងការលក់ និងការជួលបន្ត (វិសោធនកម្មទៅលើ CIFRS ១៦)
- ការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់ (វិសោធនកម្មទៅលើ CIAS ៧ និង CIFRS ៧)

ការធ្វើវិសោធនកម្មទាំងនេះ មិនត្រូវបានរំពឹងទុកថានឹងបង្កឱ្យមានផលប៉ះពាល់សំខាន់ៗទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារក្នុងកាលបរិច្ឆេទនៃការអនុវត្តដំបូង ដូច្នេះហើយពុំមានការលាតត្រដាងនោះទេ។

## ៤. ព័ត៌មានគោលនយោបាយគណនេយ្យជាសារវន្ត

### ៤.១ មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលបានបង្ហាញជាប្រាក់ដុល្លារអាម៉េរិក(“USD”) ត្រូវបានរៀបចំឡើងតាមមូលដ្ឋានថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ៤.២ រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

***រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ***

សមាសធាតុដែលបានរាប់បញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិបទសេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តិការ (“រូបិយប័ណ្ណមុខងារ”)។ ប្រាក់ដុល្លារអាម៉េរិកឆ្លុះបញ្ចាំងសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញក្នុងប្រាក់ដុល្លារអាម៉េរិកដែលជារូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

***ប្រតិបត្តិការ និងសមតុល្យ***

ប្រតិបត្តិការជារូបិយវត្ថុបរទេស ក្រៅពីប្រាក់ដុល្លាអាម៉េរិកត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាម៉េរិកក្នុងអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេស ជាលទ្ធផលពីការទូទាត់ប្រតិបត្តិការ និងពីការប្តូរទ្រព្យសកម្ម និងបំណុលជារូបិយវត្ថុកំណត់ដោយរូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាម៉េរិកនាចុងការិយបរិច្ឆេទនៃអត្រាប្តូរប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

***ការបង្ហាញជាប្រាក់រៀលខ្មែរ***

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាម៉េរិកទៅជាពាន់រៀល (“KHR’000”) ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ចុងគ្រា និងមធ្យមក្នុងការិយបរិច្ឆេទនោះ។

ទ្រព្យសកម្ម និងបំណុលដែលបានដាក់បង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ត្រូវបានប្តូរទៅជាប្រាក់រៀលខ្មែរ (“KHR”) ដោយប្រើអត្រាប្តូរប្រាក់ចុងគ្រានៃរបាយការណ៍នីមួយៗ ស្របពេលដែលចំណូល និងចំណាយសម្រាប់របាយការណ៍ចំណូលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់នីមួយៗ ត្រូវបានប្តូរទៅជាប្រាក់រៀលខ្មែរដោយប្រើអត្រាប្តូរប្រាក់ជាមធ្យមសម្រាប់ដំណាច់ការិយបរិច្ឆេទដែលបានបញ្ចប់។ រាល់ភាពលម្អៀងពីការប្តូរប្រាក់ផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងចំណូលលម្អិតផ្សេងៗ។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាម៉េរិកទៅជាខ្មែររៀល ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលទាំងស្រុងដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ និងត្រូវបានធ្វើឡើងដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដោយយោងទៅតាមអត្រាប្តូរប្រាក់ក្នុង ១ ដុល្លារអាម៉េរិកដែលបានចេញសេចក្តីប្រកាសដោយធនាគារជាតិ នៃ កម្ពុជា (“NBC”)៖

| | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|
| អត្រាប្តូរប្រាក់ចុងគ្រា | ៤.០៨៥ | ៤.១១៧ |
| អត្រាប្តូរប្រាក់ជាមធ្យម* | ៤.១១០ | ៤.០៨៧ |

*អត្រាប្តូរប្រាក់ជាមធ្យមត្រូវបានគណនាដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាមធ្យមប្រចាំថ្ងៃរបស់ធនាគារជាតិ នៃ កម្ពុជា

សមតុល្យសាច់ប្រាក់ដែលប្តូរដូចបានរៀបរាប់នេះ មិនត្រូវបានធ្វើសវនកម្មឡើយ និងមិនមែនជាមូលដ្ឋានសម្រាប់ការបកស្រាយថាចំនួនទឹកប្រាក់ជាប្រាក់ដុល្លារអាម៉េរិកនឹងអាចប្តូរទៅជាប្រាក់រៀលនៅថ្ងៃអនាគត ក្រោមអត្រាប្តូរប្រាក់ដដែល ឬអត្រាប្តូរប្រាក់ផ្សេងទៀតឡើយ។

## ៤.៣ ការបង្គត់សមតុល្យ

លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ សមតុល្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្គត់ត្រឹមសមតុល្យប្រាក់ដុល្លារអាម៉េរិកសម្រាប់សមតុល្យសាច់ប្រាក់ដុល្លារអាម៉េរិកនិងពាន់រៀលសម្រាប់សមតុល្យសាច់ប្រាក់ខ្មែររៀល ដែលនៅកៀកបំផុត។

## ៤.៤ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យមិនរឹតត្បិតនៅធនាគារជាតិ នៃ កម្ពុជា សមតុល្យនៅធនាគារផ្សេង និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមានសទ្ធនីយភាពខ្ពស់ដែលមានកាលកំណត់៣ខែ ឬតិចជាង ចាប់ពីកាលបរិច្ឆេទនៃការទិញដែលស្ថិតក្រោមឥទ្ធិពលមិនមែនជាសារវន្តនៃការផ្លាស់ប្តូរតម្លៃសមស្រប ហើយត្រូវបានប្រើប្រាស់ដោយធនាគារក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លីរបស់ខ្លួន។

## ៤.៥ ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ធនាគាររួមមាន សាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារជាតិ នៃ កម្ពុជា សមតុល្យនៅធនាគារផ្សេង ឥណទាន និងបុរេប្រទានទៅអតិថិជន ទ្រព្យសកម្មផ្សេងៗ (លើកលែងតែប្រាក់បញ្ញើដែលមិនអាចបង្វិលមកវិញ និងចំណាយបង់មុន) ប្រាក់បញ្ញើពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប្រាក់បញ្ញើពីអតិថិជន ប្រាក់កម្ចី និងបំណុលផ្សេងៗ (លើកលែងតែពន្ធត្រូវបង់) ដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់តាមគំរូអាជីវកម្មដែលបានពិភាក្សាក្នុងកំណត់សម្គាល់លេខ ៤.៥.១។



### *ការទទួលស្គាល់ និងការវាស់វែងលើកដំបូង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារនៅពេលដែលធនាគារក្លាយជាភាគីនៃកិច្ចសន្យាសំវិធានធនរបស់ឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃសមស្រប។ ថ្លៃដើមប្រតិបត្តិការដែលដែលបែងចែកដោយផ្ទាល់ក្នុងការទិញ ឬបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ក្រៅពីទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុតាមតម្លៃសមស្របតាមរយៈគណនីចំណេញ ឬខាត) ត្រូវបានបន្ថែម ឬកាត់កងពីតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ តាមភាពត្រឹមត្រូវលើការទទួលស្គាល់លើកដំបូង។

ប្រសិនបើថ្លៃប្រតិបត្តិការខុសពីតម្លៃសមស្របតាមការទទួលស្គាល់លើកដំបូង នោះធនាគារនឹងកំណត់នូវភាពខុសគ្នាដូចខាងក្រោម៖

- ប្រសិនបើតម្លៃសមស្របត្រូវបានគាំទ្រដោយតម្លៃសម្រង់ក្នុងទីផ្សារសកម្មដើម្បីកំណត់អត្តសញ្ញាណទ្រព្យសកម្ម ឬបំណុល ឬផ្អែកលើការវាយតម្លៃបច្ចេកទេសដែលប្រើប្រាស់តែទិន្នន័យដែលបានពីទីផ្សារដែលអាចអង្កេតបាននោះទេ ហើយភាពខុសគ្នាត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតលើការទទួលស្គាល់លើកដំបូង (ឧទាហរណ៍ មួយថ្ងៃជាចំណេញ ឬខាត) និង
- ក្នុងករណីផ្សេងទៀត តម្លៃសមស្របនឹងត្រូវបានកែសម្រួលដើម្បីនាំយកតម្លៃសមស្របទាំងនោះជាមួយនឹងថ្លៃដើមប្រតិបត្តិការ (ឧទាហរណ៍ មួយថ្ងៃជាចំណេញ ឬខាតនឹងខុសគ្នាដោយធ្វើការរាប់បញ្ចូលតម្លៃសមស្របនោះក្នុងសមតុល្យយោងលើកដំបូងនៃទ្រព្យសកម្ម ឬបំណុល)។

### ៤.៥.១ គំរូអាជីវកម្ម

ធនាគារវាស់វែងសមតុល្យនៅធនាគារជាតិ នៃ កម្ពុជា សមតុល្យនៅធនាគារផ្សេង ឥណទាន និងបុរេប្រទានទៅអតិថិជន និងទ្រព្យសកម្មផ្សេងៗ (លើកលែងតែប្រាក់បញ្ញើដែលមិនអាចបង្វិលមកវិញបាន និងចំណាយបង់មុន) តាមថ្លៃដើមបានរំលស់ដោយផ្អែកលើគំរូអាជីវកម្ម ឬការគ្រប់គ្រងកាលកំណត់កិច្ចសន្យារបស់ទ្រព្យសកម្ម នៅពេលដែលលក្ខខណ្ឌបានបំពេញដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកាន់កាប់តាមគំរូអាជីវកម្មដែលមានគោលបំណងកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកំណត់កាលបរិច្ឆេទជាក់លាក់នៃលំហូរសាច់ប្រាក់គឺជាការទូទាត់ប្រាក់ដើម និងការប្រាក់ (“SPPI”) ទៅតាមចំនួនប្រាក់ដើមដែលនៅសល់ ។

ព័ត៌មានលម្អិតនៃលក្ខខណ្ឌទាំងនេះ ត្រូវបានបង្ហាញដូចខាងក្រោម។

ធនាគារធ្វើការវាយតម្លៃគោលបំណងនៃគំរូអាជីវកម្មដែលទ្រព្យសកម្មត្រូវបានកាន់កាប់តាមកម្រិតសម្ពាធហ្វាស៊ីលីធីដែលឆ្លុះបញ្ចាំងពីវិធីដែលទ្រព្យសកម្មត្រូវបានគ្រប់គ្រង។ កត្តាដែលត្រូវបានពិចារណា រួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានចែងសម្រាប់សម្ពាធហ្វាស៊ីលីធី និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្រ្តរបស់អ្នកគ្រប់គ្រងផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យារក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសម្ពាធហ្វាស៊ីលីធី និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ធនាគារ

- ហានិភ័យដែលជះឥទ្ធិពលដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងកាលបរិច្ឆេទមុន មូលហេតុនៃការលក់ទាំងនោះ និងការរំពឹងទុកអំពីសកម្មភាពនៃការលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពនៃការលក់មិនត្រូវបានយកមកពិចារណាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទាំងមូលនៃវិធីសាស្ត្រដែលធនាគារបានចែងអំពីគោលបំណងសម្រាប់សម្រេចបានការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងវិធីសាស្ត្រក្នុងការទទួលស្គាល់លំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលកាន់កាប់សម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនទុកសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនទុកសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

## ៤.៥.២ ការធ្វើតេស្តការទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”)

ជាជំហានទី២នៃដំណើរការក្នុងការធ្វើចំណាត់ថ្នាក់ ធនាគារវាយតម្លៃកាលកំណត់កិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុដើម្បីកំណត់អត្តសញ្ញាណថាតើដំណើរការនោះបំពេញនូវការធ្វើតេស្ត SPPI។

សម្រាប់គោលបំណងនៃការវាយតម្លៃនេះ ‘ប្រាក់ដើម’ គឺជាតម្លៃសមស្របរបស់ទ្រព្យសកម្មហិរញ្ញវត្ថុលើការទទួលស្គាល់ដំបូង។ ‘ការប្រាក់’ គឺជាតម្លៃតបស្នងលើតម្លៃពេលវេលានៃទឹកប្រាក់ និងហានិភ័យឥណទានដែលទាក់ទងនឹងចំនួនទឹកប្រាក់ដើមដែលនៅសល់ក្នុងអំឡុងពេលជាក់លាក់ណាមួយ និងហានិភ័យជាមូលដ្ឋានផ្សេងទៀតនៃការផ្តល់ប្រាក់កម្ចី និងចំណាយ (ឧទាហរណ៍ ហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) ក៏ដូចជាគម្លាតនៃប្រាក់ចំណេញ។

ក្នុងការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជា SPPI ធនាគារពិចារណាលើលក្ខខណ្ឌកិច្ចសន្យានៃឧបករណ៍នោះ។ វារួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញតាមលក្ខខណ្ឌនេះបាន។

ក្នុងការវាយតម្លៃ ធនាគារពិចារណាទៅលើ៖

- ព្រឹត្តិការណ៍ជាយថាហេតុដែលអាចផ្លាស់ប្តូរចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសជាអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារក្នុងការទាមទារមកវិញនូវលំហូរសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជា ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមរយៈពេលកំណត់)។



### *ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់*

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយធនាគារ ដែលត្រូវបានធានាដោយទ្រព្យដាក់បញ្ចាំពីអតិថិជនបានកម្រិតធនាគារក្នុងការទាមទារលំហូរសាច់ប្រាក់របស់ទ្រព្យដាក់បញ្ចាំ (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ក្នុងករណីនេះ ធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះបំពេញតាមលក្ខខណ្ឌទូទាត់តែប្រាក់ដើម និងការប្រាក់ដែរឬទេ។ ជាទូទៅ ធនាគារពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃសំណងឥណទានដែរឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជនក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជន គឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស
- ហានិភ័យរបស់ធនាគារនៃការបាត់បង់ទ្រព្យសកម្មទាក់ទងនឹងឥណទានដែលមានទ្រព្យដាក់បញ្ចាំពេញលេញ
- វិសាលភាពដែលទ្រព្យដាក់បញ្ចាំបង្ហាញពីទ្រព្យសកម្មរបស់អតិថិជនទាំងអស់ ឬជាផ្នែកណាមួយ និង
- ថាតើធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនតម្លៃនៃទ្រព្យសកម្មនេះឬទេ។

### *ការធ្វើចំណាត់ថ្នាក់ឡើងវិញនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់លើកដំបូងឡើយ លើកលែងតែក្នុងកាលបរិច្ឆេទបន្ទាប់ពីធនាគារផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួនក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

## ៤.៥.៣ ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

### *ទ្រព្យសកម្មហិរញ្ញវត្ថុ*

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលរាល់ហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរ ឬក្នុងករណីដែលសម្ព័ន្ធធនាគារ និងធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវហានិភ័យ និងផលចំណេញស្ទើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាអភិបាលភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុឡើយ។

ការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងសមតុល្យយោងរបស់ទ្រព្យសកម្ម (ឬសមតុល្យយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលបានទទួលយក) និង (ii) ចំណេញ ឬខាតសរុបបង្គរ ដែលបានទទួលស្គាល់ក្នុងចំណូលលម្អិតផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងគណនីចំណេញ ឬខាត។

### *បំណុលហិរញ្ញវត្ថុ*

បំណុលហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ នៅពេលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានបោះបង់ចោល ឬត្រូវបានលុបចោល ឬផុតកាលកំណត់។ នៅពេលដែលបំណុលហិរញ្ញវត្ថុមានស្រាប់ ត្រូវបានជំនួសដោយបំណុលហិរញ្ញវត្ថុផ្សេងទៀតពីអ្នកឱ្យខ្ចីតែមួយលើលក្ខខណ្ឌផ្សេងគ្នា ឬលក្ខខណ្ឌនៃបំណុលដែលមានស្រាប់

ត្រូវបានកែប្រែបន្តបន្ទាប់ នោះការប្តូរ ឬការកែប្រែត្រូវបានចាត់ទុកថាជាការឈប់ទទួលស្គាល់បំណុលដើម និងទទួលស្គាល់បំណុលថ្មី។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដើម និងតម្លៃតបស្នងដែលបានបង់ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត។

### ៤.៥.៤ ការកែប្រែ និងការពន្យារពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែ គឺមានភាពខុសគ្នាខ្លាំង។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំងនោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកាលកំណត់។ ក្នុងករណីនេះ ទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានឈប់ទទួលស្គាល់ ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានកត់ត្រាដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលតំណាងឱ្យសំណងនៃចំណាយប្រតិបត្តិការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងលើកដំបូងនៃទ្រព្យសកម្ម និងថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើការឈប់ទទួលស្គាល់។ ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមានៃលក្ខខណ្ឌតាមកិច្ចសន្យាដើមជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះត្រូវពិចារណាជាដំបូងថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជី មុនពេលធ្វើការកែប្រែកើតឡើងដែរឬទេ (សូមមើលគោលនយោបាយការលុបចេញពីបញ្ជីខាងក្រោម)។ វិធីសាស្ត្រនេះមានផលប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ជាធម្មតាមិនបានបំពេញករណីទាំងនេះទេ។
- ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ ឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាតនៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការធ្វើការកែប្រែពីការកែតម្រូវតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធ្វើការកែប្រែ និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែនោះ និង
- ប្រសិនបើការកែប្រែនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃរបស់ទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត ត្រូវបានបង្ហាញជាចំណូលការប្រាក់ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព។



### ៤.៥.៥ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុអាចកាត់កងគ្នាបាន និងត្រូវបង្ហាញជាសមតុល្យសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនៅពេល ឬតែនៅពេលដែលធនាគារមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏លក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

### ៤.៥.៦ ការវាស់វែងតម្លៃសមស្រប

'តម្លៃសមស្រប' គឺជាតម្លៃដែលត្រូវទទួលដើម្បីលក់ទ្រព្យសកម្ម ឬទូទាត់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការតាមលំដាប់រវាងអ្នកចូលរួមទីផ្សារនាកាលបរិច្ឆេទនៃការវាស់វែងជាចម្បង ឬក្នុងករណីដែលមិនមានទីផ្សារ ហើយទីផ្សារដែលមានអត្ថប្រយោជន៍បំផុតដែលធនាគារមានសិទ្ធិប្រើប្រាស់នាកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលដែលឆ្លុះបញ្ចាំងពីហានិភ័យមិនមានប្រតិបត្តិការ។

នៅពេលមានតម្លៃសមស្រប ធនាគារវាស់វែងតម្លៃសមស្របនៃឧបករណ៍ដោយប្រើតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្មសម្រាប់ឧបករណ៍ នោះ។ ទីផ្សារត្រូវបានចាត់ទុកថា ‘សកម្ម’ ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលកើតឡើងជាមួយនឹងភាពញឹកញាប់ និងបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃតាមមូលដ្ឋាននិរន្តរភាព។

ប្រសិនបើមិនមានការដកស្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារប្រើបច្ចេកទេសវាយតម្លៃដែលបង្កើនការប្រើប្រាស់ធាតុចូល ដែលអាច សង្កេតបាន និងបង្រួមអប្បបរមានៃការប្រើប្រាស់ធាតុចូលដែលមិនអាចសង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូល កត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុនៅលើការទទួលស្គាល់ដំបូង គឺតម្លៃប្រតិបត្តិការឧទាហរណ៍ តម្លៃសមស្របរបស់តម្លៃតបស្នងដែលបានផ្តល់ឱ្យ ឬទទួលបាន។ ប្រសិនបើធនាគារកំណត់ថាតម្លៃសមស្របលើការទទួលស្គាល់ដំបូងខុសគ្នាពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្រប មិនត្រូវបានបង្ហាញដោយតម្លៃដែលបានដកស្រង់នៅក្នុងទីផ្សារសកម្ម សម្រាប់កំណត់អត្តសញ្ញាណទ្រព្យសកម្ម ឬបំណុលដូចគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃសម្រាប់ធាតុចូលណាមួយដែលមិនអាចអង្កេតបានដែលត្រូវវិនិច្ឆ័យថាមិនមានទំនាក់ទំនងក្នុងការវាស់វែងដែលមិនគួរឱ្យកត់សម្គាល់ បន្ទាប់មកឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប និងបានកែប្រែដើម្បីបម្លែងភាពខុសគ្នារវាងតម្លៃសមស្របចំពោះការទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ និងខាតលើមូលដ្ឋានដែលត្រឹមត្រូវលើអាយុកាលនៃឧបករណ៍ ប៉ុន្តែមិនលើសពីអាយុកាលប្រើប្រាស់ទេ នៅពេលដែលធ្វើការវាយតម្លៃត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬប្រតិបត្តិការដែលត្រូវបានលុបចោល។

ប្រសិនបើទ្រព្យសកម្ម ឬបំណុល ដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃស្នើទិញ និងតម្លៃដេញថ្លៃ នោះធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពរយៈពេលវែងក្នុងតម្លៃស្នើទិញ និងបំណុលព្រមទាំងស្ថានភាពរយៈពេលខ្លីតាមតម្លៃដេញថ្លៃ។

ផលបត្រនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានប្រឈមនឹងហានិភ័យទីផ្សារ និងហានិភ័យឥណទានដែលត្រូវបានគ្រប់គ្រងដោយធនាគារដោយផ្អែកលើមូលដ្ឋានផលប៉ះពាល់សុទ្ធចំពោះហានិភ័យទីផ្សារ ឬហានិភ័យឥណទានត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានតម្លៃដែលនឹងត្រូវបានទទួលដើម្បីលក់ស្ថានភាពរយៈពេលវែងសុទ្ធ (ឬទូទាត់ដើម្បីផ្ទេរស្ថានភាពរយៈពេលខ្លីសុទ្ធ) សម្រាប់

ហានិភ័យជាក់លាក់។ ការកែតម្រូវកម្រិតផលបត្រ ឧទាហរណ៍ ការដេញថ្លៃស្នើសុំការកែតម្រូវ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងដោយឈរលើមូលដ្ឋាននៃការប៉ះពាល់សុទ្ធត្រូវបានបែងចែកជាទ្រព្យសកម្ម និងបំណុលដាច់ដោយឡែក ដោយផ្អែកលើមូលដ្ឋាននៃការកែតម្រូវហានិភ័យដែល ទាក់ទងនឹងឧបករណ៍នីមួយៗនៅក្នុងផលបត្រ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលមានលក្ខណៈតម្រូវ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) មិនតិចជាងសមតុល្យដែលត្រូវបង់តាមតម្រូវការដែលត្រូវបានធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលសមតុល្យអាចតម្រូវឱ្យបង់។

ធនាគារ ទទួលស្គាល់ការផ្ទេររវាងកម្រិតឋានានុក្រមនៃតម្លៃសមស្របនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ក្នុងអំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

### ៤.៥.៧ ការខាតបង់ឥណទានដែលបានរំពឹងទុក (“ECLs”)

ធនាគារទទួលស្គាល់សំវិធានធនសម្រាប់ ECLs លើឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់ដូចខាងក្រោម៖

- សមតុល្យនៅធនាគារផ្សេង
- ឥណទាន និងបុរេប្រទានទៅអតិថិជន និង
- កិច្ចសន្យាឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានចេញផ្សាយ។

ECLs តម្រូវឱ្យវាស់វែងតាមរយៈការខាតបង់សំវិធានធនតាមសមតុល្យដែលស្មើនឹង៖

- ECL ១២ខែ ឧទាហរណ៍ ECL អាយុកាលដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែរបស់ឧបករណ៍ហិរញ្ញវត្ថុមួយដែលអាចកើតឡើងក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការរាយការណ៍ (សំដៅទៅដំណាក់កាលទី១) ឬ
- ECL ពេញមួយអាយុកាល ឧទាហរណ៍ ECL ពេញមួយអាយុកាល ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងអាយុកាលរបស់ឧបករណ៍ហិរញ្ញវត្ថុ (សំដៅទៅដំណាក់កាលទី២ និងដំណាក់កាលទី៣)។

ការខាតបង់សំវិធានធនសម្រាប់ ECL ពេញមួយអាយុកាលត្រូវបានតម្រូវសម្រាប់ឧបករណ៍ហិរញ្ញវត្ថុប្រសិនបើហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុនោះបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូង។ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ECLs ត្រូវបានវាស់វែងក្នុងសមតុល្យស្មើនឹង ECL ១២ខែ។ ព័ត៌មានលម្អិតបន្ថែមអំពីការកំណត់នៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានត្រូវបានផ្តល់ដូចខាងក្រោម។

ECLs គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេជាមធ្យមនៃតម្លៃបច្ចុប្បន្ននៃការខាតបង់ឥណទាន។ ECL ទាំងនេះត្រូវបានវាស់វែងជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដោយសារធនាគារក្រោមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានដែលកើតឡើងពីការថ្លឹងថ្លែងនៃសេណារីយ៉ូសេដ្ឋកិច្ចនាពេលអនាគតជាច្រើនដោយធ្វើអប្បហារនៅ EIR របស់ទ្រព្យសកម្ម។

- សម្រាប់ការសន្យាប្រាក់កម្ចីដែលមិនបានដកចេញ ECL គឺជាភាពខុសគ្នារវាងតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលកើតឡើងដោយសារធនាគារ ប្រសិនបើអ្នកកាន់កាប់ការសន្យាដកប្រាក់កម្ចី និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងថានឹងទទួលបានប្រសិនបើប្រាក់កម្ចីត្រូវបានដកចេញ និង



- សម្រាប់កិច្ចសន្យាធានាហិរញ្ញវត្ថុ ECL គឺជាភាពខុសគ្នារវាងការទូទាត់ដែលរំពឹងទុកដើម្បីទូទាត់សងអ្នកកាន់ឧបករណ៍បំណុលដែលបានធានា តិចជាងចំនួនដែលធនាគាររំពឹងថានឹងទទួលបានពីអ្នកកាន់កូនបំណុល ឬភាគីផ្សេងទៀត។
- ធនាគារវាស់វែង ECL លើមូលដ្ឋានបុគ្គល ឬនៅលើមូលដ្ឋានសមូហភាពសម្រាប់ផលប័ត្រប្រាក់កម្ចីដែលចែករំលែកលក្ខណៈហានិភ័យសេដ្ឋកិច្ចស្រដៀងគ្នា។ ការវាស់វែងនៃប្រាក់ឧបត្ថម្ភការខាតបង់គឺផ្អែកលើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុករបស់ទ្រព្យសកម្មដោយប្រើ EIR ដើមរបស់ទ្រព្យសកម្ម ដោយមិនគិតពីថាតើវាត្រូវបានវាស់វែងលើមូលដ្ឋានបុគ្គល ឬមូលដ្ឋានសមូហភាពនោះទេ។

#### *ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន*

ទ្រព្យសកម្មហិរញ្ញវត្ថុមួយមាន’ឱនភាពនៃតម្លៃឥណទាន’ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើន ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភពតម្លៃ ឥណទាន គឺត្រូវបានសំដៅថាជាទ្រព្យសកម្មដំណាក់កាលទី៣។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទាន រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានសង ឬហួសកាលកំណត់
- អ្នកផ្តល់ប្រាក់កម្ចីដល់អតិថិជន សម្រាប់ហេតុផលសេដ្ឋកិច្ច ឬកិច្ចសន្យាទាក់ទងនឹងការលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន ដោយមានការផ្តល់ការអនុគ្រោះដល់អតិថិជនដែលអ្នកផ្តល់ប្រាក់កម្ចីដែលនឹងមិនត្រូវបានពិចារណា
- ការបាត់បង់នៃទីផ្សារសកម្មមួយសម្រាប់មូលបត្រ ដោយសារការលំបាកផ្នែកហិរញ្ញវត្ថុ ឬ
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុក្នុងការបញ្ចុះតម្លៃយ៉ាងច្រើន ដែលឆ្លុះបញ្ចាំងពីការបាត់បង់ឥណទានដែលបានកើតឡើង។

វាប្រហែលជាមិនអាចកំណត់អត្តសញ្ញាណព្រឹត្តិការណ៍ដាច់ដោយឡែកតែមួយបានទេ។ ផ្ទុយទៅវិញ ឥទ្ធិពលរួមបញ្ចូលគ្នានៃព្រឹត្តិការណ៍ជាច្រើនអាចបណ្តាលឱ្យទ្រព្យសកម្មហិរញ្ញវត្ថុក្លាយជាឱនភាពនៃតម្លៃឥណទាន។ ធនាគារវាយតម្លៃថាតើឧបករណ៍បំណុលដែលជាទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់ ឬ FVTOCI ត្រូវបានធ្វើឱនភាពនៃតម្លៃឥណទាននៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ។ ដើម្បីវាយតម្លៃថាតើឧបករណ៍បំណុលរបស់រដ្ឋ និងសាជីវកម្មមានឱនភាពនៃតម្លៃឥណទាន ធនាគារពិចារណាលើកត្តាមួយចំនួនដូចជា ទិន្នផលសញ្ញាប័ណ្ណ ចំណាត់ថ្នាក់ឥណទាន និងលទ្ធភាពរបស់អ្នកខ្ចីក្នុងការប្រមូលមូលនិធិ។

ប្រាក់កម្ចីត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន នៅពេលដែលសម្បទានត្រូវបានផ្តល់ទៅឱ្យអ្នកខ្ចីដោយសារតែឱនភាពនៃតម្លៃឥណទាននៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី លុះត្រាតែមានភស្តុតាងដែលថាជាលទ្ធផលនៃការផ្តល់សម្បទានហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានកាត់បន្ថយយ៉ាងខ្លាំង និងមិនមានសូចនាករផ្សេងទៀតនៃឱនភាពនៃតម្លៃឥណទានទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលសម្បទានត្រូវបានពិចារណា ប៉ុន្តែមិនត្រូវបានផ្តល់ ទ្រព្យសកម្មត្រូវបានចាត់ទុកថាមានការថយចុះឥណទាន នៅពេលដែលមានភស្តុតាងដែលអាចសង្កេតបាននៃការថយចុះឥណទាន រួមទាំងការបំពេញតាមនិយមន័យនៃការខកខានសង។

និយមន័យនៃការខកខានសង (សូមមើលខាងក្រោម) រួមបញ្ចូលការមិនទំនងនៃសូចនាករនៃការទូទាត់ និងការមិនសងត្រឡប់ ប្រសិនបើសមតុល្យលើសកាលកំណត់សម្រាប់រយៈពេល ៩០ថ្ងៃ ឬច្រើនជាងនេះ។

### *និយមន័យនៃការខកខានសង*

ការវិនិច្ឆ័យចំពោះការកំណត់របស់ ECL គឺជានិយមន័យនៃការខកខានសង។ និយមន័យនៃការខកខានសងត្រូវបានប្រើក្នុងការវាស់វែងសមតុល្យ ECL និងក្នុងការកំណត់ថាតើការខាតបង់សំវិធានធនគឺផ្អែកលើ ECL ១២ខែ ឬពេញមួយអាយុកាល ដោយសារការខកខានសងគឺជាធាតុផ្សំនៃប្រូបាប៊ីលីតេនៃការខកខានសង ("PD") ដែលប៉ះពាល់ដល់ទាំងការវាស់វែងនៃ ECLs និងការកំណត់អត្តសញ្ញាណនៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន។

ធនាគារចាត់ទុកចំណុចដូចខាងក្រោមនេះថាជាព្រឹត្តិការណ៍នៃការខកខានសង៖

- អ្នកខ្ចីត្រូវផុតកំណត់លើសពី ៩០ថ្ងៃលើកាតព្វកិច្ចឥណទានជាសារវន្តណាមួយដល់ធនាគារ ឬ
- អ្នកខ្ចីទំនងជាមិនបង់កាតព្វកិច្ចឥណទានរបស់ខ្លួនដល់ធនាគារពេញលេញទេ។

និយមន័យនៃការខកខានសងនេះត្រូវបានប្រើប្រាស់ដោយធនាគារសម្រាប់គោលបំណងគណនេយ្យ ក៏ដូចជាសម្រាប់គោលបំណងគ្រប់គ្រងហានិភ័យឥណទានផ្ទៃក្នុង ហើយត្រូវបានតម្រឹមយ៉ាងទូលំទូលាយទៅនឹងនិយមន័យបទប្បញ្ញត្តិនៃការខកខានសង។ និយមន័យនៃការខកខានសងត្រូវបានកែសម្រួលយ៉ាងសមស្របដើម្បីឆ្លុះបញ្ចាំងពីលក្ខណៈផ្សេងៗគ្នានៃប្រភេទទ្រព្យសកម្មផ្សេងៗគ្នា។ ឥណទានវិបារូប៍ ត្រូវបានចាត់ទុកថាហួសកាលកំណត់ នៅពេលដែលអតិថិជនបានបំពានលើដែនកំណត់ដែលបានណែនាំ ឬត្រូវបានណែនាំពីដែនកំណត់តិចជាងសមតុល្យដែលនៅសល់។

នៅពេលវាយតម្លៃថាតើអ្នកខ្ចីទំនងជាមិនបង់កាតព្វកិច្ចឥណទានរបស់ខ្លួនទេ ធនាគារត្រូវគិតគូរទាំងសូចនាករគុណភាព និងបរិមាណ។ ព័ត៌មានដែលបានវាយតម្លៃអាស្រ័យលើប្រភេទនៃទ្រព្យសកម្ម ឧទាហរណ៍ក្នុងការផ្តល់ប្រាក់កម្ចីសាជីវកម្ម សូចនាករគុណភាពដែលត្រូវបានប្រើគឺជាការរំលោភលើកិច្ចព្រមព្រៀងដែលមិនពាក់ព័ន្ធសម្រាប់ការផ្តល់ប្រាក់កម្ចីលក់រាយ។ សូចនាករបរិមាណ ដូចជាស្ថានភាពហួសកាលកំណត់ និងការមិនបង់ប្រាក់លើកាតព្វកិច្ចផ្សេងទៀតរបស់ភាគីដូចគ្នា គឺជាធាតុចូលសំខាន់នៅក្នុងការវិភាគនេះ។ ធនាគារប្រើប្រភពព័ត៌មានជាច្រើនដើម្បីវាយតម្លៃការខកខានសងដែលត្រូវបានបង្កើតឡើងពីខាងក្នុង ឬទទួលបានពីប្រភពខាងក្រៅ។ ដូចដែលបានកត់សម្គាល់នៅក្នុងនិយមន័យនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទានខាងលើ ការខកខានសងគឺជាភស្តុតាងដែលបង្ហាញថាទ្រព្យសកម្មមួយត្រូវបានធ្វើឱនភាពឥណទាន។ ដូច្នេះ ទ្រព្យសកម្មដែលមានឱនភាពឥណទាន នឹងរួមបញ្ចូលទ្រព្យសកម្មដែលមិនមានការខកខានសង ប៉ុន្តែក៏នឹងរួមបញ្ចូលផងដែរនូវទ្រព្យសកម្មផ្សេងទៀតដែលមិនមានការខកខានសងដែលបានផ្តល់ឱ្យនិយមន័យនៃឱនភាពឥណទានគឺទូលំទូលាយជាងនិយមន័យនៃការខកខានសង។

### *ការកើនឡើងជាសារវន្តក្នុងហានិភ័យឥណទាន*

ធនាគារតាមដានទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ កិច្ចសន្យាឥណទានដែលបានចេញផ្សាយ និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវនៃឱនភាពតម្លៃ ដើម្បីវាយតម្លៃថាតើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង។ ប្រសិនបើមានការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ធនាគារនឹងវាស់វែងការខាតបង់សំវិធានធនដោយផ្អែកលើអាយុកាលជាជាង ECL រយៈពេល ១២ខែ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានហានិភ័យឥណទាន 'ទាប' នៅកាលបរិច្ឆេទរាយការណ៍ត្រូវបានចាត់ទុកថាមិនមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងហានិភ័យឥណទាន។ ជាលទ្ធផល ធនាគារតាមដានរាល់ទ្រព្យសកម្មហិរញ្ញវត្ថុ កិច្ចសន្យាឥណទានដែលបានចេញផ្សាយ និងកិច្ចសន្យាធានាហិរញ្ញវត្ថុដែលទទួលរងការឱនភាពនៃតម្លៃសម្រាប់ការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន។



ក្នុងការវាយតម្លៃថាតើហានិភ័យឥណទានលើឧបករណ៍ហិរញ្ញវត្ថុបានកើនឡើងយ៉ាងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូង ធនាគារប្រៀបធៀបហានិភ័យនៃការខកខានសងដែលកើតឡើងលើឧបករណ៍ហិរញ្ញវត្ថុនៅកាលបរិច្ឆេទរបាយការណ៍ដោយផ្អែកលើកាលកំណត់របស់ឧបករណ៍ជាមួយនឹងហានិភ័យនៃការខកខានកើតឡើងដែលត្រូវបានរំពឹងទុកសម្រាប់កាលកំណត់ដែលនៅសល់នៅកាលបរិច្ឆេទរបាយការណ៍បច្ចុប្បន្ន នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ជាលើកដំបូង។ ក្នុងការធ្វើការវាយតម្លៃនេះ ធនាគារពិចារណាទាំងព័ត៌មានបរិមាណ និងគុណភាព ដែលសមហេតុផល និងអាចគាំទ្របាន រួមទាំងបទពិសោធន៍ប្រវត្តិសាស្ត្រ និងព័ត៌មាននាពេលអនាគតដែលអាចរកបានដោយមិនចាំបាច់ចំណាយឬខិតខំប្រឹងប្រែង ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្ររបស់ធនាគារ និងការវាយតម្លៃឥណទានរបស់អ្នកជំនាញ រួមទាំងការប្រមើលមើលព័ត៌មាននាពេលអនាគត។

សេណារីយ៉ូសេដ្ឋកិច្ចជាច្រើនបង្កើតជាមូលដ្ឋាននៃការកំណត់ប្រូបាប៊ីលីតេនៃការខកខានសងនៅពេលទទួលស្គាល់ដំបូង និងនៅកាលបរិច្ឆេទរាយការណ៍ជាបន្តបន្ទាប់។ សេណារីយ៉ូសេដ្ឋកិច្ចផ្សេងគ្នានឹងនាំឱ្យមានប្រូបាប៊ីលីតេខុសគ្នានៃការខកខានសង។ វាគឺជាការថ្លឹងថ្លែងនៃសេណារីយ៉ូផ្សេងៗគ្នាទាំងនេះ ដែលបង្កើតជាមូលដ្ឋាននៃប្រូបាប៊ីលីតេមធ្យមដែលមានទម្ងន់នៃការខកខានសងដែលត្រូវបានប្រើដើម្បីកំណត់ថាតើហានិភ័យឥណទានបានកើនឡើងយ៉ាងខ្លាំងឬយ៉ាងណា។

សម្រាប់ការផ្តល់ប្រាក់កម្ចីសាជីវកម្ម ការប្រមើលមើលព័ត៌មាននាពេលអនាគតរួមមានការរំពឹងទុកនាពេលអនាគតនៃឧស្សាហកម្មដែលសមភាគីរបស់ធនាគារដំណើរការ ទទួលបានពីរបាយការណ៍អ្នកជំនាញសេដ្ឋកិច្ច អ្នកវិភាគហិរញ្ញវត្ថុ ស្ថាប័នរដ្ឋាភិបាល ស្ថាប័នគិតគូរដែលពាក់ព័ន្ធ និងអង្គការស្រដៀងគ្នាផ្សេងទៀត ក៏ដូចជាការពិចារណាផ្ទៃក្នុងផ្សេងៗ និងប្រភពខាងក្រៅនៃព័ត៌មានសេដ្ឋកិច្ចជាក់ស្តែង និងការព្យាករណ៍។ សម្រាប់ការលក់រាយ ការផ្តល់ប្រាក់កម្ចីព័ត៌មានដែលមើលទៅខាងមុខរួមមានការព្យាករណ៍សេដ្ឋកិច្ចដូចគ្នានឹងការផ្តល់ប្រាក់កម្ចីសាជីវកម្មជាមួយនឹងការព្យាករណ៍បន្ថែមនៃសូចនាករសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសសម្រាប់តំបន់ដែលមានការប្រមូលផ្តុំទៅឧស្សាហកម្មជាក់លាក់ ក៏ដូចជាព័ត៌មានដែលបានបង្កើតផ្ទៃក្នុងនៃឥរិយាបថទូទាត់របស់អតិថិជន។ ធនាគារបែងចែកសមភាគីរបស់ខ្លួនទៅក្នុងចំណាត់ថ្នាក់ហានិភ័យឥណទានផ្ទៃក្នុងដែលពាក់ព័ន្ធ អាស្រ័យលើគុណភាពឥណទានរបស់ពួកគេ។ ព័ត៌មានបរិមាណគឺជាសូចនាករចម្បងនៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទាន ហើយផ្អែកលើការផ្លាស់ប្តូរនៅក្នុង PD ពេញមួយអាយុកាលដោយការប្រៀបធៀប៖

- PD ពេញមួយអាយុកាលដែលនៅសល់នៅកាលបរិច្ឆេទនៃរបាយការណ៍ជាមួយនឹង
- PD ពេញមួយអាយុកាលដែលនៅសេសសល់សម្រាប់ចំណុចនេះនៅក្នុងពេលវេលាដែលត្រូវបានប៉ាន់ប្រមាណដោយផ្អែកលើការពិតនិងកាលៈទេសៈនៅពេលនៃការទទួលស្គាល់ដំបូងនៃការបង្ហាញ។

PDs ដែលត្រូវបានប្រើប្រាស់គឺមានការប្រមើលមើល ហើយធនាគារប្រើប្រាស់វិធីសាស្ត្រ និងទិន្នន័យដូចគ្នាដែលត្រូវបានប្រើដើម្បីវាស់ស្ទង់ការខាតបង់សម្រាប់ ECL។ កត្តាគុណភាពដែលបង្ហាញពីការកើនឡើងយ៉ាងសំខាន់នៃហានិភ័យឥណទានត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគំរូ PD ទាន់ពេលវេលា។ ទោះជាយ៉ាងណាក៏ដោយ ធនាគារនៅតែពិចារណាដាច់ដោយឡែកពីគ្នានូវកត្តាគុណភាពមួយចំនួន ដើម្បីវាយតម្លៃថាតើហានិភ័យឥណទានមានការកើនឡើងគួរឱ្យកត់សម្គាល់ដែរឬទេ។ សម្រាប់ការផ្តល់ប្រាក់កម្ចីសាជីវកម្មមានការផ្តោតជាពិសេសទៅលើទ្រព្យសកម្មដែលត្រូវបានបញ្ចូលក្នុង 'បញ្ជីតាមដាន' ដែលបានផ្តល់ឱ្យការលេចចេញនូវបញ្ជីតាមដាននៅពេលដែលមានការព្រួយបារម្ភថាភាពសក្តិសមនៃឥណទាន

របស់សមភាគីជាក់លាក់បានធ្លាក់ចុះ។ សម្រាប់ការផ្តល់ប្រាក់កម្ចីលក់រាយ ធនាគារពិចារណាលើការរំពឹងទុកនៃការអត់ធ្មត់ និងរយៈពេលនៃការលើកលែងការទូទាត់ ពិន្ទុឥណទាន និងព្រឹត្តិការណ៍ដូចជាភាពអត់ការងារធ្វើ ការក្ស័យធន ការលែងលះ ឬមរណភាព។

ដោយសារការកើនឡើងនូវហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់ដំបូង គឺជាវិធានការទាក់ទងការផ្លាស់ប្តូរ PD ជាក់ស្តែង និងកាន់តែមានចំនួនច្រើនសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ទាប បើប្រៀបធៀបទៅនឹងឧបករណ៍ហិរញ្ញវត្ថុដែលមាន PD ខ្ពស់ជាងនេះ នៅពេលកត់ត្រា។

ជាគោលនៅពេលដែលទ្រព្យសកម្មបានផុតកំណត់សងលើស ៣០ថ្ងៃ ធនាគារចាត់ទុកថាមានការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត ហើយទ្រព្យសកម្មស្ថិតក្នុងដំណាក់កាលទី ២ នៃគំរូឱនភាពនៃតម្លៃ ពោលគឺសំវិធានធនខាតបង់ត្រូវបានវាស់វែងជា ECL ពេញមួយអាយុកាល។ បន្ថែមលើឥណទានដែលត្រូវបានវាយតម្លៃជាលក្ខណៈបុគ្គល និងត្រូវបានបញ្ចូលក្នុងបញ្ជីឃ្លាំមើលគឺ ស្ថិតក្នុងដំណាក់កាលទី២ នៃគំរូឱនភាពតម្លៃ។ ដូចបានកត់សម្គាល់ប្រសិនបើមានភស្តុតាងបង្ហាញពីទ្រព្យសកម្មមានឱនភាពឥណទានស្ថិតក្នុងដំណាក់កាលទី ៣ នៃគំរូឱនភាពតម្លៃ។

### *ការជម្រះចេញពីបញ្ជី*

ឥណទាន និងមូលបត្របំណុលត្រូវបានជម្រះចេញពីបញ្ជី (ជាផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកសមហេតុផលថា អាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ឬចំណែកណាមួយ។ ករណីនេះមាន ជាទូទៅ នៅពេលសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការជម្រះចេញពីបញ្ជីជាព្រឹត្តិការណ៍ឈប់ទទួលស្គាល់។ ធនាគារអាចអនុវត្តសកម្មភាពអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានជម្រះចេញពីបញ្ជី។ ការស្តារដែលកើតចេញពីសកម្មភាពអនុវត្តរបស់ធនាគារនឹងបណ្តាលឱ្យមានការកើនឡើងនៃឱនភាពតម្លៃ ដែលនឹងត្រូវបានបង្ហាញនៅក្នុង ‘ការខាតបង់ឱនភាពនៃតម្លៃសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ/ប្រាក់ចំណូលផ្សេងទៀត’ នៅក្នុងគណនីចំណេញ ឬខាត។

### *ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ*

សំវិធានធនខាតបង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់៖ ជាការកាត់បន្ថយពីតម្លៃយោងដុលរបស់ទ្រព្យសកម្ម
- សម្រាប់ការសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាទូទៅជាការធ្វើសំវិធានធន និង
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុមួយរួមបញ្ចូលទាំងសមាសធាតុមិនទាន់បានប្រើប្រាស់ និងបានប្រើប្រាស់ ហើយធនាគារមិនអាចកំណត់ ECLលើសមាសធាតុការសន្យាផ្តល់ឥណទានដោយឡែកពីសមាសធាតុនៃការសន្យាផ្តល់ឥណទានដែលបានប្រើប្រាស់ធនាគារធ្វើការបង្ហាញសំវិធានធនខាតបង់រួមបញ្ចូលគ្នាសម្រាប់សមាសធាតុទាំងពីរ។ ចំនួនរួមបញ្ចូលគ្នាត្រូវបានបង្ហាញ ជាការកាត់ចេញពីតម្លៃយោងដុលនៃសមាសធាតុដែលបានប្រើប្រាស់។ ចំនួនលើសរបស់ សំវិធានធនខាតបង់លើតម្លៃយោងដុលនៃសមាសធាតុ ដែលបានប្រើប្រាស់ត្រូវបានបង្ហាញជាការធ្វើសំវិធានធន។



## ៤.៥.៨ បំណុលហិរញ្ញវត្ថុ និងមូលធន

ឧបករណ៍បំណុល និងមូលធនដែលបានអនុម័តត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ ឬមូលធនស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យាដែលមាននៅក្នុងកិច្ចព្រមព្រៀង។

បំណុលហិរញ្ញវត្ថុគឺជាកាតព្វកិច្ចតាមកិច្ចសន្យា ក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬដើម្បីប្តូរទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាមួយអង្គភាពផ្សេងទៀតក្រោមលក្ខខណ្ឌដែលមិនអំណោយផលដល់ធនាគារ ឬកិច្ចសន្យាដែលនឹង ឬអាចត្រូវបានទូទាត់ជាភាគហ៊ុនផ្ទាល់របស់ធនាគារ និងកិច្ចសន្យាមិនមែននិស្សន្ទ ដែលធនាគារមាន ឬត្រូវមានកាតព្វកិច្ចផ្តល់នូវចំនួនអថេរនៃភាគហ៊ុនផ្ទាល់របស់ខ្លួន ឬកិច្ចសន្យាចម្លងពីភាគហ៊ុនផ្ទាល់ដែលនឹងត្រូវបានទូទាត់ក្រៅពីការដោះដូរចំនួនទឹកប្រាក់ថេរនៃសាច់ប្រាក់ (ឬទ្រព្យសកម្មហិរញ្ញវត្ថុមួយផ្សេងទៀត) សម្រាប់ចំនួនថេរនៃឧបករណ៍ទ្រព្យមូលធនផ្ទាល់ខ្លួនរបស់ធនាគារ។

ឧបករណ៍មូលធន គឺជាកិច្ចសន្យាណាមួយដែលបង្ហាញពីការប្រាក់ដែលនៅសេសសល់នៅក្នុងទ្រព្យសកម្មរបស់អង្គភាពបន្ទាប់ពីកាត់កងបំណុលទាំងអស់របស់ខ្លួន។

ឧបករណ៍មូលធនដែលចេញផ្សាយដោយធនាគារត្រូវបានទទួលស្គាល់តាមសាច់ប្រាក់ដែលទទួលបានដកចំណាយចេញផ្សាយដោយផ្ទាល់។ ការទិញឧបករណ៍មូលធនផ្ទាល់ខ្លួនរបស់ធនាគារត្រូវបានទទួលស្គាល់ និងកាត់កងដោយផ្ទាល់នៅក្នុងមូលធន។ គ្មានការចំណេញ/ខាតណាមួយត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬការបាត់បង់លើការទិញ ការលក់ ការចេញ ឬការលុបចោលឧបករណ៍ភាគហ៊ុនផ្ទាល់ខ្លួនរបស់ធនាគារនោះទេ។

### *បំណុលហិរញ្ញវត្ថុផ្សេងៗ*

បំណុលហិរញ្ញវត្ថុផ្សេងទៀត រួមមានប្រាក់កម្ចីដែលត្រូវបានវាស់វែងជាដំបូងតាមតម្លៃសមស្រប ដកថ្លៃប្រតិបត្តិការសុទ្ធ។ បំណុលហិរញ្ញវត្ថុផ្សេងទៀតត្រូវបានវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមបានរំលស់ដោយប្រើវិធីសាស្រ្តការប្រាក់មានប្រសិទ្ធភាព។

### *ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ*

សម្រាប់បំណុលហិរញ្ញវត្ថុដែលកំណត់ជារូបិយប័ណ្ណបរទេស ហើយត្រូវបានវាស់វែងតាមថ្លៃដើមបានរំលស់នាចុងបញ្ចប់នៃរយៈពេលរាយការណ៍នីមួយៗ ចំណេញ និងខាតនៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេសត្រូវបានកំណត់ដោយផ្អែកលើថ្លៃដើមបានរំលស់នៃឧបករណ៍។ ការកើនឡើង និងការខាតបង់នៃការផ្លាស់ប្តូររូបិយប័ណ្ណបរទេសទាំងនេះត្រូវបានទទួលស្គាល់នៅក្នុងសមាសធាតុខ្ទង់ 'ចំណេញ និងខាតផ្សេងទៀត' នៅក្នុងចំណេញ ឬខាតសម្រាប់បំណុលហិរញ្ញវត្ថុដែលមិនមែនជាផ្នែកនៃទំនាក់ទំនងការពារហានិភ័យដែលបានកំណត់។ សម្រាប់អ្នកដែលត្រូវបានកំណត់ថាជាឧបករណ៍ការពារហានិភ័យសម្រាប់ការការពារហានិភ័យនៃរូបិយប័ណ្ណបរទេស ការកើនឡើង និងការខាតបង់នៃការប្តូររូបិយប័ណ្ណបរទេសត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណូលលម្អិតផ្សេងទៀត និងបង្គរនៅក្នុងផ្នែកដាច់ដោយឡែកនៃមូលធន។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុដែលជារូបិយប័ណ្ណបរទេសត្រូវបានកំណត់ជារូបិយប័ណ្ណបរទេសនោះ ហើយត្រូវបានបកប្រែតាមអត្រាការប្រាក់នៅចុងបញ្ចប់នៃរយៈពេលរាយការណ៍។ សម្រាប់បំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដូចនៅ FVTPL សមាសធាតុប្តូរប្រាក់បរទេសបង្កើតបានជាផ្នែកនៃការកើនឡើង ឬខាតតម្លៃសមស្រប ហើយត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ ឬការបាត់បង់សម្រាប់បំណុលហិរញ្ញវត្ថុដែលមិនមែនជាផ្នែកនៃទំនាក់ទំនងការពារហានិភ័យដែលបានកំណត់។

### *ការកែប្រែ និងការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ*

ធនាគារមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែគឺខុសគ្នាខ្លាំង។ ក្នុងករណីនេះ ទំនួលខុសត្រូវហិរញ្ញវត្ថុថ្មីដោយផ្អែកលើលក្ខខណ្ឌដែលបានកែប្រែត្រូវបានទទួលស្គាល់ដោយតម្លៃសមស្រប។ ភាពខុសគ្នារវាងចំនួនទឹកប្រាក់អនុវត្តនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានទទួលស្គាល់ និងការពិចារណាដែលបានបង់ត្រូវបានទទួលស្គាល់ជាចំណេញ និងខាត។ ការពិចារណាដែលបានបង់រួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរប្រសិនបើមាន និងការសន្មតនៃបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុមិនត្រូវបានរាប់បញ្ចូលជាការដកហូតទេ នោះថ្លៃដើមបានរំលស់នៃបំណុលត្រូវបានគណនាឡើងវិញដោយការធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែក្នុងអត្រាការប្រាក់ដើមដែលមានប្រសិទ្ធភាព ហើយផលចំណេញ ឬការខាតត្រូវបានទទួលស្គាល់ជាចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអណ្តែត អត្រាការប្រាក់មានប្រសិទ្ធភាពដើមដែលប្រើដើម្បីគណនាការកែប្រែ ឬខាតត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលនៃការកែប្រែ។ ការចំណាយ និងថ្លៃសេវាណាមួយដែលកើតឡើងត្រូវបានទទួលស្គាល់ថាជាការកែតម្រូវលើចំនួនបំណុលដែលជាប់ទាក់ទង និងបានរំលស់ក្នុងរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែដោយគណនាឡើងវិញនូវអត្រាការប្រាក់ដែលមានប្រសិទ្ធភាពលើឧបករណ៍។

## ៤.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

សមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់តាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃ។ នៅពេលដែលសមាសធាតុនៃទ្រព្យសម្បត្តិ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា នោះត្រូវបានរាប់ជាធាតុដាច់ដោយឡែក (ធាតុផ្សំសំខាន់ៗ) នៃទ្រព្យសម្បត្តិ និងបរិក្ខារ។

ចំណេញ ឬខាតណាមួយលើការលុបចោលនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។

រំលស់ត្រូវបានគណនាដើម្បីលុបថ្លៃដើមនៃទ្រព្យសម្បត្តិ និងបរិក្ខារចេញពីបញ្ជី ដកតម្លៃសំណល់ដែលបានប៉ាន់ស្មានរបស់ពួកគេ ដោយប្រើវិធីរំលស់ថេរលើអាយុកាលប្រើប្រាស់ដែលបានប៉ាន់ស្មានទុក ហើយជាទូទៅត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិត។

| | អាយុកាលប្រើប្រាស់ដោយផ្អែកលើចំនួននៃឆ្នាំ |
|---|---|
| ការកែលម្អទ្រព្យជួល | ៥ |
| បរិក្ខារ | ៤ |
| បរិក្ខារកុំព្យូទ័រ | ៣ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ៤ |
| យានយន្ត | ៥ |

វិធីសាស្ត្រនៃការរំលស់ អាយុកាលប្រើប្រាស់ និងតម្លៃសំណល់ត្រូវបានត្រួតពិនិត្យតាមកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ និងបានកែសម្រួលប្រសិនបើសមស្រប។

ទ្រព្យសកម្មដែលកំពុងដំណើរការមិនត្រូវបានធ្វើរំលស់ទេ រហូតដល់រួចរាល់សម្រាប់ប្រើប្រាស់តាមបំណងរបស់គណៈគ្រប់គ្រង។



ការចំណាយបន្តបន្ទាប់ត្រូវបានបញ្ចូលជាមូលធនកម្មតែនៅពេលដែលវាអាចទៅរួចដែលថាអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃការចំណាយនឹងហូរទៅធនាគារ។ ការជួសជុល និងថែទាំបន្តត្រូវបានចំណាយដូចដែលបានកើតឡើង។

ចំណេញ ឬខាតលើការលុបចោលនៃទ្រព្យសម្បត្តិ និងបរិក្ខារត្រូវបានកំណត់ដោយការប្រៀបធៀបប្រាក់ចំណូលដែលបានមកពីការលុបចោលជាមួយនឹងបរិមាណនៃទ្រព្យសម្បត្តិ និងបរិក្ខារ ហើយត្រូវបានទទួលស្គាល់សុទ្ធនៅក្នុង "ចំណូលផ្សេងទៀត" នៅក្នុងរបាយការណ៍នៃចំណូលលម្អិត។

ទ្រព្យសម្បត្តិ និងបរិក្ខារដែលបានរំលស់ពេញលេញ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរហូតដល់ត្រូវបានលុបចោល ឬជម្រះចេញពីបញ្ជី។

## ៤.៧ ទ្រព្យសកម្មអរូបី

កម្មវិធីកុំព្យូទ័រ និងថ្លៃដើមដែលពាក់ព័ន្ធ ត្រូវបានបង្ហាញតាមការថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ។ រំលស់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណូលលម្អិតនៅលើមូលដ្ឋានរំលស់ថេរក្នុងអត្រា ២០% ក្នុងមួយឆ្នាំ។ ប្រសិនបើមានការចង្អុលបង្ហាញថាមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងអត្រារំលស់ ឬអាយុមានប្រយោជន៍នៃទ្រព្យសកម្មអរូបី រំលស់ត្រូវបានកែសម្រួលជាអនាគត ដើម្បីឆ្លុះបញ្ចាំងពីការរំពឹងទុកថ្មី។

កម្មវិធីកុំព្យូទ័រដែលកំពុងដំណើរការមិនត្រូវបានរំលស់ទេ រហូតដល់រួចរាល់សម្រាប់ប្រើប្រាស់តាមបំណងដោយគណៈគ្រប់គ្រង។

## ៤.៨ ភតិសន្យា

ធនាគារវាយតម្លៃថាតើកិច្ចសន្យា ឬជាភតិសន្យា នាកាលបរិច្ឆេទនៃការចាប់ផ្តើមកិច្ចសន្យា។

ធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម និងការទទួលខុសត្រូវលើបំណុលភតិសន្យាដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងភតិសន្យាទាំងអស់ក្នុងនាមជាភតិកៈ លើកលែងតែភតិសន្យាដែលមានរយៈពេលខ្លី។ សម្រាប់ភតិសន្យាទាំងនេះ ធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាជាចំណាយប្រតិបត្តិការលើមូលដ្ឋានរំលស់ថេរលើរយៈពេលភតិសន្យា។

### *សិទ្ធិប្រើប្រាស់លើទ្រព្យសកម្ម*

សិទ្ធិប្រើប្រាស់លើទ្រព្យសកម្មរួមមានការវាស់វែងដំបូងទៅលើបំណុលភតិសន្យាដែលស្របគ្នា ការទូទាត់ភតិសន្យាត្រូវបានធ្វើឡើងនាឬមុនកាលបរិច្ឆេទចាប់ផ្តើមដំបូង ដកចេញនូវរាល់អត្ថប្រយោជន៍ពីភតិសន្យាដែលបានទទួល និងរាល់ថ្លៃដើមផ្ទាល់ដំបូង។ វាត្រូវបានវាស់វែងជាបន្តបន្ទាប់តាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់ឱនភាពតម្លៃ។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវធ្វើរំលស់ក្នុងរយៈពេលភតិសន្យាដែលខ្លី និងអាយុកាលប្រើប្រាស់នៃទ្រព្យសកម្មយោង។ រំលស់ចាប់ផ្តើមពីកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### *បំណុលភតិសន្យា*

បំណុលភតិសន្យា ត្រូវបានវាស់ដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ដែលមិនត្រូវបានបង់នៅកាលបរិច្ឆេទចាប់ផ្តើមដោយបានអប្បហារដោយប្រើអត្រាប្រាក់កម្ចីបន្ថែមដែលការប្រាក់នៃធនាគារដែលធនាគារនឹងបង់ទៅឱ្យអតិថិជនលើ

កាលកំណត់ស្រដៀងគ្នា ជាមួយនឹងមូលនិធិធានាស្រដៀងគ្នាដើម្បីទទួលបានទ្រព្យសកម្មនៃតម្លៃសិទ្ធិប្រើប្រាស់លើទ្រព្យសកម្មស្រដៀងគ្នាក្នុងបរិបទសេដ្ឋកិច្ចស្រដៀងគ្នា។

ការទូទាត់ភតិសន្យាដែលមាននៅក្នុងការវាស់វែងនៃបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេរ ដកចេញប្រាក់លើកទឹកចិត្តដែលអាចទទួលបាន និង
- ការបង់ប្រាក់ពិន័យ សម្រាប់ការបញ្ចប់កិច្ចសន្យាជួល ប្រសិនបើរយៈពេលជួលនោះឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសដើម្បីបញ្ចប់កិច្ចសន្យាភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់ជាបន្តបន្ទាប់ដោយការបង្កើនសមតុល្យ ដើម្បីឆ្លុះបញ្ចាំងពីការប្រាក់លើបំណុលភតិសន្យា (ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព) និងដោយកាត់បន្ថយសមតុល្យយោង ដើម្បីឆ្លុះបញ្ចាំងពីការទូទាត់ភតិសន្យាដែលបានធ្វើឡើង។

ធនាគារវាស់វែងឡើងវិញនូវបំណុលភតិសន្យា (និងធ្វើនិយ័តកម្មលើសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម) នៅពេលដែល៖

- រយៈពេលភតិសន្យាត្រូវបានផ្លាស់ប្តូរ ឬនៅពេលមានការផ្លាស់ប្តូរព្រឹត្តិការណ៍ ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរការវាយតម្លៃនៃជម្រើសទិញ ក្នុងករណីដែលបំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញដោយធ្វើអប្បហារទៅលើការទូទាត់ភតិសន្យាដែលបានកែសម្រួល ដោយប្រើអត្រាអប្បហារដែលបានកែសម្រួលឡើងវិញ។
- កិច្ចសន្យាភតិសន្យាត្រូវបានកែប្រែ ហើយការកែប្រែនៃភតិសន្យាមិនត្រូវបានចាត់ទុកជាភតិសន្យាដាច់ដោយឡែកនោះទេ ក្នុងករណីនេះ បំណុលភតិសន្យាត្រូវបានវាស់ឡើងវិញដោយផ្អែកលើរយៈពេលភតិសន្យាកែប្រែដោយធ្វើអប្បហារទៅលើការទូទាត់ភតិសន្យា ដោយប្រើអត្រាអប្បហារដែលបានកែសម្រួលឡើងវិញទៅតាមកាលបរិច្ឆេទនៃការកែប្រែ។

### *ភតិសន្យារយៈពេលខ្លី និងភតិសន្យាដែលមានតម្លៃទាប*

ធនាគារអនុវត្តការលើកលែងការទទួលស្គាល់ភតិសន្យារយៈពេលខ្លីទៅលើការជួលយានយន្តរយៈពេលខ្លីរបស់ខ្លួន (ឧទាហរណ៍ ភតិសន្យាទាំងនោះដែលមានរយៈពេលភតិសន្យា ១២ខែ ឬតិចជាងចាប់ពីការចាប់ផ្តើម និងមិនមានជម្រើសទិញទេ)។ ធនាគារក៏អនុវត្តចំពោះការលើកលែងការទទួលស្គាល់ភតិសន្យាដែលមានតម្លៃទាបដែរ ប្រសិនបើមាន។ ការទូទាត់ភតិសន្យាលើភតិសន្យារយៈពេលខ្លី និងភតិសន្យាដែលមានទ្រព្យសកម្មតម្លៃទាប ត្រូវបានទទួលស្គាល់ជាចំណាយលើមូលដ្ឋានរំលស់ថេរលើកាលកំណត់ភតិសន្យា។

## ៤.៩ ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

សមតុល្យយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានត្រួតពិនិត្យតាមកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗដើម្បីកំណត់ថាតើមានសូចនាករនៃឱនភាពនៃតម្លៃ។ ប្រសិនបើមានការកើតឡើង សមតុល្យដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានប៉ាន់ស្មាន។

សមតុល្យដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីសមតុល្យដែលអាចប្រមូលមកវិញបាន គឺដោយយកតម្លៃសមស្របដកចំណាយក្នុងការលក់។ ក្នុងការវាយតម្លៃ តម្លៃក្នុងការប្រើប្រាស់ ការប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលត្រូវបានធ្វើអប្បហារលើតម្លៃបច្ចុប្បន្នដោយប្រើប្រាស់អត្រាអប្បហារបង់ពន្ធមុនដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់នៃទ្រព្យសកម្ម។ សម្រាប់គោលបំណងក្នុងការធ្វើតេស្តឱនភាពតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមចំពោះទ្រព្យសកម្មដែលតូចដែលបម្លែងលំហូរសាច់ប្រាក់ពីការបន្តប្រើប្រាស់ដែលមានឯករាជ្យភាពនៃលំហូរសាច់ប្រាក់នៃទ្រព្យសកម្មផ្សេងទៀត ឬក្រុមទ្រព្យសកម្ម (“ឯកតាបង្កើតសាច់ប្រាក់”)។



ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើសមតុល្យយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់លើសពីសមតុល្យដែលអាចប្រមូលមកវិញបានដែលបានប៉ាន់ស្មាន។ ការខាតបង់ឱនភាពតម្លៃ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណូលលម្អិត។

## ៤.១០ អត្ថប្រយោជន៍និយោជិត

### *អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានបង្គរក្នុងការិយបរិច្ឆេទដែលសេវាកម្មជាប់ពាក់ព័ន្ធ ត្រូវបានផ្តល់ដោយនិយោជិតរបស់ធនាគារ។

## ៤.១១ សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលពីព្រឹត្តិការណ៍កន្លងមក ហើយប្រហែលជាលំហូរចេញនៃធនធានដែលរួមមាននូវអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនឹងត្រូវឱ្យទូទាត់នូវកាតព្វកិច្ច។ ប្រសិនបើមានផលប៉ះពាល់ជាសារវន្តសំវិធានធនត្រូវបានកំណត់ដោយការធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុកតាមអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងនូវការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃពេលវេលានៃទឹកប្រាក់ និងហានិភ័យជាក់លាក់នៃបំណុល។

## ៤.១២ វិភាគទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (“MEF”)

វិភាគទានពី MEF តំណាងឱ្យថ្លៃដើមនៃការចាប់ផ្តើមអាជីវកម្ម និងការកែលម្អទ្រព្យជួលរបស់ធនាគារដែលគ្រប់គ្រងដោយ MEF ។ ធនាគារបានទទួលស្គាល់ការចំណាយលើការចាប់ផ្តើមអាជីវកម្មដើម្បីរកប្រាក់ចំណេញ ឬខាត ខណៈដែលការចំណាយមូលធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ហើយត្រូវបានរំលស់ពេញមួយអាយុកាលប្រើប្រាស់។

ចំណាយចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម និងការកែលម្អទ្រព្យជួលត្រូវបានផ្ទេរចេញពេញលេញដោយ MEF ទៅធនាគារជាមួយនឹងលក្ខខណ្ឌមិនសងត្រឡប់។ ដូច្នេះ វិភាគទានពី MEF ត្រូវបានចាត់ទុកជាគណនីមូលធន។

## ៤.១៣ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព

អត្រាការប្រាក់ប្រសិទ្ធភាព (“EIR”) គឺជាអត្រាមួយដែលធ្វើអប្បហាការទូទាត់សាច់ប្រាក់នាពេលអនាគត ដែលរំពឹងទុករបស់អាយុកាលនៃទ្រព្យសកម្មហិរញ្ញវត្ថុ តាមរយៈអាយុកាលនៃឧបករណ៍ហិរញ្ញវត្ថុដែលបានរំពឹងទុក ឬបំណុលហិរញ្ញវត្ថុ ឱ្យស្មើនឹងសមតុល្យយោងសុទ្ធនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬថ្លៃដើមបានរំលស់នៃបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ធនាគារប៉ាន់ស្មានលំហូរសាច់ប្រាក់ដែលរំពឹងទុកដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនគិតពីការខាតបង់ឥណទានដែលរំពឹងទុកនោះទេ។ ការគណនារួមបញ្ចូលថ្លៃសេវា និងចំណាយទាំងអស់ដែលបានបង់ ឬទទួលបានរវាងភាគីនៃកិច្ចសន្យា ដែលជាផ្នែកសំខាន់មួយនៃអត្រាការប្រាក់ដ៏មានប្រសិទ្ធភាព ថ្លៃប្រតិបត្តិការ និងបុព្វលាភ ឬការធ្វើអប្បហារផ្សេងទៀត។

ការចំណាយលើប្រតិបត្តិការគឺជាការចំណាយបន្ថែមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញយក ការបោះផ្សាយ ឬការលក់ចេញទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ការចំណាយបន្ថែមគឺជាការចំណាយមួយដែលនឹងមិនត្រូវបានកើតឡើង ប្រសិនបើអង្គភាពមិនបានទិញ ចេញ ឬលក់ចេញឧបករណ៍ហិរញ្ញវត្ថុ។

### ៤.១៣.១ ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ និងខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វាត្រូវបានគណនាដោយការអនុវត្តអត្រាការប្រាក់ប្រសិទ្ធភាពចំពោះសមតុល្យយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែៈ

- ឱនភាពឥណទានទ្រព្យសកម្មហិរញ្ញវត្ថុដែលបានទិញ ឬដើម។ EIR ដែលកែតម្រូវដោយឥណទានត្រូវបានអនុវត្តតាមថ្លៃដើមដែលបានរំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនត្រូវបានទិញ ឬមានប្រភពមកពីទ្រព្យសកម្មហិរញ្ញវត្ថុដែលខូចគុណភាពឥណទាន ប៉ុន្តែក្រោយមកបានក្លាយទៅជាទ្រព្យសកម្មហិរញ្ញវត្ថុដែលខូចឥណទាន។ EIR ទៅនឹងតម្លៃរំលោះនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅក្នុងរយៈពេលរាយការណ៍ជាបន្តបន្ទាប់ត្រូវបានអនុវត្ត។

អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវដោយឥណទានគឺជាអត្រាដែលបញ្ចុះតម្លៃយ៉ាងពិតប្រាកដលើការទូទាត់សាច់ប្រាក់នាពេលអនាគតដែលបានប៉ាន់ប្រមាណឬបង្កាន់ដៃតាមរយៈអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងតម្លៃរំលោះនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលជាទ្រព្យសកម្មហិរញ្ញវត្ថុដែលខូចដោយឥណទានដែលបានទិញ ឬមានប្រភពដើម។

ចំណូលការប្រាក់ដែលត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពដែលបង្ហាញក្នុងរបាយការណ៍ចំណូលលម្អិតរួមមានការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់។

### ៤.១៣.២ ចំណាយការប្រាក់

ចំណាយការប្រាក់ក៏ត្រូវបានគណនាផងដែរដោយប្រើវិធីសាស្ត្រ EIR សម្រាប់បំណុលហិរញ្ញវត្ថុទាំងអស់ដែលធ្វើឡើងក្នុងថ្លៃដើមបានរំលស់។ ការចំណាយការប្រាក់ដែលបង្ហាញក្នុងរបាយការណ៍ចំណូលលម្អិតរួមមានបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមបានរំលស់។

## ៤.១៤ កម្រៃ និងចំណូលផ្សេងៗ

